# ទស្សនាវដ្តីកសិកម្ម

# THE AGRICULTURE MAGAZINE



ឆ្នាំទី ២០ ត្រីមាសទី ២ (មេសា-មិថុនា) ឆ្នាំ ២០២១ លេខ ៧៨

អាសយដ្ឋានលេខ:២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១/ទូរសារលេខ : (៨៥៥)២៣ ២១៧ ៣២០
គេហទំព័រ : http://www.maff.gov.kh
e-mail : info@maff.gov.kh

# មាតិកា ទំព័រ


- ព្រះរាជសារ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........................................ ០១
- ព្រះរាជសារ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........................................ ០២
- ព្រះរាជសារ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ នៃព្រះរាជាណាចក្រកម្ពុជា** ជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........................................ ០៣
- សុន្ទរកថាឯកឧត្តម **វេង សាខុន**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម........................................ ០៤
- ជំនួយស្មារតីឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ដំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE........................... ១០
- ដំណាំមន........................................ ១៦
- ចំណេះដឹងស្តីអំពីសុខភាពសត្វ(បន្តពីទស្សនាវដ្តីកសិកម្ម លេខ៧៧) ........................................ ៣០
- បច្ចេកទេសដាំដំណាំកៅស៊ូជាលក្ខណៈគ្រួសារ (បន្តពីទស្សនាវដ្តីកសិកម្មលេខ៧៧)........................... ៣៨
- ការគ្រប់គ្រងព្រៃប្រកបដោយនិរន្តរភាពតាមរយៈយន្តការរេនបូកនៅខេត្តកំពង់ធំ........................... ៤៤
- របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆមាសទី១ ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត........................................ ៤៦
- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........................................ ៦១

# ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ
# នរោត្តម សីហមុនី
# ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ជូន ឯកឧត្តម **វេង សាខុន**
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្តម ជាទីរាប់អានដ៏ខ្ពង់ខ្ពស់

ខ្ញុំបានទទួលរួចហើយនូវលិខិតរបស់ឯកឧត្តម ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ដែលបានថ្វាយសព្ទសាធុការពរជ័យ ចំពោះខ្ញុំ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ឆ្នាំ២០២១ ។

ខ្ញុំសូមអរគុណ និងសូមប្រសិទ្ធពរជ័យ បវរសួស្ដី សិរីមង្គល វិបុលសុខគ្រប់ប្រការ នៅក្នុងទិវាដ៏នក្ខត្តឫក្ស នៃបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំឆ្លូវ ដ៏ឧត្តុង្គឧត្តមនេះ សូម ឯកឧត្តម ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកបតែនឹងព្រះពុទ្ធពរគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម ឯកឧត្តម ទទួលនូវសេចក្ដីរាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២១

# ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ
# នរោត្តម សីហមុនី
# ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ជូន ឯកឧត្តម **វេង សាខុន**
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្តម ជាទីរាប់អានដ៏ខ្ពង់ខ្ពស់

ខ្ញុំបានទទួលរួចហើយនូវលិខិត ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ របស់ឯកឧត្តម ដែលបានថ្វាយសព្ទសាធុការពរចំពោះខ្ញុំ ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនជន្មាយុ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ។

ខ្ញុំសូមអរគុណ និងសូមកោតសរសើរចំពោះឯកឧត្តម និងសហការីទាំងអស់ ដែលបានចូលរួមអនុវត្តតាមវិធានការរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បានល្អប្រសើរ ។

ខ្ញុំសូមជូនពរ ឯកឧត្តម ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកបតែនឹងព្រះពុទ្ធពរគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម ទទួលនូវសេចក្ដីរាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២១

**សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតា**
**នរោត្តម មុនិនាថ សីហនុ**
**នៃព្រះរាជាណាចក្រកម្ពុជា**

ជូន ឯកឧត្ដម វេង សាខុន
រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្ដម

ខ្ញុំ សូមអរគុណដ៏ជ្រាលជ្រៅ ចំពោះលិខិតថ្វាយព្រះពររបស់ឯកឧត្ដម នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥។

សូមជូនពរឯកឧត្ដម ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកបតែនឹងព្រះពុទ្ធពរគ្រប់ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងទទួលនូវសេចក្ដីរាប់អាន អំពីខ្ញុំ។

**នរោត្តម មុនិនាថ សីហនុ**

ភ្នំពេញ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១

# សុន្ទរកថា
# ឯកឧត្តម វេង សាខុន
# រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ថ្លែងក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម

ថ្ងៃអង្គារ ៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១

**គណៈអធិបតី**

- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ
- សមាជិក សមាជិកា នៃអង្គពិធីទាំងមូលជាទីមេត្រី!



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*

ជាបឋមក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ព្រមទាំងសមាជិក សមាជិកានៃអង្គពិធីទាំងមូលដែលបានអញ្ជើញចូលរួមក្នុង ពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម នាពេលនេះ។

ប្រាកដណាស់ថា កិច្ចប្រជុំបូកសរុបដែលបានប្រព្រឹត្តទៅអស់រយៈពេល ២ថ្ងៃមកនេះ មិនត្រឹមតែជាឱកាសមួយសម្រាប់យើងទាំងអស់គ្នាចូលរួមពិភាក្សាចែករំលែកទស្សនៈ និងផ្តល់នូវធាតុចូលជាគំនិតថ្មីៗ លើលទ្ធផលការងារ កាលានុវត្តភាព និងបញ្ហាប្រឈមផ្សេងៗដែលយើងបានជួបប្រទះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឱកាសសម្រាប់យើងទាំងអស់គ្នាបូកសរុប និងវាយតម្លៃលើសមិទ្ធផលដែលយើងសម្រេចបានក្នុងឆ្នាំកន្លងមក ព្រមទាំងរិះរកគ្រប់មធ្យោបាយ ដើម្បីកំណត់បណ្តាសកម្មភាព ជាអាទិភាពឈានឆ្ពោះទៅរកការអភិវឌ្ឍវិស័យកសិកម្មឱ្យមានការរីកចម្រើនឆាប់រហ័ស និងប្រកបដោយចីរភាព។ ជាពិសេសនៅក្នុងបរិការណ៍មួយដែលប្រទេសជាតិយើងកំពុងខិតខំប្រឹងប្រែងស្តារសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញក្រោយពីវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ-១៩ និងគ្រោះទឹកជំនន់កន្លងមកនេះ។



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*

**អង្គពិធីនាំងម្ចូលជាទីមេត្រី!**

បច្ចុប្បន្ននេះ ការរាតត្បាតនៃជំងឺកូវីដ-១៩ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សមិទ្ធផលសង្គម-សេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាននាពេលកន្លងមកដោយលំបាកប៉ុណ្ណោះទេ តែថែមទាំងអាចបន្ថុចបង្អាក់ដល់កិច្ចដំណើរការអភិវឌ្ឍឈានឡើងរបស់កម្ពុជា ពិសេសអាចនឹងពន្យារពេល នៃការឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជា ក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ផងដែរ។ ប្រាកដណាស់ថាវិបត្តិជំងឺកូវីដ-១៩នេះ នឹងបញ្ចប់នៅពេលណាពិតប្រាកដនោះឡើយ ហើយក៏គ្មាននរណាអាចទស្សន៍ទាយ និងវាយតម្លៃអំពីផលប៉ះពាល់មកលើគ្រប់ទិដ្ឋភាពនៃជីវភាពរស់នៅរបស់សង្គមជាតិនីមួយៗបានជាក់ច្បាស់នោះដែរ។ ជាបច្ច័យ ស្ថានភាពនៃកំណើនសេដ្ឋកិច្ចពិភពលោកនៅក្នុងឆ្នាំ២០២០នេះ ត្រូវបានព្យាករណ៍ថា មានភាពថមថយដល់កម្រិតទាបបំផុតគិតចាប់តាំងពីសង្គ្រាមលោកលើកទី២មក។

គួរកត់សម្គាល់ថា តាមទិន្នន័យនៃការជំរឿននាពេលថ្មីៗនេះ បានបង្ហាញថា ប្រជាជនប្រមាណជា ៥៤,៧% នៃប្រជាជនកម្ពុជាធ្វើការក្នុងវិស័យទី១ (កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) បន្ទាប់មក គឺវិស័យការងារទី៣(សេវាកម្ម) មានអត្រា ២៦,៥% ហើយចុងក្រោយគឺវិស័យការងារទី២ (ឧស្សាហកម្ម)មានអត្រា១៨,៨%។ វិស័យការងារទាំង៣នេះសម្រាប់ឆ្នាំ២០០៨ មានក្នុងអត្រា ៧២,៣% ១៩,២% និង៨,៥%។ យើងសង្កេតឃើញថា ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មនៅឆ្នាំ១៩៩៨ ស្មើនឹង ៧៧,៥% បានធ្លាក់ចុះមកនៅត្រឹម ៧២,៣% នៅឆ្នាំ២០០៨ និងធ្លាក់ចុះ ៥៤,៧% នៅជំរឿនឆ្នាំ២០១៩។ ទិន្នន័យនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ឆ្ពោះទៅរកវិស័យឧស្សាហកម្មជាបន្តបន្ទាប់នា រយៈពេលចុងក្រោយនេះ ពិសេសស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។

ដូចខ្ញុំបានរំឭកជាហូរហែរួចមកហើយថា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ គឺមានគោលដៅពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារការធានាសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ ដោយបានកំណត់ច្បាស់នូវចក្ខុវិស័យក្នុងក្របខណ្ឌកំណែទម្រង់ស៊ីជម្រៅ ដើម្បីប្រែក្លាយកសិកម្មកម្ពុជាឱ្យមានលក្ខណៈទំនើប ប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា តាមរយៈការបង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយធានាបាននូវការអភិវឌ្ឍ និងអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព។

លើសពីនេះទៀត អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងបាននឹងកំពុងជំរុញបន្ថែមដល់សហគមន៍ កសិករ ផលិតករ



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*



*ឯកឧត្តម ង៉ិន ឆាយ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយដ្ឋានកសិកម្ម អញ្ជើញអានរបាយ៍ការណ៍បូកសរុបក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*

ខ្នាតតូច និងមធ្យម សហការធ្វើការដាំដុះ ចិញ្ចឹមសត្វ និងត្រីជាមួយវិស័យឯកជន តាមរយៈការធ្វើកសិកម្មតាមកិច្ចសន្យាដើម្បីធានាបាននូវបរិមាណផ្គត់ផ្គង់ទីផ្សារ និងស្ថិរភាពតម្លៃ ព្រមជាមួយការលើកទឹកចិត្ត ជំរុញគាំទ្រវិស័យឯកជន សហគ្រាសខ្នាតតូច មធ្យម និងដៃគូអភិវឌ្ឍន៍នានា វិនិយោគលើវិស័យកែច្នៃ ដើម្បីធានានូវនិរន្តរភាពនៃការផលិតក្នុងស្រុក ស្ថិរភាពទីផ្សារ បង្កើនតម្លៃបន្ថែម លើកកម្ពស់គុណភាពស្តង់ដារអនាម័យ និងសុវត្ថិភាពឆ្លើយតបតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យ របស់ទីផ្សារទាំងក្នុងតំបន់ និងអន្តរជាតិ។

ទោះជាយ៉ាងណា វិស័យកសិកម្ម ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងក្នុងអត្រា១,៦% ក្នុងឆ្នាំ២០២១ ពីកំណើន ០.៩% ក្នុងឆ្នាំ២០២០ ដោយសារការកើនឡើងនៃអនុវិស័យដំណាំ អនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យនេសាទ។ ដោយឡែក អនុវិស័យដំណាំត្រូវបានព្យាករណ៍ថានឹងសម្រេចបានកំណើនខ្ពស់ជាងឆ្នាំ២០២០ ដោយសារការរំពឹងទុកនូវកំណើនផលិតកម្មកសិកម្ម ស្របពេលដែលថ្លៃ និងតម្រូវការខាងក្រៅមានការកើនឡើង។ ជាមួយគ្នាផងដែរ អនុវិស័យចិញ្ចឹមសត្វត្រូវបានព្យាករណ៍ថា នឹងបន្តកំណើនវិជ្ជមានគាំទ្រដោយការរំពឹងទុកនូវកំណើនការចិញ្ចឹមសត្វបែបពាណិជ្ជកម្ម ពិសេសការចិញ្ចឹមជ្រូកដែលជំរុញដោយភាពល្អប្រសើរនៃថ្លៃសាច់ជ្រូក។ ទន្ទឹមនេះ អនុវិស័យនេសាទ ត្រូវបានព្យាករណ៍ថា នឹងមានកំណើនខ្ពស់ជាងឆ្នាំ២០២០បន្តិច ដែលត្រូវបានជំរុញដោយកំណើនល្អនៃអនុវិស័យវារីវប្បកម្ម។ ទោះជាយ៉ាងណា យើងក៏ទទួលស្គាល់ថា ក្នុងបរិបទនៃការជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរពីវិបត្តិជាសកលបណ្ដាលមកពីហានិភ័យនៃជំងឺកូវីដ-១៩ ក៏ដូចជាការប្រែប្រួលអាកាសធាតុ គ្រោះរាំងស្ងួត ទឹកជំនន់ជាដើមនោះ បានធ្វើឱ្យវិស័យកសិកម្ម យើងជួបប្រទះបញ្ហាប្រឈមមួយចំនួនមានជាអាទិ៍៖ (១)- ផលិតភាពក្នុងការដាំដុះនៅមានកម្រិតទាបនៅឡើយ ហើយកសិករមួយចំនួនធំធ្វើស្រែមួយដងក្នុងមួយឆ្នាំដោយពុំទាន់ប្រើប្រាស់បច្ចេកទេសទំនើប គ្រាប់ពូជមិនទាន់សុទ្ធល្អ និងធ្វើការដាំដុះពឹងផ្អែកលើរបបទឹកភ្លៀង ដោយសារខ្វះប្រព័ន្ធស្រោចស្រព ដែលមានហានិភ័យខ្ពស់ចំពោះការទទួលបានផលិតផលតាមការរំពឹងទុក។ (២)-ធាតុចូលកសិកម្ម ដូចជាជីគីមី និងថ្នាំកសិកម្មត្រូវបាននាំចូលពីបរទេសដែលមានតម្លៃថ្លៃ ហើយថ្លៃប្រេងនិងអគ្គិសនីខ្ពស់ដែលធ្វើឱ្យថ្លៃផលិតកម្មខ្ពស់។ បញ្ហាតម្លៃដឹកជញ្ជូន និងប្រព័ន្ធសេវាភស្តុភារ មិនទាន់គ្រប់គ្រាន់ធ្វើឱ្យមានតម្លៃខ្ពស់ មិនអាចប្រកួតប្រជែងជាមួយផលិតផលកសិកម្មពីបរទេស។ (៣)- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការផ្សព្វផ្សាយបច្ចេកទេស និងការផ្តល់សេវាព័ត៌មានទីផ្សារកសិផលទៅដល់កសិករនៅមិនទាន់បានទូលំទូលាយនៅឡើយ។ ផលិតកម្មដំណាំកសិកម្មបានទទួលផលប៉ះពាល់ជាអវិជ្ជមានដោយគ្រោះរាំងស្ងួត ទឹកជំនន់ ដង្កូវហ្វូង និងជំងឺម៉ូសាអ៊ិកលើដំណាំដំឡូងមី។ (៤)- ការសិក្សាស្រាវជ្រាវលើបច្ចេកទេសដាំដុះ ការបន្សុទ្ធពូជ ការគ្រប់គ្រងទឹក និងជីជាតិដី និងវិធានការកម្ចាត់សមាសភាពចង្រៃនៅមានកម្រិត ហើយស្ថានីយពិសោធន៍ស្រាវជ្រាវកសិកម្មនៅពុំទាន់បំពេញតួនាទីបានល្អប្រសើរ ដោយខ្វះមន្ត្រីបច្ចេកទេស



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម

និងហេដ្ឋារចនាសម្ព័ន្ធបម្រើការងារពិសោធន៍ស្រាវជ្រាវ។ (៥)-សមត្ថភាពបច្ចេកទេស បទដ្ឋានគតិយុត្តនិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការងារអនាម័យ និងភូតគាមអនាម័យ មិនទាន់កសាងបានគ្រប់គ្រាន់ដើម្បីធានាគុណភាព និងសុវត្ថិភាពកសិផលសម្រាប់ប្រើប្រាស់ក្នុងស្រុក និងការនាំចេញ។ (៦)- សមត្ថភាពរបស់សហគមន៍កសិកម្ម ដែលបានបង្កើតក្នុងគោលបំណងបង្កើនអំណាចតថ្លៃ ការទទួលបានសេវាបច្ចេកទេស និងឥណទានត្រូវបានវាយតម្លៃថានៅមានកម្រិត។ កសិករតែងជួបប្រទះនូវការធ្លាក់ចុះនៃតម្លៃកសិផលនៅពេលប្រមូលផលដោយសារផលិតផលមិនទាន់ស្របតាមតម្រូវការស្តង់ដារទីផ្សារទាំងស្រុង ការអនុវត្តផលិតកម្មតាមកិច្ចសន្យានៅពុំទាន់បានល្អប្រសើរ និងការស្វែងរកទីផ្សារមិនទាន់បានគ្រប់ជ្រុងជ្រោយ។ (៧)-ការប្រមូលទិន្នន័យនៅមិនទាន់មានភាពសុក្រឹតល្អ ជាពិសេសផលិតកម្មដំណាំរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងទិន្នន័យការនាំចេញកសិផលគ្មានវិញ្ញាបនបត្រភូតគាមអនាម័យនៅតាមបណ្តាខេត្តជាប់ព្រំដែន។

ឆ្លើយតបទៅនឹងមូលបញ្ហាដូចបានរៀបរាប់ខាងលើ អង្គប្រជុំក៏បានកំណត់នូវទិសដៅ និងវិធានការថ្មីៗទៀតសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២១ ដើម្បីធានាដល់ការគ្រប់គ្រង និងអភិវឌ្ឍវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់ដូចដែលបានរៀបរាប់លម្អិតនៅក្នុងរបាយការណ៍របស់ឯកឧត្តម ងិន ឆាយ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នៅមុននេះបន្តិច។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់លើលទ្ធផលបូកសរុបការងារឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម ដែលសម្រេចបានសមិទ្ធផលដ៏ល្អប្រសើរនេះ កើតចេញពីការខិតខំប្រឹងប្រែងយ៉ាងសកម្មអស់ពីកម្លាំងកាយចិត្ត គំនិតប្រាជ្ញាប្រកបដោយភាពច្នៃប្រឌិត និងមានសាមគ្គីភាពផ្ទៃក្នុងបានល្អរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្តក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់តាមអភិក្រម "រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍" ដែលខ្ញុំសូមចូលរួមអបអរសាទរនូវសមិទ្ធផល ដែលសម្រេចបានជាវិជ្ជមាននេះ ពិតមែនតែយើងនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។

អនុលោមតាម ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ពិសេសឆ្លើយតបនឹងបញ្ហាប្រឈមខាងលើនេះ ក្នុងទិសដៅពង្រីកកំណើនអនុវិស័យដំណាំកសិកម្មឱ្យកាន់តែល្អប្រសើរប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលដើម្បីដើរតាមឱ្យទាន់ទៅនឹងការវិវឌ្ឍន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថលក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ ផ្សារភ្ជាប់ទៅនឹងចំណុចគន្លឹះដែលខ្ញុំបានលើកឡើងកាលពីឆ្នាំ២០២០ កន្លងទៅនោះ ខ្ញុំសូមផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដើម្បីជាមូលដ្ឋានអនុវត្តបន្តដូចតទៅ៖

ទី១. ត្រូវរៀបចំ និងពង្រឹងអនុវត្តក្របខ័ណ្ឌយុទ្ធសាស្រ្ត គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិ ដែលបម្រើឱ្យការងារគ្រប់គ្រងផលិតកម្មដំណាំ ការត្រួតពិនិត្យគុណភាព ជាពិសេសជំរុញការបញ្ចប់ការរៀបចំច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ និងយុទ្ធសាស្រ្តអភិវឌ្ឍន៍លើដំណាំសំខាន់ៗ រួមមាន បន្លែ ចេក ស្វាយ ស្វាយចន្ទី ពោត កសិកម្មសរីរាង្គ ។ល។ ទន្ទឹមនឹងនេះ ក៏មិនត្រូវមើលរំលងអំពីការពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង ដឹកនាំ និងអាជីវកម្មរបស់សហគមន៍កសិកម្មឱ្យមានលក្ខណៈអាជីពក្នុងធុរកិច្ចកសិកម្ម និងសហការជាមួយវិស័យឯកជន ដើម្បីអភិវឌ្ឍខ្សែច្រវាក់តម្លៃលើមុខដំណាំសំខាន់ៗ តាមរយៈការគាំទ្រហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដូចជាផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព ឃ្លាំង និងទីផ្សារ។ល។ សម្របសម្រួលជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានា ក្នុងការទទួល



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម

បានទុនជាមួយនឹងការប្រាក់សមរម្យ។ ជាមួយនេះ ក៏ត្រូវគិតគូរអំពីការចងក្រងសហគមន៍ដែលមានសក្ដានុពលឱ្យក្លាយទៅជាសហគមន៍ទេសចរណ៍ប្រកបដោយភាពទាក់ទាញផងដែរ ព្រមទាំងត្រូវជំរុញឱ្យមានការបង្កើតច្រើនឡើងថែមទៀតនូវ "សហគ្រិនភាពកសិកម្មថ្មីៗ -Agri-Entrepreneurship Incu-bators" ដើម្បីការរីកលូតលាស់កសិកម្មប្រកបដោយប្រសិទ្ធភាព និងបរិយាប័ន្ន។

ទី២. ត្រូវជំរុញការសិក្សាស្រាវជ្រាវបច្ចេកទេសផលិតកម្មដំណាំបន្សុទ្ធ និងពង្រីកពូជដំណាំដែលមានគុណភាពល្អធន់នឹងការប្រែប្រួលអាកាសធាតុ និងតម្លៃបន្ថែមខ្ពស់ នៅតាមស្ថានីយពិសោធន៍ស្រាវជ្រាវតាមសហគមន៍កសិកម្ម និងការលើកទឹកចិត្តឱ្យវិស័យឯកជនចូលរួមវិនិយោគក្នុងការផលិតពូជដំណាំ ដែលមានគុណភាពខ្ពស់ស្របតាមស្តង់ដារ និងតម្រូវការទីផ្សារដើម្បីធ្វើឱ្យមានបរិមាណគ្រប់គ្រាន់ និងតម្លៃសមរម្យសម្រាប់ប្រើប្រាស់ក្នុងផលិតកម្ម។ ទន្ទឹមនឹងនេះ ត្រូវជំរុញការផលិតបន្លែ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មឱ្យមានគុណភាពល្អ និងសុវត្ថិភាពដែលអាចជំនួសការនាំចូល និងបម្រើការនាំចេញ ដោយប្រើប្រាស់ស្តង់ដារការអនុវត្តកសិកម្មល្អប្រកបដោយភាពវៃឆ្លាត តាមរយៈការអនុវត្តផលិតកម្មតាមកិច្ចសន្យា ការពង្រីកទីផ្សារប្រមូលផ្ដុំ បោះដុំ និងចែកចាយឱ្យបានទូលំទូលាយ។

ទី៣. ត្រូវគិតគូរអំពីការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ជាតិកសិកម្មក្នុងការវិភាគ និងវាយតម្លៃគុណភាពធាតុចូលកសិកម្ម (ពូជ ជី ថ្នាំកសិកម្ម) គុណភាពដីទឹក និងកម្រិតសំណល់ថ្នាំកសិកម្មក្នុងផលិតផលកសិកម្ម ដោយត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគ្រប់ដៃគូអភិវឌ្ឍន៍ ដើម្បីឱ្យមានការទទួលស្គាល់ជាលក្ខណៈស្តង់ដារ ISO។ ទន្ទឹមនឹងនេះ ក៏ត្រូវលើកកម្ពស់ការគ្រប់គ្រងធនធានដីកសិកម្ម ដោយជំរុញការសិក្សាវាយតម្លៃគុណភាពដី ការធ្វើផែនទីតំបន់ដាំដុះទៅតាមប្រភេទដី និងមុខដំណាំ ការអនុវត្តវិធានការចម្រុះគ្រប់គ្រងជីជាតិដី និងការរៀបចំយុទ្ធសាស្ត្រផ្លាស់ប្ដូរមុខដំណាំ ព្រមទាំងត្រូវពង្រឹង និងពង្រីកផ្នែកវិស្វកម្មកសិកម្ម និងយន្តូបនីយកម្មកសិកម្មតាមរយៈការស្រាវជ្រាវ អភិវឌ្ឍបច្ចេកវិទ្យា និងឧបករណ៍សម្ភារ បច្ចេកវិទ្យាក្រោយពេលប្រមូលផលប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹកសម្រាប់កសិកម្មប្រកបដោយប្រសិទ្ធភាព។

ទី៤. ត្រូវពង្រឹងវិធានការការពារដំណាំ អនាម័យ និងភូតគាមអនាម័យ តាមរយៈការតាមដានវាយតម្លៃ ព្យា-ករណ៍ និងការអន្តរាគមន៍កម្ចាត់សមាសភាពចង្រៃលើដំណាំ ការត្រួតពិនិត្យ និងចុះបញ្ជីកសិដ្ឋានការអនុវត្តកសិកម្មល្អ ពង្រឹងយន្តការទប់ស្កាត់ការឆ្លងរាលដាលនូវសមាសភាពចង្រៃ និងរឹតបន្តឹងការនាំចូលកសិផលគ្មានគុណភាព និងគ្មានសុវត្ថិភាព ដែលនាំឱ្យប៉ះពាល់ដល់ផលិតកម្មដំណាំក្នុងស្រុក និងសុខភាពប្រជាពលរដ្ឋ។ អគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលទិន្នន័យស្ថិតិដំណាំកសិកម្មឱ្យគ្រប់ជ្រុងជ្រោយ ជាពិសេសនៅតាមបណ្ដាក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងការនាំចេញ នាំចូលកសិផលនៅតាមបណ្ដាខេត្តជាប់ព្រំដែន ដោយប្រើប្រាស់ទម្រង់ប្រមូលទិន្នន័យថ្មីប្រកបដោយការទទួលខុសត្រូវខ្ពស់។

ទី៥. ជំរុញសេវាត្រួតពិនិត្យភូតគាមអនាម័យឱ្យកាន់តែកៀកនឹងអ្នកប្រើប្រាស់ និងកាន់តែមានភាពងាយ

ស្រួល (ដោយដាក់ឱ្យដំណើរការស្នាក់ការផ្ដល់សេវាភូតគាមអនាម័យប្រចាំតំបន់ ដំណើរការការដាក់ពាក្យស្នើសុំការត្រួតពិនិត្យតាមប្រព័ន្ធកុំព្យូទ័រ អភិវឌ្ឍប្រព័ន្ធ e-Phyto) និងជំរុញការចរចាជាមួយបណ្ដាប្រទេសនាំចូល ដើម្បីរៀបចំពិធីសារ ស្ដីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យ សម្រាប់ការនាំចេញផលិតផលកសិកម្មកម្ពុជាទៅទីផ្សារអន្តរជាតិ ដោយផ្ដោតលើមុខដំណាំដែលមានសក្ដានុពលជាអាទិភាព។ ជំរុញការចុះបញ្ជីនិងអាជីវកម្មប្រភេទពូជដំណាំ និងចងក្រងបញ្ជីប្រភេទពូជដំណាំជាតិ ដើម្បីគ្រប់គ្រងសកម្មភាពអាជីវកម្មពូជដំណាំ ព្រមទាំងពង្រឹងយន្តការត្រួតពិនិត្យគុណភាពពូជដំណាំនៅទីវាល និងលើទីផ្សារ សំដៅលើកកម្ពស់គុណភាព និងកាត់បន្ថយការក្លែងបន្លំពូជដំណាំ។

ទី៦. អង្គភាពជំនាញពាក់ព័ន្ធទាំងអស់ត្រូវពិចារណាគិតគូរឱ្យបានស៊ីជម្រៅទៅលើ៖ ១. វិធានការរយៈពេលខ្លី និងបន្ទាន់ ដោយត្រូវវិភាគឱ្យបានគ្រប់ជ្រុងជ្រោយអំពីភាពងាយទទួលរងគ្រោះ។ ២. វិធានការរយៈពេលមធ្យម និងវែង ដោយត្រូវប្រមូលព័ត៌មាន និងទិន្នន័យឱ្យបានច្បាស់លាស់ ពិភាក្សាលើបញ្ហាគន្លឹះ កំណត់តំបន់អាទិភាព និងមានវិធានការដោះស្រាយរាល់បញ្ហាប្រឈមចំពោះមុខ។ ត្រូវគិតគូរជាយុទ្ធសាស្ត្រក្នុងការស្តារ និងជំរុញការងើបឡើងវិញនូវកំណើនវិស័យកសិកម្ម ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិបន្ទាប់ពីវិបត្តិកូវីដ-១៩ ត្រូវបានបញ្ចប់។ ៣. ចាត់វិធានការតាមដាន-ត្រួតពិនិត្យ-វាយតម្លៃ ដែលអង្គភាពជំនាញនីមួយៗ ត្រូវទទួលខុសត្រូវតាមភារកិច្ច។

## អង្គពិធីទាំងមូលជាទីមេត្រី

ជាថ្មីម្ដងទៀត ខ្ញុំសូមសម្ដែងនូវមូលវិចារណ៍ប្រកបដោយមោទនភាព ចំពោះអគ្គនាយកដ្ឋានកសិកម្មដែលសម្រេចបាននូវសមិទ្ធផលជាវិជ្ជមាននេះ។ ខ្ញុំមានទំនុកចិត្តទាំងស្រុង និងជឿជាក់ថា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃអគ្គនា-យកដ្ឋានកសិកម្មក៏ដូចជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំងអស់នឹងខិតខំចូលរួមបំពេញភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ មានមនសិការវិជ្ជាជីវៈ សាមគ្គីភាពឯកភាពផ្ទៃក្នុងប្រកបដោយភាតរភាព យោគយល់គ្នាទៅវិញទៅមកល្អ តាមគោលការណ៍ "សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ"។ ទន្ទឹមនឹងនេះ ត្រូវគិតគូរផ្ដល់ការលើកទឹកចិត្តដល់មន្ត្រីដោយផ្អែកលើលទ្ធផលការងារប្រកបដោយសមធម៌ ព្រមទាំងខិតខំប្រឹងប្រែងដោះស្រាយនូវបញ្ហាប្រឈម និងសំណូមពរដែលអង្គប្រជុំបានលើកឡើងជាមួយអន្តរស្ថាប័នពាក់ព័ន្ធឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ចូលរួមអនុវត្តឱ្យបានសកម្មថែមទៀត តាមទិសដៅគន្លឹះទាំងឡាយដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំបូកសរុបនេះ ដើម្បីធ្វើការកែលម្អ និងអនុវត្តការងារឱ្យបានកាន់តែល្អប្រសើរ សំដៅសម្រេចឱ្យបាននូវសមិទ្ធផលថ្មីៗថែមទៀត សមស្របតាមចក្ខុវិស័យដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដើម្បីអភិវឌ្ឍវិស័យកសិកម្មឆ្ពោះទៅកាន់ការរីកចម្រើនប្រកបដោយសក្ដានុពល។

ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្ដាប្រទេសជាមិត្ត វិស័យឯកជន ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ អង្គការជាតិ-អន្តរជាតិ ពាក់ព័ន្ធទាំងអស់ដែលបានចូលរួមវិភាគទាន និងឧបត្ថម្ភគាំទ្រដល់ ការរួមចំណែកអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជាក្នុងរយៈពេលកន្លងមកដែលខ្ញុំសង្ឃឹមថា ការរួមវិភាគទាន និងការជួយឧបត្ថម្ភគាំទ្រនេះនឹងមានបន្តទៅទៀតទាំងក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត ពិសេសដើម្បីបន្តជំរុញចលនាការកែទម្រង់ស៊ីជម្រៅប្រកបដោយចីរភាពដែលជារបៀបវារៈឆ្នាំ២០៣០ នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ជាទីបញ្ចប់ជាមួយនឹងការប្រកាសបិទ កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ ក៏ដូចជាការអបអរសាទរសមិទ្ធផលដែលអគ្គនាយកដ្ឋានកសិកម្មសម្រេចបានកន្លងមកនេះ ខ្ញុំសូមជូនពរបវរប្រសើរចំពោះគណៈអធិបតី ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ នៃអង្គពិធីទាំងមូល សូមទទួលនូវពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ !**

# ជំនួយស្មារតី
# ឯកឧត្តម វេង សាខុន
# រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ជំឡូងមី ផ្លែស្វាយ និងមាន់សាច់ ក្នុងកម្មវិធី ASPIRE

ថ្ងៃចន្ទ ៤កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាព ក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ជំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE*

## I- សេចក្តីផ្តើម

១. បដិសណ្ឋារកិច្ចចំពោះ៖ គណៈអធិបតី ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងបងប្អូនកសិករតំណាងបណ្តុំអាជីវកម្មទាំងអស់ជាទីមេត្រី។

២. ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយជាអនេក ដោយបានចូលរួមក្នុងពិធី ចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ជំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE នាពេលនេះ។ ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា បងប្អូនកសិករតំណាងបណ្តុំអាជីវកម្ម និងភ្ញៀវកិត្តិយសទាំងអស់ដែលបានចំណាយពេល វេលាដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធីដ៏មានសារៈសំខាន់នេះ។

៣. និយាយជារួម ការរៀបចំកម្មវិធីដ៏មានអត្ថន័យនាថ្ងៃនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីការខិតខំប្រឹងប្រែងរួមគ្នាតាមអភិក្រម "រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍" ដែលជាសក្ខីភាពមួយដ៏ល្អសម្រាប់ឈានទៅបន្តអនុវត្ត ក៏ដូចជាពង្រីកវិសាលភាពឱ្យបានទូលំទូលាយទៅដល់សហគមន៍ផ្សេងៗទៀតក្នុងក្របខណ្ឌនៃកម្មវិធី ASPIRE ដើម្បីរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ និងបច្ចេកវិទ្យាឌីជីថល។

## II- ស្ថានភាពរួម និងអនុសាសន៍ អង្គពិធីទាំងមូលជាទីមេត្រី

១. ដូចឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញាបានជ្រាបយ៉ាងច្បាស់ហើយថារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត "យុទ្ធសាស្ត្រចតុ-កោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣" ដែលនៅតែចាត់ទុកវិស័យកសិកម្ម ជាវិស័យមួយដ៏សំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយបានកំណត់យ៉ាងច្បាស់ថា



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញថ្លែងក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ជំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE*



ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ដំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE

ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការកែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ពិសេសធនធានព្រៃឈើ និងជលផល គឺជាមុខព្រួញដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច ក៏ដូចជាការបង្កើនចំណូលដល់ប្រជាកសិករដោយអនុលោមតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ គឺត្រូវជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន ១២% នៃបរិមាណនាំចេញសរុប នៅឆ្នាំ២០២៥។ លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជា កំពុងតែធ្វើគ្រប់វិធីក្នុងការជំរុញដំណើរការរបស់សហគ្រាសធុនតូច និងមធ្យមឱ្យកាន់តែរីកចម្រើន និងមានលទ្ធភាពច្រើនជាងមុន ដោយត្រូវពង្រឹងបន្ថែមទៀតនូវបរិយាកាសវិនិយោគនៅកម្ពុជាឱ្យបានល្អប្រសើរមានលក្ខណៈសាមញ្ញមិនបានរើសអើង និងបើកចំហយ៉ាងធំទូលាយ ដើម្បីស្រូបយកកម្លាំងពលកម្ម ផ្តល់ប្រាក់ចំណូល និងប្រើប្រាស់វត្ថុធាតុដើមកសិកម្មឱ្យអស់លទ្ធភាព និងកាត់បន្ថយការនាំចូលក៏ដូចជាការធ្វើចំណាកស្រុករបស់ពលករយើងទៅក្រៅប្រទេសផងដែរ ដើម្បីទទួលបានតម្លៃបន្ថែមក្នុងជីវភាពរស់នៅរបស់ខ្លួនក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងជួបនូវវិបត្តិជំងឺឆ្លងកូវីដ-១៩។

២. ទោះជាយ៉ាងណា ការប្រើប្រាស់ផលិតផលកសិកម្មបាននឹងកំពុងក្លាយជាកម្លាំងចលករមួយយ៉ាងសំខាន់ក្នុងការជួយជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននូវឥរិយាបទផលិតពីការផលិតដើម្បីហូបចុកក្នុងគ្រួសារ មកផលិតដើម្បីទីផ្សារដែលត្រូវធានាឱ្យបាននូវនិរន្តរភាពនៃបរិមាណផ្គត់ផ្គង់ ស្តង់ដារផលិតគុណភាព សុវត្ថិភាព និងស្ថិរភាពតម្លៃ ដែលគ្រប់និន្នាការទាំងអស់នេះ ប្រាកដជានឹងចូលរួមធ្វើឱ្យប្រសើរឡើង ទាំងផ្នែកសេដ្ឋកិច្ច សង្គម បរិស្ថាន ការប្រែប្រួលអាកាសធាតុ បរិយាប័ន្ន និងនវានុវត្តន៍ ក្នុងបរិបទនៃដំណើរឆ្ពោះទៅសម្រេចចក្ខុវិស័យដើម្បីប្រែក្លាយកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

៣. គួររំឭកជូនផងដែរថា កម្ពុជាបានចូលជាសមាជិក IFAD នៅឆ្នាំ១៩៩២ ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាតំណាង ហើយចាប់តាំងពីឆ្នាំ១៩៩៦ រៀងរហូតមកទល់បច្ចុប្បន្ននេះ IFAD បានផ្តល់នូវជំនួយហិរញ្ញប្បទានតាមរយៈការអនុវត្តគម្រោងជាច្រើនក្នុងការរួមចំណែកអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជាដោយផ្តោតជាសំខាន់លើការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនក្រីក្រនៅតំបន់ជនបទជាពិសេសកសិករដែលមានដីតិច តាមរយៈការបង្កើនផលិតភាពកសិកម្ម ការជំរុញការអនុវត្តកសិកម្មចម្រុះដោយប្រើប្រាស់បច្ចេកទេសទំនើប ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុព្រមទាំងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ ការកសាងសមត្ថភាពរបស់មន្ត្រីអនុវត្តគម្រោង ក៏ដូចជាការអភិវឌ្ឍសមត្ថភាពរបស់ប្រជាកសិករ និងសហគមន៍កសិកម្មដែលនៅដាច់ស្រយាលនៅក្នុងប្រទេសកម្ពុជា ដោយឈរលើសុឆន្ទៈ និងឧត្តមគតិនៃការគិតគូរដល់ប្រយោជន៍ជាតិ និងប្រជាជនជាធំ ដើម្បីអភិវឌ្ឍមាតុភូមិកម្ពុជាឱ្យទទួលបានជោគជ័យតាមទិសដៅដែលបានគ្រោងទុកនាពេលអនាគត។

ទន្ទឹមនឹងនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះចំណាប់អារម្មណ៍ដ៏មានអត្ថន័យរបស់ឯកឧត្តម មាស ពិសិដ្ឋ នាយក



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ដំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE



*ពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ជំឡូងមី ផ្លែស្វាយ និងមាន់សាច់ប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម* ***វេង សាខុន*** *រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

កម្មវិធី ASPIRE AIMS & S-RET ព្រមទាំងទស្សនវិស័យរបស់កសិករតំណាងបណ្តុំអាជីវកម្ម និងតំណាងវិស័យឯកជននៅមុននេះបន្តិច ក៏ដូចជាអង្គភាពពាក់ព័ន្ធទាំងអស់ដែលបានខិតខំសហការបំពេញការងារបានល្អប្រសើរ និងសម្រេចបាននូវលទ្ធផលជាផ្លែផ្កាគួរឱ្យកោតសរសើរ ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ក្នុងក្របខណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។

៤. ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមរំឭកជូនថា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ មានគោលដៅពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទ។ ដោយឡែក ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ក៏បានកំណត់ច្បាស់នូវចក្ខុវិស័យកសិកម្មកម្ពុជា ជាកសិកម្មទំនើបដែលមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ និងវិបុលភាព សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា។ ដើម្បីសម្រេចចក្ខុវិស័យនេះ យើងបានកំណត់គោលដៅយុទ្ធសាស្ត្រ ដោយបង្វែរទិសពីការអភិវឌ្ឍតាមបែបវិបុលកម្ម ទៅកាន់ការអភិវឌ្ឍតាមបែបប្រពលវប្បកម្ម និងកសិពាណិជ្ជកម្ម ពោលគឺការពង្រីកសមត្ថភាពដាំដុះលើផ្ទៃដីដែលមានស្រាប់ តាមរយៈការបង្កើនរដូវដាំដុះដោយប្រើប្រាស់បច្ចេកទេសទំនើបប្រើប្រាស់គ្រាប់ពូជដែលមានគុណភាពល្អ និងការបង្កើនតម្លៃបន្ថែមក្នុងការកែច្នៃកសិផល ឆ្លើយតបទៅតាមតម្រូវការទីផ្សារក្នុង និងក្រៅស្រុកទាំងបរិមាណ គុណភាព សុវត្ថិភាព និងស្តង់ដារ ដោយធានាបាននូវការអភិវឌ្ឍ និងអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព។

៥. នៅក្នុងឆ្នាំ២០២០នេះ បរិមាណអង្ករនាំចេញមានចំនួន ៦៩០ ៨២៩តោន មានការកើនឡើងចំនួន ៧០-៧២៣តោន (+១១.៤%) ធៀបនឹងឆ្នាំ២០១៩ ដែលមានត្រឹមតែ ៦២០ ១០៦តោន។ ដោយឡែក ការនាំចេញស្រូវក្រៅផ្លូវការមានចំនួន ២ ០១៤ ៦០៩តោន។ រីឯការនាំចេញកសិផល (ក្រៅពីអង្ករ) ប្រចាំឆ្នាំ២០២០ មានបរិមាណសរុបចំនួន ៤ ១៨២ ៦៣២,១០ តោន ដែលក្នុងនោះរួមមាន៖ ដំឡូងមីក្រៀម ដំឡូងមីស្រស់ ផ្លែឈើស្រស់ គ្រាប់ស្វាយចន្ទី គ្រាប់ពោត ផ្លែស្វាយស្រស់ ម្ទេសស្រស់ ដូងប្រេង ស្រូវ កន្ទក់ និងផលិតផលចំនួន៧០ មុខទៀត មានបរិមាណនាំចេញសរុបចំនួន ២៤៣ ១៤៨,៣៨ តោន ដែលក្នុងនោះក៏មានបន្លែគ្រប់ប្រភេទចំនួន ១០៥,៤៦ តោន និងម្ទេសស្រស់ចំនួន ៧០ ៥៤៦តោន។ រីឯតម្រូវការបន្លែប្រចាំឆ្នាំមានប្រមាណ ១ ០៤៥ ៧២៥ តោន ពោលគឺប្រមាណពី ២ ៥០០ ទៅ ៣ ០០០ តោន/ថ្ងៃ។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានលទ្ធភាពផ្គត់ផ្គង់បន្លែប្រមាណត្រឹមតែ ៧៩៥ ៩៦៤តោន ស្មើនឹង៧៦% ប៉ុណ្ណោះ ដែលតម្រូវឱ្យមានការនាំចូលបន្លែជាមធ្យមប្រមាណពី៥០០ ទៅ ១ ០០០តោន/ថ្ងៃ ដើម្បីបំពេញតម្រូវការក្នុងស្រុក។ ប៉ុន្តែបន្លែដែលនាំចូលទាំងនោះ មិនមានប្រភពច្បាស់លាស់ទេ។ លើសពីនេះទៀត យើងមានគម្រោងដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា គម្រោង ASPIRE, CASDP, LEAP, AVIP កំពុងអនុវត្តគម្រោងផលិតកម្មបន្លែសុវត្ថិភាព ជាមួយកសិករដៃគូក្នុងទូទាំងប្រទេសផងដែរ។ ដូច្នេះយើង



*ឯកឧត្តម* ***វេង សាខុន*** *រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញផ្តល់វិញ្ញាបនបត្រ ជូនដល់តំណាងបណ្តុំកសិករ ក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ជំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE*



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញទស្សនាពិព័រណ៍ផលិតផលកសិកម្មក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ដំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE*

សង្ឃឹមថានៅពេលអនាគតកម្ពុជានឹងមានលទ្ធភាពផលិតបន្លែសុវត្ថិភាព សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងសម្រាប់នាំចេញទៀតផង។

៦. គិតត្រឹមឆ្នាំ២០២០ សហគមន៍កសិកម្ម សរុបមានចំនួន១ ២០០សហគមន៍ មានម្ចាស់ភាគហ៊ុនសរុបចំនួន១៤៤ ១៨២នាក់ ក្នុងនោះ សមាជិកជានារីមានចំនួន៩០ ៥៦២នាក់ និងភាគហ៊ុនជាទឹកប្រាក់សរុបមានចំនួន៤២ ៨៤១លានរៀល ស្មើនឹង១០លានដុល្លារអាមេរិក ដើមទុនសរុបចំនួន៩៣ ៧៦៩លានរៀល ស្មើនឹង ២៣,៤លានដុល្លារអាមេរិក។ ទន្ទឹមនេះ ក្រសួងបានរៀបចំចងក្រងបណ្តុំកសិករបានចំនួន ១ ៩២២ បណ្តុំក្នុងនោះ បណ្តុំអាជីវកម្មបន្លែមានចំនួន៥៧០ ស្រូវចំនួន ១៩៧ ស្វាយចន្ទីចំនួន២៥ មាន់ស្រែចំនួន៦១៦ បណ្តុំត្រីចំនួន ១៧៣ ដំឡូងមីចំនួន៥៩ ស្វាយកែវរមៀតចំនួន១៩ និងបណ្តុំផ្សេងៗទៀតបានចំនួន២៦៣។ លើសពីនេះទៀត ក្រសួងបានបង្កើតសហភាពសហគមន៍កសិកម្មសរុបចំនួន១១ ដែលមានសហគមន៍កសិកម្មជាសមាជិកចំនួន២១៥ និងមានដើមទុនសរុបចំនួន ២ ៩១៥លានរៀល។ ទន្ទឹមនឹងនេះ ក្រសួងបានរៀបចឱ្យបង្កើតអនុគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ២៥ រាជធានី/ខេត្ត និងបានរៀបចំផែនការយុទ្ធសាស្ត្រកសិ-ឧស្សាហកម្មឆ្នាំ២០១៩-២០៣០។ សហគមន៍កសិកម្មចំនួន២៩២ សហគមន៍ ក្រុមកសិករសហគមន៍ និងកសិករផ្សេងទៀតបានចុះកិច្ចសន្យា ជាមួយក្រុមហ៊ុនធំៗចំនួន ៨៣៩ កិច្ចសន្យាផលិតកម្មកសិកម្ម។

៧. ក្នុងឆ្នាំ២០២០ ផលិតកម្មសត្វមានការកើនឡើងគួរឱ្យកត់សម្គាល់។ ជាក់ស្តែងសត្វចិញ្ចឹមសរុបបានកើនពី៤៥,៨៥លានក្បាលក្នុងឆ្នាំ២០១៩ ដល់ ៥៣,៩០លានក្បាលនៅឆ្នាំ២០២០ (កើនចំនួន១៧,៦% ដែលធ្វើឱ្យកម្ពុជាមានសមត្ថភាពផលិតសាច់សម្រាប់បម្រើតម្រូវការក្នុងស្រុកបានប្រមាណ ២៥៦ ពាន់តោន ស្មើនឹង៨៥% នៃតម្រូវការសាច់សរុបប្រមាណ ៣០១ ពាន់តោនក្នុងមួយឆ្នាំ)។ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ គោក្របីកើន១,៤% ជ្រូកកើន១៥,១% និងបក្សីកើន១៩,០%។ រីឯតម្រូវការសាច់សរុបប្រមាណ ៣០១ពាន់តោន ក្នុងនោះសាច់គោ-ក្របី ៨៤ពាន់តោន សាច់ជ្រូក ១៥៥ពាន់តោន និងសាច់បក្សី ៦២ពាន់តោន។ ដោយសារកំណើនផលិតកម្មសត្វក្នុងឆ្នាំ២០២០នេះ កម្ពុជាមានលទ្ធភាពអាចផ្គត់ផ្គង់សាច់ បានប្រមាណ ២៥៦ពាន់តោន ស្មើនឹង៨៥% នៃតម្រូវការសាច់សរុប (ឆ្នាំ២០១៩ លទ្ធភាពផ្គត់ផ្គង់សាច់បាន ៨២%)។ ដោយឡែក ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ បើប្រៀបធៀបនឹងឆ្នាំ២០១៩ ឃើញថា ផលិតកម្មសត្វសរុបកើនឡើង៩,២% ក្នុងនោះគោ ក្របីកើន១,៣% ជ្រូកកើន១០,៣% និងបក្សីកើន១០,០%។ ប្រៀបធៀបនឹងឆ្នាំ២០១៩ កន្លងទៅឃើញថាការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មមានការកើន៣៧% ក្នុងនោះគោ ក្របីកើន៣៣,០% ជ្រូកកើន១៩,៤% និងបក្សីកើន៣៨,៦%។ លើសពីនេះទៀត កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ក្រសួងក៏បានរៀបចំពិធីសម្ពោធសមាគមវារីវប្បករនៅកម្ពុជាផងដែរ។

## III- អនុសាសន៍

### អង្គពិធីទាំងមូលជាទីមេត្រី

ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយ សូមផ្តល់អនុសាសន៍គន្លឹះមួយចំនួនជូនដល់អង្គវេទិកាទាំងមូលដើម្បីទុកជាពុទ្ធិពិចារណា និងអនុវត្តបន្តដូចតទៅ៖

ទី១. ដើម្បីឱ្យការអនុវត្តកិច្ចសន្យាទាំងនេះបានល្អប្រសើរនោះ ភាគីទទួលបន្ទុកផ្គត់ផ្គង់ត្រូវធ្វើការដាំដុះតាមបច្ចេកទេសត្រឹមត្រូវ ប្រកបដោយភាពវៃឆ្លាតតាមវិធាន Cam GAP ដូចជាការដាំដុះបន្លែក្នុងផ្ទះសំណាញ់អាចការពារដំណាំយើងបានពីការបំផ្លាញរបស់សមាសភាពចង្រៃ ការធ្វើកសិកម្មសរីរាង្គ ការប្រើប្រាស់ប្រព័ន្ធស្រោចស្រពដោយតំណក់ទឹក (Drip Irrigation) ការរៀបចំផែនការដាំដុះបានត្រឹមត្រូវ ដោយត្រូវបែងចែងជាវេន



*ឯកឧត្ដម **វេង សាខុន** រដ្ឋមន្ដ្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញទស្សនាពិព័រណ៍ផលិតផលកសិកម្មក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ដំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE*

ដាំដុះតាមមុខដំណាំនីមួយៗនៅតាមចម្ការនៃគ្រួសារបណ្ដុំ ដើម្បីធានាថាបណ្ដុំមានបន្លែគ្រប់មុខ និងទៀងទាត់តាមបរិមាណត្រូវការក្នុងកិច្ចសន្យា។ ម៉្យាងទៀតការប្ដូរមុខដំណាំតាមរបៀបនៃការដាំឆ្លាស់នេះក៏នឹងអាចការពារដំណាំយើងបានប្រសើរថែមទៀតផង។

ទី២. ត្រូវរៀបចំឱ្យមាន QR Code ត្រឹមត្រូវជាបណ្ដើរៗតាមមុខដំណាំ និងអ្នកដាំដុះ ដើម្បីធានាដល់ការធ្វើសវនកម្មលើគុណភាពផលិតផលរបស់អ្នកដាំដុះ។ នេះជាប្រការចាំបាច់សម្រាប់ការស្វែងរកទីផ្សារដែលកំពុងមានភាពប្រកួតប្រជែងខ្ពស់នាពេលបច្ចុប្បន្ន និងក្នុងពេលអនាគត។ ទន្ទឹមនឹងនេះត្រូវចាត់បុគ្គលិក ឬ តំណាងចុះពិនិត្យការដាំដុះរបស់បងប្អូនកសិករជាអ្នកផលិតឱ្យបានជាប្រចាំ ដើម្បីធានាថាផលិតផលដែលក្រុមហ៊ុនទិញ ជាផលិតផលដែលមានគុណភាពស្របតាមស្ដង់ដារ Cam GAP ដោយត្រូវធានាថា ផលិតផលបន្លែមានគុណភាពខ្ពស់ ពុំមានបន្សល់នូវសំណល់សារធាតុគីមីឡើយ។

ទី៣. បច្ចុប្បន្នការកែច្នៃកសិផលគឺ ជាមុខព្រួញយ៉ាងសំខាន់ដែលយើងត្រូវយកចិត្តទុកដាក់ និងធ្វើការវិនិយោគដើម្បីទាញយកផល ខណៈដែលការដាំដុះបន្លែរបស់យើងនៅពឹងផ្អែកលើកត្តាធម្មជាតិនៅឡើយ ហើយការផ្គត់ផ្គង់បន្លែក៏នៅមិនទាន់អាចធានាបានទៀងទាត់ពេញមួយឆ្នាំនៅឡើយដែរ។ ដូច្នេះ ត្រូវបន្តជំរុញការដាំដុះបន្លែដែលមានឧត្តមភាពប្រកួតប្រជែងឱ្យបានគ្រប់រដូវ ដើម្បីជំនួសការនាំចូល និងការរៀបចំបង្កើតទីផ្សារបោះដុំ និងចែកចាយបន្លែ ដែលមានស្ដង់ដារអនាម័យខ្ពស់ ដើម្បីអនុវត្តវិធានបច្ចេកទេសក្រោយពេលប្រមូលផល លាងសម្អាត វេចខ្ចប់ ទុកដាក់បន្លែបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសអនាម័យ និងភូតគាមអនាម័យ កាត់បន្ថយការបាត់បង់ និងធានាគុណភាពផលិតផល។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានកសិកម្ម ត្រូវបន្តជំរុញពាណិជ្ជូបនីយកម្មកសិកម្ម តាមរយៈការបន្តពង្រឹងប្រព័ន្ធអនាម័យ និងភូតគាមអនាម័យ ការសម្រួលពាណិជ្ជកម្ម ការវិនិយោគបន្ថែមលើមន្ទីរពិសោធន៍គុណភាពសម្រាប់ការនាំចេញ ព្រមទាំងជំរុញការផលិត និងប្រើប្រាស់ផលិតផលកសិកម្មក្នុងស្រុកឱ្យអស់លទ្ធភាព និងកាត់បន្ថយការនាំចូលផលិតផលកសិកម្មដោយខុសច្បាប់ឱ្យបានជាអតិបរមា។

ទី៤. ប្រាកដណាស់ថា ការចុះកិច្ចសន្យាផលិតកម្មនាពេលនេះគឺ ជាការអនុវត្តដោយដាច់ខាតតាមអ្វីដែលបានចែងក្នុងកិច្ចសន្យានោះ។ ប៉ុន្ដែជាក់ស្ដែងដំណើរការនៃការអនុវត្ត តែងមានភាពរអាក់រអួលបណ្ដាលពីបញ្ហាប្រឈមនានាជាសត្យានុម័ត ដែលប្រការនេះទាមទារឱ្យមានការយោគយល់គ្នា ពិភាក្សាគ្នា ដើម្បីរួមគ្នាដោះស្រាយតាមគោលការណ៍ "ឈ្នះ-ឈ្នះ" ជៀសវាងភាពប្រទូស្ដរ៉ាយនឹងគ្នា។ ដូច្នេះ ការចុះហត្ថលេខានាពេលនេះ គឺជាសក្ខីភាពមួយបង្ហាញថា ភាគីអ្នកផ្គត់ផ្គង់ និង




*ឯកឧត្ដម **វេង សាខុន** រដ្ឋមន្ដ្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញទស្សនាពិព័រណ៍ផលិតផលកសិកម្មក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ដំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE*



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញថតរូបអនុស្សាវរីយ៍ក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ដំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE*

ភាគីអ្នកទិញត្រូវបានឯកភាពគ្នារួចហើយ ទាំងគុណភាព បរិមាណ និងពេលវេលា។

ទី៥. ស្នើដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិទាំងអស់ បន្តជួយដល់ការអភិវឌ្ឍសហគមន៍កសិកម្មបន្ថែមទៀតតាមរយៈការយកសហគមន៍កសិកម្មធ្វើជាស្ពានក្នុងការតភ្ជាប់រវាងគម្រោងជាមួយកសិករ និងជាមួយដៃគូពាក់ព័ន្ធនានារបស់កសិករ តាមអភិក្រម "រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍" ដោយសារសហគមន៍កសិកម្មគឺជាបណ្តុំនៃការប្រមូលផ្តុំកសិករ និងមានភារកិច្ចក្នុងការផ្ទេរបច្ចេកទេសកសិកម្មទៅដល់កសិករដទៃទៀត ដើម្បីធានាបាននូវនិរន្តរភាពរបស់គម្រោង និងការផ្តល់ផលប្រយោជន៍បានយ៉ាងច្រើន ដល់ប្រជាកសិករខ្នាតតូច និងមធ្យម។ ត្រូវជំរុញឱ្យមានការបង្កើតច្រើនឡើងថែមទៀតនូវ "សហគ្រិនភាពកសិកម្មថ្មីៗ - Agri-Entrepreneurship Incubators" ដើម្បីបង្កើនផលិតភាពកសិកម្មប្រកបដោយប្រសិទ្ធភាព និងបរិយាប័ន្ន ក៏ដូចជាការទាក់ទាញភ្ញៀវទេសចរណ៍ផងដែរ។

## IV- សេចក្តីបញ្ចប់

១. ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិទាំងអស់ និងសូមឆ្លៀតយកឱកាសនេះ ដើម្បីថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងអង្គភាពជំនាញជាសេនាធិការ ដែលបានរួមសហការយ៉ាងជិតស្និទ្ធ ដោយមានការគាំទ្រពីបណ្តាអង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងក្រុមហ៊ុនដៃគូផ្សេងៗទៀត ក្នុងការរៀបចំកម្មវិធីនេះឡើង ដែលបានប្រព្រឹត្តទៅប្រកបដោយជោគជ័យតាមការរំពឹងទុក។ សូមថ្លែងអំណរគុណផងដែរ ដល់គ្រប់អន្តរស្ថាប័នពាក់ព័ន្ធទាំងអស់រួមទាំងដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ និងវិស័យឯកជន ចំពោះការផ្តល់កិច្ចសហការប្រកបដោយបុរេសកម្ម ព្រមទាំងការផ្តល់នូវជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជាឱ្យទទួលបានជោគជ័យ ដើម្បីលើកកម្ពស់ការបង្កើនភាពប្រកួតប្រជែងតាមរយៈការបង្កភាពងាយស្រួល និងការបង្កើតបរិយាកាសអំណោយផលដល់ការធ្វើធុរកិច្ច និងវិនិយោគនៅកម្ពុជាពិសេសក្នុងកាលៈទេសៈនៃការរាតត្បាតពីជំងឺកូវីដ-១៩។

ខ្ញុំសង្ឃឹមថា គ្រប់តួអង្គពាក់ព័ន្ធទាំងអស់នឹងបន្តជួយគាំទ្រយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យាក៏ដូចជាការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជាឱ្យបានសកម្មថែមទៀត ដើម្បីលើកទឹកចិត្តដល់សហគមន៍កសិកម្ម ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ចជនបទ ជាពិសេសបងប្អូនកសិករដែលប្រកបមុខរបរកសិកម្ម ឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។

២. ជាទីបញ្ចប់ ជាមួយនឹងការអបអរសាទរពិធី ចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ដំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE នាពេលនេះ ខ្ញុំសូមប្រសិទ្ធពរជ័យបវរប្រសើរ ជូនឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា សមាជិក សមាជិកា នៃអង្គពិធីទាំងមូល សូមទទួលនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ!***





# ដំណាំមន

ដោយៈ អគ្គនាយកដ្ឋានកសិកម្ម

## ១. សេចក្ដីផ្ដើម

ស្លឹកមនគឺជាអាហារមូលដ្ឋានសម្រាប់ដង្កូវនាងមានឈ្មោះថា Bombyx mori។ ដង្កូវនាងប្រភេទនេះ ចិញ្ចឹមខ្លួនលើការស៊ីចំណីស្លឹកមនតែមួយមុខគត់(មន Morus)។ គោលបំណងនៃការដាំដុះមនឱ្យបានល្អ គឺដើម្បីផលិតឱ្យបានច្រើននូវបរិមាណស្លឹកមនដែលមានគុណភាព និងផ្ទុកនៅសារធាតុចិញ្ចឹមខ្ពស់។ ដើម្បីបង្កើនផលិតផលស្លឹកមនព្រមទាំងការកាត់បន្ថយតម្លៃផលិតកម្ម ត្រូវការពឹងផ្អែកលើការអនុវត្តសកម្មភាពបច្ចេកទេសជាច្រើនដូចជា ការគិតពីសេដ្ឋកិច្ចនៃបរិមាណជីដែលត្រូវប្រើប្រាស់ ការកាត់តែងមែក និងការជ្រើសរើសយកកម្មវិធីស្រោចស្រពសមស្រប។ បន្ថែមលើនេះទៀតត្រូវការសិក្សាពីទិដ្ឋភាពទូទៅនៃការដាំដំណាំ និងសិក្សាពីលទ្ធភាពផលិតស្លឹករបស់ដំណាំមនតាមលក្ខណៈសេដ្ឋកិច្ច។

ដោយមានការទទួលយកនូវបច្ចេកទេសនៃផលិតកម្មដំណាំមនតាមបែបវិទ្យាសាស្ត្រគេអាចប្រមូលផលស្លឹកមនបាន ២០តោនក្នុងផ្ទៃដីដាំមួយហិកតា ហើយអាចទទួលត្រលប់មកវិញដោយផលិតបានសំបុកដង្កូវនាងជាមធ្យម១០០០គីឡូក្រាម និងផលិតបានសរសៃសូត្រចំនួន ១៥០គីឡូក្រាម។ ដោយធ្វើការប្រៀបធៀបតម្លៃជាមួយដំណាំដទៃទៀត វាត្រូវគេប៉ាន់ស្មានថា តម្លៃរបស់សូត្រដែលផលិតបានជាក់ស្ដែងច្រើនជាងតម្លៃរបស់ស្រូវ និងតម្លៃរបស់ដំណាំដទៃទៀត។

## ២. ស្ថានភាពទូទៅនៃដំណាំមន

មនដុះលូតលាស់បានល្អនៅតំបន់មានអាកាសធាតុមិនត្រជាក់ខ្លាំង ប៉ុន្តែវារីកសាយភាយយ៉ាងទូលំទូលាយនៅក្នុងតំបន់ និងលាតសន្ធឹងពីតំបន់ត្រូពិចទៅតំបន់ត្រជាក់បង្គួរ។ តំបន់ដែលបានរីកដុះដាលច្រើនជាងគេគឺ តំបន់អាស៊ីរួមមានកូរ៉េ ចិន និងជប៉ុន ហើយអនុវត្តតាមដោយតំបន់អាស៊ីអាគ្នេយ៍ ភាគកណ្ដាល អាស៊ីខាងកើត និងភាគខាងត្បូងអឺរ៉ុប។

កត្តាធម្មជាតិរបស់ដី និងអាកាសធាតុជាកត្តាចាំបាច់បំផុត ដែលត្រូវអនុវត្តជាមួយដំណាំមន ដើម្បីឱ្យមានភាពបន្ស៊ាំទៅនឹងបរិស្ថាន ដោយហេតុនេះហើយ ទើបមានការដាំដំណាំមននេះដើម្បីអភិវឌ្ឍចេញជាប្រភេទពូជផ្សេងៗក្នុងគោលបំណង រកពូជណាដែលមានការដុះលូតលាស់បានល្អ ទាំងមនដែលដាំក្នុងព្រៃនិងមនបានដាំដុះ ត្រូវបានគេបែងចែកជា២៤ប្រភេទដំបូងគេ។ ពូជដាំដុះថ្មី បានមកពីពូជមូលដ្ឋានបីប្រភេទដែលមានឈ្មោះថា Morus Lhou (Ser.) Koids, Morus alba L. និង Morus bombycis Koids ។

មនមានទំនោរទៅរកការបន្ស៊ាំខ្លួនទៅនឹងលក្ខខណ្ឌបរិស្ថានដោយខ្លួនឯង នៅកន្លែងដែលវាបានដាំដុះ។ពូជមួយដែលគេទទួលស្គាល់ល្អបំផុតសម្រាប់ការដាំដុះនៅតំបន់ពិសេសមួយមិនអាចបញ្ជាក់ថាជាពូជដែលផ្ដល់ផលល្អនៅតំបន់ដទៃទៀតបានទេ។ ដូច្នេះចំណេះដឹងអំពីពូជនីមួយៗវាចាំបាច់សម្រាប់ការជ្រើសរើសយកពូជណាដែលសមស្របនៅតំបន់នោះ។

### ២.១. ដើមកំណើត និងប្រវត្តិដំណាំមន

ប្រទេសចិនជាប្រទេសដំបូងគេ ដែលបានចិញ្ចឹមដង្កូវនាង និងដាំដំណាំមន ហើយបានស្រាវយកសរសៃសូត្រ ពីសំបុកដង្កូវនាងជាង៥០០០ឆ្នាំមកហើយ និងជាប្រទេសផលិតសូត្រធំជាងគេនៅក្នុងពិភពលោកយើងនេះ។ បន្ទាប់ពី១០០០ឆ្នាំកន្លង មកដំណាំមនបានរីករាលដាលទៅអាស៊ីកណ្ដាល និងអឺរ៉ុប។ ពីសតវត្សរ៍ទី៩ ដល់១១ ដំណាំមនបានរីករាលដាលដល់ប្រទេសអេស៊ីប អាហ្វ្រិកខាងជើង អេស្ប៉ាញ Sicily និងភាគខាងត្បូងរុស្ស៊ី។ ពីសតវត្សរ៍ទី១២ដល់១៣ បានរីករាលដាលដល់ប្រទេសអ៊ីតាលី និងសតវត្សរ៍ទី១៥រីករាលដាលដល់ប្រទេសបារាំង ។ ប្រទេសកូរ៉េបានអភិវឌ្ឍន៍វិស័យនេះ ៣០០ឆ្នាំក្រោយប្រទេសកូរ៉េ។ ប្រទេសឥណ្ឌានិងប្រទេសនៅអាស៊ីអាគ្នេយ៍ រួមមានប្រទេសឥណ្ឌូនេស៊ី បានអភិវឌ្ឍន៍វិស័យសូត្រនៅដើមនៃគ្រិស្តសករាជ។ នៅទ្វីបអាមេរិច បានរីកចំរើននៅវិស័យសូត្រនៅឆ្នាំ១៥២២ ក្នុងនោះមានសហរដ្ឋអាមេរិក និងប្រេស៊ីល (FAO Agricultural Services Bulletin73/2)។

### ២.២. ស្ថានភាពដំណាំមននៅលើពិភពលោក

ប្រទេសសំខាន់ៗ នៅលើពិភពលោកដែលមានដាំដំណាំមនៈ

- ទ្វីបអាស៊ីមានៈ ប្រទេសចិន ជប៉ុន ឥណ្ឌា កូរ៉េ អ៊ីរ៉ង់ តួគី វៀតណាម បង់ក្លាដេស ស៊ីរី ឥណ្ឌូនេស៊ី អាហ្គានីស្ថាន លីបង់ ឡាវ ភូមា កម្ពុជា ថៃ ប៉ាគីស្ថាន និង អ៊ីរ៉ាក់
- ទ្វីបអឺរ៉ុបមានៈ ប្រទេសរុស្ស៊ី ប៊ុលហ្គារី រ៉ូមានី អ៊ីតាលី ក្រិក អេស្ប៉ាញ ហុងហ្គារី យូហ្គោស្លាវី ប៉ូឡូញ អាល់បានី ឆេកូស្លូវ៉ាគី បារាំង និង អាឡឺម៉ង់។
- ទ្វីបអាហ្វ្រិកមានៈ ប្រទេសអេស៊ីប កុងហ្គោ ម៉ាដាហ្គាស្កា នីសេរីយ៉ា សាធារណៈរដ្ឋអាហ្វ្រិកកណ្ដាល អាល់ស៊េរី តង់ស៊ានី ម៉ារ៉ុក និង ហ្គាណា
- អាមេរិកឡាទីនមានៈ ប្រទេសប្រេស៊ីល ប៉ារ៉ាហ្គាយ កូឡុំប៊ី អាស៊ង់ទីន អេក្វាទ័រ និងកូស្តារីកា(FAO Agri -cultural Services Bulletin73/2) ។

### ២.៣. ស្ថានភាពដំណាំមននៅប្រទេសកម្ពុជា

ការដាំដំណាំមន និងការត្បាញសូត្រ ត្រូវបានអនុវត្តនៅប្រទេសកម្ពុជា ចាប់តាំងពីសតវត្សទី១៣មក។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ កោសេយ្យវប្បកម្មនៅប្រទេសកម្ពុជាត្រូវបានអភិវឌ្ឍន៍ដោយមានការដាំដុះដំណាំមននៅលើផ្ទៃដីប្រហែល៦០០០ហិកតា។ នៅទសវត្សឆ្នាំ១៩៦០ ប្រទេសកម្ពុជាអាចផលិតសរសៃសូត្របានចំនួន២០តោន/១ឆ្នាំ ខណៈដែលតម្រូវការសម្រាប់ជាតិសរុបប្រចាំឆ្នាំ៨០តោន/១ឆ្នាំ។

នៅកំឡុងពេលរបបខ្មែរក្រហម(ឆ្នាំ១៩៧៥-១៩៧៩) ផលិតផលសរសៃសូត្រ និងសកម្មភាពត្បាញត្រូវបានបាត់បង់ស្ទើរគ្មានសល់។ បន្ទាប់ពីសម័យខ្មែរក្រហមនេះប្រជាជនដែលមានចំណេះដឹងក្នុងការចិញ្ចឹមដង្កូវនាងពីមុន ចាប់ផ្ដើមសកម្មភាពនេះឡើងវិញ ប៉ុន្តែទទួលបានទិន្នផលតិចតួចបំផុត។ ចាប់ពីឆ្នាំ១៩៨០សកម្មភាពត្បាញក្នុងប្រទេសកម្ពុជាបានចាប់ផ្ដើមសារជាថ្មី ដោយផ្ដោតសំខាន់លើការត្បាញសូត្រដែលនាំចូលពីប្រទេសវៀតណាម(គង់ សំអឿន, ២០១០)។

នៅពេលបច្ចុប្បន្ន ផលិតផលសរសៃសូត្រ និងការត្បាញគឺសកម្មភាពចម្បងក្នុងអនុវិស័យនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ផលិតផលសរសៃសូត្រដែលសំខាន់មានតែនៅក្នុងភ្នំស្រុក ក្នុងខេត្តបន្ទាយមានជ័យប៉ុណ្ណោះ(ដាំមននៅលើផ្ទៃដីប្រហែល១០០ហិកតា និងត្រូវបានកំពុងថយចុះនាពេលបច្ចុប្បន្ន) ដែលត្រូវបានចាត់ទុកជា មជ្ឈមណ្ឌលកោសេយ្យវប្បកម្មប្រពៃណី។ ការដាំដុះមនថ្មីៗ ត្រូវបានចាប់ផ្ដើមអនុវត្តនៅខេត្តកំពត និងខេត្តសៀមរាបដោយវិស័យឯកជន។ ផលិតផលសរសៃសូត្រប្រចាំឆ្នាំត្រូវគេប៉ាន់ស្មានថាមានតិចជាជាង៥តោន។ តម្បាញសូត្រមានសកម្មភាពកាន់តែកើនឡើងៗនៅតាមតំបន់ជនបទ ដោយសារការកើនឡើងយ៉ាងគំហ៊ុក ហើយសកម្មភាពត្បាញមាននៅក្នុងខេត្តមួយចំនួនដូចជាខេត្តតាកែវ(ស្រុកសំរោង ស្រុកបាទី និងស្រុកព្រៃកប្បាស) ខេត្តកំពង់ចាម(ព្រែកចង្ក្រាន) ខេត្តព្រៃវែង(ស៊ីធរកណ្ដាល) ខេត្តបន្ទាយមានជ័យ(ភ្នំស្រុក) និងក្នុងខេត្តសៀមរាប។ នៅក្នុងឆ្នាំ២០០១ ត្រូវបានគេប៉ាន់ស្មានថាមានអ្នកត្បាញប្រហែល១០,០០០គ្រួសារក្នុងប្រទេសកម្ពុជា(គង់ សំអឿន,២០១២)។

### ២.៤. សារៈប្រយោជន៍ដំណាំមន

ដំណាំមនមិនមែនជាដំណាំគ្រាន់តែសម្រាប់យកស្លឹកមកចិញ្ចឹមដង្កូវនាងមួយមុខទេតែស្លឹកមន គេអាចយកទៅកែច្នៃជាតែសម្រាប់កាត់បន្ថយជាតិស្ករក្នុងឈាម។ ជាងនេះទៅទៀតផ្លែរបស់វា គេអាចហូបស្រស់ ឬក៏កែច្នៃធ្វើទឹកផ្លែឈើស្រស់ ទឹកផ្លែឈើកំប៉ុងបានជាច្រើនប្រភេទ ជាស្រាក្រហម និងធ្វើជាអាហារសម្រាប់អវកាសយានិកទៀតផង រីឯសំបកនៃដើមមនគេយកទៅកែច្នៃជាក្រណាត់សម្រាប់ធ្វើសំលៀកបំពាក់បានទៀត។



ស្លឹកមនជាចំណីសត្វដង្កូវនាង



សរសៃសូត្របានពីសំបុកដង្កូវនាង



សំពត់ហូល ផា មួង ផលិតពីសរសៃសូត្រ




ស្រាក្រហមផលិតពីផ្លែមន

២.៥. ពូជដំណាំមន

នៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃមានពូជមនចំនួន ២៤ពូជកំពង់មានវត្តមានដាំនៅក្នុងប្រទេសកម្ពុជាទាំងពូជក្នុងស្រុក និងពូជនាំចូលដែលពូជទាំងនោះមានដូចខាងក្រោមៈ

- ពូជក្នុងស្រុកចំនួន៩ពូជមានដូចជា ពូជល្ហុង ពូជកែវ ពូជបាយ ពូជសំពៅ ពូជប្រាសាក់ ពូជ BR4 Salum ពូជ Khun Pay2 ពូជ Canva និងពូជ NM60។
- ពូជនាំចូលេពីប្រទេសកូរ៉េចំនួន១២ពូជដូចជា ពូជ Su-won ពូជ chongil ពូជ Suhon ពូជ Suseong ពូជ Daryung ពូជ Sangil ពូជ Milseong ពូជ Sange ពូជ Geomseol ពូជ Shinil ពូជ Yeongchun និងពូជ Koeryan។
- ពូជនាំចូលពីប្រទេសវៀតណាមមានចំនួន ៣ពូជដូចជា ពូជ Limdong1 ពូជ Limdong2 ពូជ Limdong3។ (គង់សំអឿន,២០១២)។

២.៦.ទិន្នផលស្លឹក

កត្តាដែលចូលរួមចំណែកដល់ការផ្ដល់ទិន្នផលស្លឹកមនគឺចំនួនមែក ទំហំស្លឹក ចំនួននិងកម្រាស់របស់ស្លឹកមន និងប្រវែងរបស់ស្លឹកមន និងប្រវែងរបស់ចន្លោះថ្នាំង ។ កត្តាទាំងនេះគួរត្រូវត្រួតពិនិត្យដើម្បីបង្កើនសមត្ថភាពផលិតស្លឹករបស់ដំណាំមន។ តាមរយៈ ការសិក្សាបង្ហាញថាទិន្នផលស្លឹកមនអាស្រ័យលើចំនួន និងប្រវែងសរុបរបស់មែក និងទម្ងន់ស្លឹករបស់វា។

២.៧. គុណភាពស្លឹក

ជាទូទៅគុណភាពស្លឹកមនមានឥទ្ធិពលលើការលូតលាស់ទាំង៥ដំណាក់កាលរបស់ដង្កូវនាង ជាពិសេសលើគុណភាពសរសៃសូត្រ។ ដើម្បីវាយតម្លៃគុណភាពស្លឹករបស់ពូជមនមួយក្នុងការអនុវត្ត គេកំណត់លទ្ធផលបន្ទាប់ពីស្រាវសូត្រដង្កូវនាង ជាជាងការពិនិត្យសារធាតុគីមីដែលមានក្នុងស្លឹកមន។

២.៨. ភាពស៊ាំនៃជំងឺ និងគ្រោះធម្មជាតិ

មានជំងឺផ្សេងៗគ្នាជាច្រើនកើតលើដើមមនពាសពេញប្រទេសកូរ៉េ។ ជំងឺដែលធ្ងន់ធ្ងរជាងគេមានឈ្មោះថាជំងឺតឿ ឬក្រិន។ ជំងឺនេះបណ្ដាលឱ្យខូចភ្នែកដើមមន (die-back) និងរលួយឫស។ ដើមមនក៏រងការប៉ះពាល់ដោយគ្រោះធម្មជាតិផងដែរ ដូចជាការបំផ្លាញដោយអាកាសធាតុត្រជាក់ រាំងស្ងួត ខ្យល់ខ្លាំង និងកង្វះពន្លឺ ។ ការបង្កាត់មនដែលធន់ទ្រាំ និងគ្រោះធម្មជាតិ និងជំងឺជាចំណុចមួយគួរយកពិចារណាឱ្យបានខ្ពស់។

## ៣. លក្ខខណ្ឌបរិស្ថាននៃដំណាំមន

៣.១. សីតុណ្ហភាព

ដំណាំមនអាចដាំដុះ និងលូតលាស់បាននៅសីតុណ្ហភាពចន្លោះពី១៣-១៨អង្សាសេ តែសីតុណ្ហភាពដែលល្អបំផុតសម្រាប់ការលូតលាស់គឺ២៤-២៨អង្សាសេ (FAO agricultural services bulletin80)។

៣.២. ពន្លឺ

ដំណាំមនត្រូវការពន្លឺពី៩-១៣ម៉ោង/១ថ្ងៃ(FAO agri-cultural services bulletin80)។

៣.៣. សំណើម

ដំណាំមនត្រូវការសំណើមបរិយាកាសពី៦៥-៨០% សម្រាប់ការលូតលាស់ (FAO agricultural services bulletin80)។

ដំណាំមន អាចដាំដុះបាននៅតំបន់ដែលមានកម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំ៦០០-២៥០០ម.ម/១ឆ្នាំ (FAO agricultural services bulletin80)។

### ៣.៤. ដី

ដំណាំមនអាចដុះលូតលាស់បានលើដីភាគច្រើនបំផុត ប៉ុន្តែវាដុះលូតលាស់ល្អលើដីដែលមានជីជាតិ ដីមិនជាំទឹកដែលមានpH ពី៥,៥-៧,០ (Buckingham,2010)។

## ៤. លក្ខណៈរូបសាស្ត្រនៃដំណាំមន

### ៤.១. លក្ខណៈដើម

ដើមមននៅពេលខ្ចីដុះលូតលាស់រាងដូចធ្នឹម ប៉ុន្តែបន្ទាប់មកនឹងដុះលូតលាស់យឺត និងកម្រមានដល់កម្ពស់១០-២០មលណាស់(Wikipedia.org)។



ដើមមន

### ៤.២. លក្ខណៈស្លឹក

ស្លឹកមនជាប្រភេទស្លឹកឆ្លាស់ ស្លឹកពេញមានទងស្លឹកញឹក ហើយជាទូទៅទងស្លឹកនេះមានច្រើននៅពេលដើមត្រួយលាស់ថ្មី ជាងនៅលើដើមមានមែកចាស់ ហើយមានរាងដូចធ្មេញរណានៅតាមគែមស្លឹក(Wikipedia.org)។ ស្លឹកដើរតួដូចជារោងចក្រជាអ្នកផលិតកាបូអ៊ីត្រាតពីកាបូនឌីអុកស៊ីតទឹក និងពន្លឺព្រះអាទិត្យ។ ស្លឹកក៏ជាអ្នកសំយោគសារធាតុផ្សេងៗដែលដើមត្រូវការ។ ការលូតលាស់របស់ពន្លកត្រួយជាមធ្យមប្រចាំថ្ងៃនៅខែស្លឹកឈើលាស់៣ស.ម និងរដូវក្តៅ១ស.ម(FAO agricultural services bulletin80)។



ស្លឹកមន

### ៤.៣. លក្ខណៈផ្កា

ផ្កាមនរាងខ្ចីមានពណ៌បៃតង សំយ៉ុងចុះក្រោមនៅជាចង្កោមមិនច្បាស់លាស់ដែលមាននៅតាមអ័ក្សនៃមែកដែលលូតលាស់ពីរដូវថ្មី និងតាមភ្នែកនៃមែកចាស់។ ពួកវាដំណើរលម្អងតាមរយៈខ្យល់ហើយការដាំដុះ ខ្លះអាចផលិតផ្លែដោយមិនចាំបាច់ឆ្លងកាត់ការដំណើរលម្អង។ ដំណើរលម្អងកាត់គឺមិនចាំបាច់ទេ។ នៅកាលីហ្វញ៉ាការដាក់ផ្លែដោយមិនមានការដំណើរលម្អងទេ(crfg.org)។



ផ្កាឈ្មោល ផ្កាញី

### ៤.៤. លក្ខណៈផ្លែ

ផ្លែមនគឺផ្សំឡើងនៃពហុផ្លែ ដែលមានប្រវែងពី២-៣ស.ម។ ផ្លែពេញវ័យមានពណ៌បៃតង ឬពណ៌លឿងស្លេក។ពូជភាគច្រើនផ្លែប្រែពណ៌ជាផ្កាឈូក និងបន្ទាប់ទៅជាពណ៌ក្រហមពេលចាប់ផ្ដើមទុំ ហើយក៏ទៅជាពណ៌ស្វាយ ឬខ្មៅនិងមានរស់ជាតិផ្អែមពេលវាទុំពេញលេញ។ ពេលយើងយកគ្រាប់មនពីផ្លែពណ៌សទៅដាំ យើងនឹងទទួលបានផ្លែវាពណ៌សដែរនៅពេលទុំផ្លែនេះក៏ផ្អែមដែរ តែមិនផ្អែមខ្លាំងដូចផ្លែមានពណ៌ខ្មៅទេ។ (Wikipedia.org)



ផ្លែមន

### ៤.៥. លក្ខណៈឬស

ឫសដំណាំមនដែលស្រូបយកខ្យល់ សារធាតុចិញ្ចឹម

និងទឹកគឺឫសចំហៀងឬ ឫសដុះផ្ដេកស្របផ្ទៃដី។ ដំណាំមន ជារុក្ខជាតិមានឫសក្រាស់ ហើយរាលដាលទៅចំហៀងស្រប ផ្ទៃខាងលើដីពីដើមមន និងមានជម្រៅត្រឹម២៤អ៊ីនពីផ្ទៃខាង លើនៃដី។ ក្រៅពីមានឫសចំហៀងស្របផ្ទៃដីច្រើនដើមមនក៏ មានឫសដុះតាមចំហៀងតូចៗដែរ ដែលឫសទាំងនេះដុះ ចុះក្រោមដើម្បីរក្សាលំនឹងរបស់ដើម(crfg.org)។



ឫសមន

## ៥. ការបន្តពូជរបស់ដើមមន

វិធីសាស្ត្របន្តពូជរបស់ដំណាំមនអាចប្រព្រឹត្តទៅបាន តាមរយៈគ្រាប់ និងតាមរយៈសរីរាង្គលូតលាស់។ យើងអាច យកគ្រាប់មនមកបណ្ដុះដាំ តែវាត្រូវការរយៈពេលយូរ និងមិន សូវល្អដូចការបន្តពូជតាមរយៈសរីរាង្គលូតលាស់។ ការបន្តពូជ ដោយសរីរាង្គលូតលាស់គឺជាការដាំផ្ទាល់នឹងដីតែម្ដង។ ការធ្វើ បែបនេះធ្វើឱ្យកូនថ្មី ដែលបានដាំមានលក្ខណៈឯកសណ្ឋាន ភាពនៅក្នុងចម្ការ។ វិធីសាស្ត្របន្តពូជដោយសរីរាង្គលូតលាស់ មានដូចជា ការបំប៉ៅការសាកមែក និងការកាត់មែកដាំ។ ការ បំប៉ៅជាវិធីសាស្ត្រពេញនិយមដែលគេអនុវត្តនៅប្រទេសមាន សីតុណ្ហភាពក្ដៅបង្គួរ និងវិធីសាស្ត្រកាត់មែកដាំពេញនិយម នៅតំបន់ស៊ុបត្រូពិច។













## ៦. ការបង្កើតចម្ការដំណាំមន

### ៦.១. វិធីសាស្ត្រដាំ

វិធីសាស្ត្រដាំមនអាស្រ័យលើលក្ខខណ្ឌអាកាសធាតុ និងដីនៅតាមតំបន់នីមួយៗ យើងត្រូវរៀបចំថ្នាលសម្រាប់ដាំ ដំណាំមនឱ្យបានល្អត្រឹមត្រូវ។

#### ក. ការរៀបចំរណ្ដៅ

ពេលវេលាដែលល្អបំផុត សម្រាប់បង្កលក្ខណៈដីឱ្យ បានល្អប្រសើរ គឺនៅពេលរៀបចំដីសម្រាប់ដាំ ។ យើងត្រូវគិត ដល់លក្ខខណ្ឌ សម្រាប់ឱ្យឫសដំណាំមនអភិវឌ្ឍន៍បានល្អ។ ត្រូវជីករណ្ដៅឱ្យធំ ហើយត្រូវដាក់សារធាតុសរីរាង្គនៅបាត រណ្ដៅ យកឫសដែលកើតជំងឺ និងរលួយចេញមុនដាំវាទៅក្នុង រណ្ដៅ។ វិធីនេះនឹងធ្វើឱ្យមនដុះលូតលាស់ល្អ និងមានសុខ ភាពល្អទៀតផង

#### ខ. ការដាំ

ជ្រើសរើសកូនមនដែលមានទំហំប៉ុនៗគ្នាមកដាំ ដើម្បី ធានាថាវាដុះលូតលាស់បានស្មើៗគ្នានៅក្នុងចម្ការ។ ដាក់កូន មនចូលក្នុងរណ្ដៅ និងត្រូវជៀសវាងកុំឱ្យឫសមនប៉ះពាល់ជា មួយជីធម្មជាតិដែលយើងដាក់នៅបាតរណ្ដៅ រួចលប់បំពេញដី ពីលើ។

#### គ. ប្រភេទនៃដំណាំមន

មានការដាំមនពីរប្រភេទគឺប្រភេទដាំតែមួយជួរ និងដាំ ជាពីរជួរ(គូ)។

ប្រភេទដាំមួយជួរៈ មនត្រូវបានដាំចន្លោះជួរ និងចន្លោះ គុម្ពស្មើៗគ្នាទាំងអស់ក្នុងចម្ការ។

ប្រភេទដាំជាពីរជួរៈ ត្រូវបានគេដាំឆ្លាស់គ្នាពីជួរមួយ ឬទៅជួរមួយម្ដងទូលាយ ម្ដងចង្អៀត និងផ្សំឡើងពី២-៣ ឬ ច្រើនជួរ។

វិធីសាស្ត្រនេះគឺជាវិធីសាស្ត្រដែលគេពេញនិយមភាគច្រើន។

### ឃ. ចន្លោះគុម្ព

ចន្លោះគុម្ពសម្រាប់ដាំមនគឺវាអាស្រ័យលើលក្ខខណ្ឌរូបសាស្ត្ររបស់ពូជ និងលក្ខខណ្ឌរបស់ដីនៅតាមតំបន់សម្រាប់ដាំនោះ។

### ង. ការកំណត់ចន្លោះគុម្ពផ្អែកលើវិធីសាស្ត្រកាត់

| | ទម្រង់ | ប្រភេទ | ចន្លោះជួរ(m) | ចន្លោះគុម្ព(m) | កំណត់សម្គាល់ |
|---|---|---|---|---|---|
| តំបន់ក្ដៅបង្គួរ | កាត់ទាប | មួយជួរ | ១.៥-១.៨ | ០.៥-០.៨ | ប្រភេទចាស់ |
| | | ជួរមានដើមគូរ | ចន្លោះធំ ១.៨<br>ចន្លោះតូច០.៦ | ០.៥ | អនុសាសន៍ថ្មីៗ |
| តំបន់ត្រូពិច | កាត់មធ្យម | មួយជួរ | ២-២.៥ | ០.៨-១.២ | |
| | កាត់ទាប | ប្រព័ន្ធរណ្ដៅ<br>ប្រព័ន្ធជួរ | ០.៩-០.៧៥<br>០.៤-០.៦ | ០.៩-០.៧៥<br>០.៥-០.៦ | |













ដើម្បីបានភ្នែកដែលល្អ
គួរកាត់យកបន្ទាប់ពីការ
កាត់តែងមែកត្រឹមគល់




### ៦.២. ការអនុវត្តនៅតំបន់ត្រូពិច

តំបន់ត្រូពិចសើមដែលមានសីតុណ្ហភាពខ្ពស់ មានភ្លៀងធ្លាក់ជាប្រចាំ និងដីមមោកមានជីជាតិគឺជាកន្លែងមានលក្ខខណ្ឌសមស្របសម្រាប់ការលូតលាស់របស់ឫសតាមវិធីសាស្រ្តកាត់ដាំ។ មានពូជក្នុងស្រុកមួយចំនួនដែលអាចលូតលាស់បានយ៉ាងល្អក្នុងលក្ខខណ្ឌបែបនេះ។ ការកាត់ផ្នែកនៃមែកមកដាំអាចផលិតជាកូនមនបាន។

#### ក. វិធីសាស្រ្ត

#### ការកាត់មែកដាំ

កំឡុងពេលរដូវវស្សា គឺជាពេលវេលាល្អបំផុតដើម្បីអនុវត្តការកាត់មែកយកដាំ។ ប្រសិនបើមានទឹកច្រើនសមស្របពេញមួយឆ្នាំ យើងអាចអនុវត្តវិធីនេះពេលណាក៏បាន។

#### ការដាំ

ក្នុងកំឡុងពេលរដូវភ្លៀង ការកាត់មែកអាចដាំដោយផ្ទាល់លើដីចម្ការតែម្តង។ រណ្តៅដែលបានដាក់ជីកំប៉ុស្តរួចនឹងជួយបង្កើនការដុះលូតលាស់របស់កូនមនបានយ៉ាងល្អ។

## ៧. ការពត់រាង (ការតាក់តែងដើមឆ្នាំដំបូង)

ការពត់រាងដើមមនចន្លោះគុម្ពសមស្រម និងវិធីប្រមូលផលសមស្របមានឥទ្ធិពលទៅលើទិន្នផលស្លឹកមន។

### ៧.១. ទម្រង់នៃការកាត់ទាប

វិធីសាស្រ្តនេះ គឺជាទូទៅត្រូវបានគេណែនាំឱ្យប្រើប្រាស់ លើកលែងតែកន្លែងដែលមានភ្លៀង ឬព្រិលច្រើនដែលវានឹងបណ្តាលឱ្យស្លឹកខាងក្រោមខូច។






### ៧.២. ការពត់រាង(ការតាក់តែងដើម)ក្នុងករណីដែលការដាំផ្សេង

ក. នៅចន្លោះ១-៤ខែបន្ទាប់ពីដាំ

- បន្ទាប់ពីការដាំមែកដែលកាត់នោះហើយដើមនីមួយៗ គួរតែទុកឱ្យដុះពន្លកត្រួយតែមួយដែលយើងរំពឹងថាវានឹងក្លាយជាដើមមេ
- នៅពេលវាលូតលាស់បានកម្ពស់១ម នៅអាយុ៤ខែ ឬយូរជាងនេះ វាត្រូវបានកាត់ទុកឱ្យនៅត្រឹមតែប្រវែង ១៥ស.ម ពីដី
- ផ្នែកដែលនៅសល់ក្លាយជាដើមមេដែលមានភ្នែក៣-៤នឹងត្រូវដុះចេញជាពន្លកថ្មីពេលក្រោយ

ខ. ចាប់ពីអាយុ៩ខែបន្ទាប់ពីដាំ

- បន្ទាប់ពីពន្លកថ្មីនោះមានកម្ពស់ប្រវែង១ម គឺនៅអាយុប្រហែល៩ខែបន្ទាប់ពីដាំពន្លកខ្ចី៣ត្រូវបានជ្រើសរើសចេញពីពន្លកដែលដុះលូតលាស់បានល្អនោះ ត្រូវកាត់ទុកកម្ពស់១០ស.មពីដី ចំពេលប្រមូលផលលើកទីមួយ។
- វិធីកាត់ប្រភេទនេះ ពន្លកខ្ចីនៅផ្នែកខាងលើដើមត្រូវបានកាត់បន្តិចម្តងៗខ្ពីឡើងៗ នឹងផ្នែកខាងក្រោមនៃដើមកាន់តែវែងបន្តិចម្តងៗ ដូច្នេះកំពូលត្រួយទាំងបីនោះគឺមានលក្ខណៈស្មើរតែប្រហាក់ប្រហែលលើដី។
- នៅពេលដើមវាផលិតច្រើនជាង៣ត្រួយ ត្រួយបីដែលធំជាងគេត្រូវទុកវា ហើយត្រួយផ្សេងទៀតត្រូវកាត់ចោលឱ្យត្រឹមដើម។
- ក្នុងករណីដើមមិនសូវលូតលាស់ ការអនុវត្តបែបនេះត្រូវពន្យាពេលរយៈពេល២-៣ខែ។

## ៨. ការតាក់តែងមែក

ការតាក់តែងមែកបានត្រឹមត្រូវគឺជាកត្តាសំខាន់ដើម្បីរក្សាផ្នែកខាងលើរបស់ដើមមន សម្រាប់ការបែកមែកដ៏មានប្រសិទ្ធភាព។ មែកល្អនឹងផលិតបានទិន្នផលស្លឹកខ្ពស់ និងដើមដែលបានពត់រាងរួចនឹងធ្វើឱ្យដើមមើលឃើញស្អាត។

### ៨.១. ប្រភេទនៃការតាក់តែង







| រាងដូចកណ្ដាប់ដៃ | | រាងមិនដូចកណ្ដាប់ដៃ |
|---|---|---|
| ធ្វើឱ្យភ្នែកមិនទាន់ដុះចាប់ផ្ដើមដុះនៅក្បែរគល់ ពន្លកតិចតែរឹងមាំងាយស្រួលពត់រាងនិងគ្រប់គ្រងសត្វចង្រៃ | ពន្លកសម្រាប់ដុះជាមែកកន្លែងដែលត្រូវកាត់ ចំនួនរបស់មែកដុះលូតលាស់សម្រាប់ការអនុវត្តការដាំដុះ | ភ្នែកធម្មតា ១០ស.ម ខាងលើគល់មែកច្រើនតែខ្សោយពិបាកនឹងកំណត់រាង |

### ៨.២. គោលការណ៍កែសម្រួលដើមដែលនៅសល់

| ការកាត់វែង( ទុក៣-៥ម ) | ការកាត់ខ្លី( ក្បែរគល់ ) |
|---|---|
| មែកនៃដើមនៅខ្ចី<br>មែកមានទំហំធំ<br>មែកផ្នែកខាងលើ<br>មែកនៃដើមដែលខ្លាំង | មែកនៃដើមចាស់<br>មែកមានទំហំតូចៗ<br>មែកនៅខាងក្រោម<br>មែកនៃដើមខ្សោយ |

### ៨.៣. វិធីសាស្ត្រកាត់មែក

ដើម្បីកែសម្រួលមែកដែលនៅសល់ មែកត្រូវកាត់ឱ្យបានសមស្របដូចខាងក្រោម៖




## ៩. ការប្រើប្រាស់ជី

បរិមាណ និងភាពញឹកញាប់នៃការប្រើប្រាស់ជីអាស្រ័យលើការលូតលាស់របស់ដើមមន ការតាក់តែងមែក វិធីសាស្ត្រប្រមូលផល ទឹកភ្លៀង ប្រភេទដី និងលក្ខខណ្ឌអាកាសធាតុ។

### ៩.១. តំមន់ត្រូពិច

បរិមាណដី និងវិធីសាស្ត្រប្រើប្រាស់ត្រូវបានបង្ហាញដូចខាងក្រោម៖

- នៅដំណាក់កាលទី១: ត្រូវប្រើ៥០-៥០-៥០គីឡូក្រាម/ហិកតា
- នៅដំណាក់កាលទី២: ត្រូវប្រើ៥០-០-០ គីឡូក្រាម/ហិកតា
- នៅកំណាក់កាលទី៣: ត្រូវប្រើ៥០-៥០-៥០ គីឡូក្រាម/ហិកតា
- នៅដំណាក់កាលទី៤: ត្រូវប្រើ៥០-០-០ គីឡូក្រាម/ ហិកតា
- នៅដំណាក់កាលទី៥: ត្រូវប្រើ៥០-០-០ គីឡូក្រាម/ ហិកតា



| គ.ក្រ/ហ.ត | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ | ដំណាក់កាលទី៤ | ដំណាក់កាលទី៥ |
|---|---|---|---|---|---|
| អាសូត | ៥០ | ៥០ | ៥០ | ៥០ | ៥០ |
| ផូស្វ័រ | ៥០ | | ៥០ | | |
| ប៉ូតាស្យូម | ៥០ | | ៥០ | | |

### ៩.២. វិធីសាស្រ្តប្រើប្រាស់

- ការបាចៈ នៅចម្ការមនដែលមានដីរាបស្មើ ជីត្រូវបានគេបាចនៅចន្លោះគុម្ពនៃដើមមន។ ដីនិងជីត្រូវលាយជាមួយគ្នាដោយប្រើចប។ វិធីសាស្រ្តនេះសមស្របសម្រាប់មនពេញវ័យ។



(B)



- សារធាតុសរីរាង្គៈ ជីកំប៉ុស្តដាក់ក្នុងរណ្ដៅ ដាក់នៅចន្លោះជួររបស់មន។ ចំបើង និងជីស្រស់យកពីរុក្ខជាតិតូចៗ ឬស្លឹកឈើ អាចដាក់នៅពីលើរណ្ដៅដីកំប៉ុស្តនោះ។




(A)

- ការបាចជុំវិញៈ សម្រាប់ដីជម្រាល និងមននៅក្មេង។ ត្រូវជីករណ្ដៅរាក់ៗក្បែរគល់មនរួចដាក់ជីក្នុងរណ្ដៅនោះ និងកប់ដីពីលើ។



(A)



(B)

## ១០. ការគ្រប់គ្រងទឹក

កម្ពស់ទឹកភ្លៀងសមស្របប្រចាំថ្ងៃគឺ៤-៥ម.ម នៅរដូវដុះលូតលាស់។ ការស្រោចស្រពត្រូវការអនុវត្តប្រសិនបើកម្ពស់ទឹកភ្លៀងទាបជាងកម្រិតកំណត់។ ការស្រោចស្រពជាមធ្យមពី ២០០-២៥០តោន/ហិកតារៀងរាល់៤-៥ថ្ងៃម្តង។ ការប្រើគម្របដីដោយសារធាតុសរីរាង្គគ្របដីអាចកាត់បន្ថយការតំហួតទឹក និងបង្កើនរន្ធសម្រាប់ផ្ទុកទឹកនៅក្នុងដីបាន។

## ១១. ការគ្រប់គ្រងស្មៅ និងវិធានការការពារ

### ១១.១. វិធានការគីមី

ថ្នាំសម្លាប់ស្មៅត្រូវបានបាញ់ផ្នែកខាងលើនៃផ្ទៃដីដើម្បីការពារកុំឱ្យស្មៅដុះ ឬអាចប្រើដោយផ្ទាល់លើស្មៅកំពុងលូតលាស់ ប៉ុន្តែភាពចាំបាច់បំផុតត្រូវការពារកុំឱ្យថ្នាំប៉ះស្លឹកមន។

### ១១.២. វិធានការក្សេត្រសាស្ត្រ

ចំបើង និងសារធាតុផ្សេងៗ ត្រូវបានដាក់គ្របផ្ទាល់លើដីដើម្បីការពារកុំឱ្យស្មៅដុះ ដោយសារស្មៅពុំអាចស្រូបយកពន្លឺព្រះអាទិត្យនោះបាន។ វិធីនេះជួយបង្កើតមមោកដល់ដី និងសមស្របបំផុតសម្រាប់ដីជម្រាល ។ ប្រសិនបើមានសត្វល្អិតចង្រៃនៅក្នុងគម្របដីនេះយើងអាចប្រើថ្នាំសម្លាប់សត្វល្អិតបាន។

## ១២. ការប្រមូលផល

មានវិធីសាស្ត្រ២យ៉ាងក្នុងការប្រមូលផលស្លឹកមន។ ជម្រើសនីមួយៗ អាស្រ័យលើលក្ខខណ្ឌធម្មជាតិ វិធីសាស្ត្រចិញ្ចឹមដង្កូវនាង និងការចំណាយលើពលកម្មពេលប្រមូលផល ។ ល។ ការជ្រើសរើសត្រួយ និងស្លឹកបន្ទាប់ពីត្រួយក៏ជាកត្តាសំខាន់សម្រាប់ចិញ្ចឹមដង្កូវតូចៗ( ដំណាក់កាលទីមួយ ) រីឯស្លឹកបន្តបន្ទាប់សម្រាប់ដង្កូវ នៅដំណាក់កាលបន្តទៀតរហូតដល់ស្លឹកចាស់សម្រាប់ចិញ្ចឹមដង្កូវពេញវ័យនៅដំណាក់កាលទី៥ មុនវាឡើងសំបុក្រ។

### ១២.១. វិធីសាស្ត្របេះស្លឹក

វិធីសាស្ត្រនេះពិតជាត្រូវការចំណាយកម្លាំងច្រើន។ ការបេះស្លឹកត្រូវបានគេធ្វើឡើងនៅរដូវភ្លៀងធ្លាក់ និងរដូវរាំហើយ និងការបេះមែកត្រួយនៅកំឡុងរដូវស្លឹកឈើលាស់ដែលជារដូវចិញ្ចឹមដង្កូវនាង។ វិធីសាស្ត្រពិសេសដើម្បីបេះស្លឹកមនគឺកាំបិតជាប់ម្រាមដៃសម្រាប់កាត់ស្លឹកនិងមែកស្លឹកទាំងមូល។







### ១២.២. វិធីសាស្ត្រកាត់យកមែក

វិធីសាស្ត្រនេះត្រូវបានគេណែនាំឱ្យអនុវត្ត ព្រោះវាមិនចំណាយកម្លាំងច្រើន។ ការប្រមូលផលអាស្រ័យទៅលើរដូវកាលនៃការចិញ្ចឹមដង្កូវនាង និងវិធីសាស្ត្រលក្ខខណ្ឌសរីរៈរបស់មន ប្រសិទ្ធភាពនៃការប្រើពលកម្ម និងការដុះលូតលាស់ពន្លកត្រួយថ្មី។






## ១២.៣. វិធីសាស្ត្រតាក់តែងមែកសម្រាប់កូនដង្កូវទើបញាស់

ស្លឹកខ្ចីទន់លូតលាស់កំឡុងពេលរដូវភ្លៀង។ ដើម្បីផលិតស្លឹកខ្ចីដែលមានគុណភាពសម្រាប់ដង្កូវនាងទើបញាស់នៅរដូវលំហើយគឺជាការចាំបាច់មួយត្រូវអនុវត្តតាមបច្ចេកទេស។នេះគឺជាការសំខាន់ដើម្បីធានាបាននៅសំបុកដង្កូវនាងដែលមានទិន្នផលល្អ។ វិធីនេះអនុវត្តតែនៅតំបន់ក្ដៅបង្គួរតែប៉ុណ្ណោះ។

វិធីសាស្ត្រកាត់ចុងត្រួយ

- មែកមនត្រូវកាត់យ៉ាងហោចណាស់២ ទៅ ៣ខែមុន ចិញ្ចឹមដង្កូវនាង
- នៅពេលត្រួយខ្ចីលាស់បានប្រហែល១៥ស.ម ត្រូវចាប់ផ្ដើមកាត់
- កាត់ពន្លកត្រួយ១៥ស.ម ខាងលើមែក។ បេះស្លឹកពាក់កណ្ដាលផ្នែកខាងលើ ចំណែកពាក់កណ្ដាលនៃផ្នែកខាងក្រោមទុក។
- ពេលវេលាសមស្របសម្រាប់អនុវត្តវិធីនេះគឺនៅ២០-២៥ថ្ងៃ មុនពេលដង្កូវនាងឡើងសំបុក នៅរដូវភ្លៀងឬ ៣០-



៣៥ថ្ងៃ មុនពេលឡើងសំបុកនៅរដូវប្រាំង។

- បន្ទាប់ពីនោះ២ ឬ៣ថ្ងៃ ពន្លកចំហៀងនឹងដុះចេញជាច្រើនដែលអាចសមស្របសម្រាប់កូនដង្កូវនាងទើបញាស់។
- បន្ទាប់ពីប្រមូលផល មែកដែលត្រូវបានកាត់ដល់គល់ និងត្រូវដាក់ជីដល់មន
- ដំណាំមនប្រហែល៥០ដើមអាចចិញ្ចឹមដង្កូវនាង បានមួយប្រអប់។

## ១៣. ប្រមូលផលនៅតំបន់ត្រូពិច និងការកាត់តែងមែក

នៅភាគច្រើននៃតំបន់ត្រូពិច ស្លឹកមនត្រូវបានប្រមូលផលតាមរយៈការបេះជាបន្តពេញមួយឆ្នាំ។ ការបេះបន្តបែបនេះធ្វើឱ្យស្លឹកមិនមានគុណភាព និងចំណាយពលកម្មច្រើន។ ការប្រមូលផលមែកមិនត្រូវបានគេទទួលយកទូលំទូលាយទេ។

### ១៣.១. ចាប់ពីដាំរហូតដល់ពេលប្រមូលផលលើកដំបូង

ខាងក្រោមនេះ បង្ហាញពីការលូតលាស់ដំបូងរបស់ដំណាំមនរហូតដល់ពេលប្រមូលផលលើកដំបូង។ នៅដំណាក់កាលនេះ មនលូតលាស់ដល់ដំណាក់កំពូល និងប្រព័ន្ធដំណាំចម្រុះត្រូវបានគេអនុវត្ត។

- បន្ទាប់ពីដាំបាន៦ខែ មនដុះលូតលាស់ និងចាប់ផ្ដើមបែកមែក
- នៅអាយុ៩ខែបន្ទាប់ពីដាំ អាចប្រមូលស្លឹកមួយចំនួន សម្រាប់ចិញ្ចឹមដង្កូវនាង កាត់ផ្នែកខាងចុងដើម្បីបង្កើនការលូតលាស់ត្រួយ។
- នៅអាយុ១១ខែបន្ទាប់ពីដាំប្រមូលស្លឹកពីមែកបន្ទាប់
- អាយុ១៥ខែបន្ទាប់ពីដាំប្រមូលផលមែកទីបី
- បន្ទាប់ពីប្រមូលផលត្រូវកាត់តែងមែក និងបន្ទាប់ពីកាត់តែងមែករួច ស្លឹកអាចប្រមូលផលបាននៅរយៈពេល២-៣ខែម្ដង។

### ១៣.២. វិធីសាស្ត្រដំណាំចម្រុះ

ការប្រើវិធីនេះអាស្រ័យលើទំហំសមស្របរបស់ចម្ការដំណាំមន

### ១៣.៣. ការប្រមូលផល

តារាងខាងក្រោមបង្ហាញពីចម្ការនីមួយៗត្រូវបានកាត់អាស្រ័យលើតម្រូវការចិញ្ចឹមដង្កូវនាង។ ចម្ការដែលបានកាត់ត្រូវការរយៈពេល២-៣ខែដើម្បីដុះឡើងវិញ។

| កូនស្រែ | ទី១ | ទី២ | ទី៣ | ទី៤ | ទី៥ | ទី៦ | ទី៧ | ទី៨ | ទី៩ | ទី១០ | ទី១១ | ទី១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| I | | | | | | | | | | | | |
| II | | | | | | | | | | | | |
| III | | | | | | | | | | | | |
| IV | | | | | | | | | | | | |

## ឯកសារយោង៖


១. គង់ សំអឿន, ២០២១ របាយការណ៍វឌ្ឍភាពស្តីពីលទ្ធផលនៃការអនុវត្តគម្រោងគាំទ្រការស្តារឡើងវិញសូត្រនៅកម្ពុជា

២. គង់ សំអឿន, ២០២១ របាយការណ៍សកម្មភាពអនុវត្តការងារគម្រោងគាំទ្រការស្តារឡើងវិញសូត្រនៅកម្ពុជា

៣. Dr. Sung Gyoo Byung,2013. Sericulture & Apicultural Materials Division Department of Agricultural Biology, Nation Academy of Agricultural Science, RDA, Republic of Korea

៤. Alan Backingham, 2010. Grow Frut Gardens, Yards, Bolconies, Roof terraces, page162

៥. FAO Agricultural Services Bulletin 80,1990. Sericulture training manual

៦. FAO Agricultural Services Bulletin 73/2,1992. Silkworm rearing

៧. www.en.wikipedia.org/wiki/Morus(plant), 29 August 2014 at 9:40am

៨. www.crfg.org/pubs/ff/mulberry.html, 9 September 2014 at 4:20pm.












# ចំណេះដឹងស្ដីអំពីសុខភាពសត្វ

រៀបចំដោយៈ
អគ្គនាយកដ្ឋានសុខតាពសត្វ និងផលិតកម្មសត្វ

បន្តពីទស្សនាវដ្ដីកសិកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២១ លេខ៧៧



☛ ការឱ្យគោស៊ី ២០០ក្រាមក្នុងមួយថ្ងៃ ដើម្បីបង្កើតគុណភាពរបបចំណីរបស់គោទម្ងន់ ២០០គីឡូក្រាម និង ៥០០ក្រាម ក្នុងមួយថ្ងៃ អាចជួយដល់គោធ្វើការ និងផលិតទឹកដោះ។ ការផ្ដល់១ទៅ២គីឡូក្រាមក្នុងមួយថ្ងៃរយៈពេល៦អាទិត្យ សម្រាប់បំប៉នមុនលក់។គួរផ្ដល់បរិមាណចំណីពាក់កណ្ដាលពេលព្រឹក និងពាក់កណ្ដាលទៀតពេលយប់។

☛ ការផលិតស្លឹកដំឡូងមីស្ងួត (ប្រូតេអ៊ីន២៥%)

~ ដាំដំឡូងមីលើថ្នាលដែលមានគម្លាត ៤០,៦០ សង់ទីម៉ែត្រពីដើម និងពីជួរនីមួយៗ

~ ដំឡូងមីអាចប្រមូលផលលើកទីមួយ បន្ទាប់ពីដាំបាន៣ទៅ៤ខែ។ ដំឡូងមីអាចប្រមូលផលលើកទី២ នៅចន្លោះពីរខែបន្ទាប់មកទៀត ដើម្បីផលិតជាម្សៅស្លឹកដំឡូងមីស្ងួត បន្ទាប់ពីការលាស់ស្លឹកសារជាថ្មី។គេអាចប្រមូលពី ៤ ទៅ៥ដងសម្រាប់ពេញមួយឆ្នាំ។

~ បន្ទាប់ពីប្រមូលផល ស្លឹកដំឡូងមីត្រូវសម្ងួត( ១ ទៅ២ថ្ងៃ ) ដើម្បីផលិតជាម្សៅ។

~ ដំឡូងមីមានជាតិពុលដែលហៅថា អាស៊ីតស្យានិត( HCN )។ការសម្ងួតអាចកាត់បន្ថយកម្រិតជាតិពុលលើសពី៩០% ហើយពេលនេះស្លឹកអាចឱ្យសត្វស៊ីបាន។

~ ការសម្ងួតដោយព្រះអាទិត្យត្រូវសម្ងួតរហូតដល់ស្ងួតក្រៀម។ស្លឹកដំឡូងមីអាចរក្សាទុកបានច្រើនអាទិត្យ។



ស្លឹកដំឡូងមី



ការប្រមូលផលស្លឹកដំឡូងមី



ស្លឹកដំឡូងមីក្រោយចិញ្ច្រាំ និងហាលថ្ងៃ



ការទុកដាក់ក្នុងថង់រាប់ខែ



ណាយស្ករត្នោត

### ការធ្វើចំណីផ្សំ

- គ្រប់សមាសធាតុផ្សំទាំងអស់ត្រូវលាយច្របល់ដោយប្រុងប្រយ័ត្នដោយដៃ
- កូរស្ករជាមួយទឹកឱ្យសព្វបន្ទាប់មកប្រស់ ឬស្រោចលើគំនរចំណី និងច្របល់ឱ្យសព្វល្អ។



ច្របល់កន្ទក់ជាមួយចំណិតមើមដំឡូងស្ងួតឱ្យបានសព្វល្អ



ពេលនេះណាយជាមួយស្លឹកដំឡូងមី



៧-៣ថ្ងៃក្រោយមកគោបានទម្លាប់ស៊ីចំណីផ្សំ

### ៣.៤ ចំបើងផ្អាប់ដោយអ៊ុយរ៉េ

គោលបំណងដើម្បីបង្កើតសារធាតុចិញ្ចឹមរបស់ចំបើងអ៊ុយរ៉េ ត្រូវលាយជាមួយទឹក និងចំបើង។

- អាម៉ូញ៉ាក់ដែលមាននៅក្នុងអ៊ុយរ៉េ ធ្វើឱ្យគុណភាពចំបើងកើនឡើង ដូចជាធ្វើឱ្យជាតិសសៃរឹងងាយរលាយ (ចំបើងអាចងាយរំលាយ)
- អាម៉ូញ៉ាក់បង្កើនការផ្ទុកនីត្រូសែនក្នុងចំបើង និងជួយដល់ការលូតលាស់របស់ពួកមីក្រុបក្នុងពោះធំ
- ការផ្អាប់ចំបើងជាមួយអ៊ុយរ៉េនឹងបង្កើតគុណភាពសារធាតុចិញ្ចឹម និងបរិមាណស៊ីចំបើងបានច្រើន។

#### ការធ្វើចំបើងផ្អាប់ដោយអ៊ុយរ៉េ

កត្តាសំខាន់ៗរួមមាន៖

- បរិមាណអ៊ុយរ៉េគឺ ៥ គីឡូក្រាមសម្រាប់ផ្អាប់ជាមួយចំបើងស្ងួត១០០គីឡូក្រាម
- បរិមាណសំណើមគឺ អ៊ុយរ៉េ១ គីឡូក្រាមលាយជាមួយទឹក១០លីត្រ
- រយៈពេលផ្អាប់គឺ ចំបើងអាចឱ្យគោស៊ីនៅពីរអាទិត្យបន្ទាប់ពីផ្អាប់ក្នុងខែក្ដៅ ព្រោះវាមានសីតុណ្ហភាពលើស



ធ្វើអាងសម្រាប់ផ្អាប់ចំបើង



ពេលរៀបចំបើងពេញអាងត្រូវយកថង់ ឬតង់គ្របឱ្យជិតកុំឱ្យចូលខ្យល់



ថ្លឹងជីអ៊ុយរ៉េ ២គក្រ និងកំបោរស ២គក្រ លាយ ជាមួយទឹក ១០០ លីត្រ (ត្រូវលាយឱ្យសព្វល្អ)



៣អាទិត្យក្រោយអាចឱ្យគោស៊ីបាន



រៀបចំបើងបានមួយជាន់ត្រូវស្រោចល្បាយទឹកអ៊ុយរ៉េម្តង ធ្វើបែបនេះរហូតរៀបពេញអាង



- រៀបចំបើងបានមួយជាន់ត្រូវស្រោចល្បាយទឹកអ៊ុយរ៉េម្តង ធ្វើបែបនេះរហូតរៀបពេញអាង

ពី៣០អង្សាសេ ប៉ុន្តែយើងត្រូវរងចាំ៣អាទិត្យក្នុងខែភ្លៀង ពីព្រោះវាត្រជាក់ និងដំណើរការផ្អាប់មានសភាពយឺត។

~ ការគ្របចំបើង ត្រូវគ្របឱ្យជិតចៀសវាងខ្យល់ចូលប៉ះជាមួយនឹងចំបើង។

**ការស៊ីចំបើងផ្អាប់**

~ គោមួយក្បាលទម្ងន់៣០០គីឡូក្រាម អាចស៊ីចំបើងផ្អាប់៦គីឡូក្រាមក្នុងមួយថ្ងៃ។

~ គោពីរក្បាល ស៊ី១២គីឡូក្រាមក្នុងមួយថ្ងៃ

~ រយៈពេលផ្អាប់គឺ៣អាទិត្យ ដូចនេះកសិករត្រូវរៀបចំបរិមាណចំបើងដើម្បីផ្តល់ឱ្យគោក្នុងពេល ៣អាទិត្យ គឺស្មើ និង១២គីឡូក្រាម គុណនឹង២១ថ្ងៃ ស្មើនឹង២៥២គ.ក្រ

~ បរិមាណ១០០គ.ក្រចំបើងផ្អាប់ដោយអ៊ុយរ៉េ គឺប្រហែលម៉ែត្រគូប ដូចនេះអាងត្រូវមានទំហំធំជាង២,៥ម៉ែត្រគូប។

~ ពេលគោស៊ីចំបើងក្នុងអាងទី១ កសិករត្រូវរៀបចំផ្អាប់ក្នុងអាងទី២ទៀត ពេលគោស៊ីនៅអាងទី១អស់បន្ទាប់ពី៣អាទិត្យនោះអាងទី២ ក៏រួចរាល់សម្រាប់បើកឱ្យគោស៊ី

ដែរ។ ពេលគោចាប់ផ្ដើមស៊ីនូវអាងទី២ កសិករត្រូវចាប់ផ្ដើមផ្គាប់អាងទី១ជាថ្មីទៀត។

~ ដើម្បីផ្ដល់ចំបើងផ្គាប់ដោយអ៊ុយរ៉េជាចំណីគោ កសិករត្រូវសាងសង់អាងពីរដែលមានទំហំ៣ម៉ែត្រគូប។

ការចាប់ និងការពិនិត្យសត្វ៖

~ ត្រូវធ្វើឱ្យសត្វមានសុវត្ថិភាព

~ មិនត្រូវធ្វើឱ្យសត្វ ស្រ្តេស

~ ត្រូវមានជំនាញដើម្បីចាប់សត្វ និងព្យាបាលសត្វ

**ក- បក្សី**

១. ការពិនិត្យហ្វូងសត្វ

☞ ទិដ្ឋភាពទូទៅ

មានដែលមាំមួនមានរោម ស្លាបភ្លឺរលោងការលូតលាស់រាងកាយល្អ គឺជាសញ្ញាសត្វមានសុខភាពល្អ។

~ ពេលឃើញមាន់ងាប់ក្នុងសភាពល្អ ភ្នាក់ងារចម្លងជំងឺ និងសម្លាប់មាន់ក្នុងរយៈពេលខ្លី គឺមានដូចជាជំងឺផ្ដាសាយបក្សី ដង្កោ( ញូវកាស ).....។

☞ ឥរិយាបថ

~ មាន់នៅមានដងខ្លួនត្រង់ មាំមួន រវៀសរវៃ

~ ពេលមាន់នៅបែកពីគេ ហើយបង្ហាញភាពស្ពឹកស្រពន់និងងាយស្រួលចាប់នោះ ប្រហែលមានជំងឺហើយ។



រវៀសរវៃ ស្លាបភ្លឺរលោងស៊ីចំណី



ស្គម មិនស៊ីចំណី មិនសូវបានរោម



ក្បាល និងកន្ទុយប៉ះឡើង



បិទភ្នែក និងអស់កម្លាំង

**ការដើរ**

មាន់ចិញ្ចឹមលក្ខណៈគ្រួសារ ត្រូវមានជើងមាំ ដើម្បីស្វែងរកចំណី។ ជើងខ្វិចៈ មានដើររកស៊ីចំណីដោយខ្លួនឯង តែងមានរបួសធ្វើឱ្យវាឈឺជើងវាមិនអាចរកចំណីស៊ីបានគ្រប់គ្រាន់។ បើមិនមានការព្យាបាលត្រឹមត្រូវ មាន់នឹងចុះស្គម ហើយសត្វចង្រៃងាយចាប់ស៊ី។



*មាន់ដើររឹងមាំ ដើម្បីស្វែងរកចំណីក្នុងភូមិ*



*ចំពោះមាន់ដើររកចំណីដោយខ្លួនឯង បើជើងពិការ គឺមិនអាចរស់បានទេ*

## ២. ការពិនិត្យផ្ទាល់

**ការចាប់(កាន់)**

អំឡុងពេលសង្កេតលើហ្វូងសត្វ មានសារៈសំខាន់ណាស់ ក្នុងការកំណត់សត្វដែលឈឺ(ខ្សោយ អស់កម្លាំង ឈឺជើង...)។ចាំបាច់ត្រូវចាប់មាន់ឈឺ និងកាន់វាឱ្យបានត្រឹមត្រូវ ដើម្បីធ្វើការពិនិត្យឱ្យបានច្បាស់លាស់។ ការពិនិត្យនេះអាចកត់សម្គាល់នូវសញ្ញាគ្លីនិកមួយចំនួន ដែលជួយក្នុងការធ្វើរោគវិនិច្ឆ័យ។

**ការពិនិត្យលើក្បាលមាន់**

- សិរ និងណង់ត្រូវមានពណ៌ក្រហមភ្លឺរលោង
- ភ្នែកត្រូវមានពន្លឺភ្លឺថា និងវាងវៃ
- រន្ធច្រមុះត្រូវស្អាត មិនមានហៀរ សំបោរ និងមិនឮសម្លេងដកដង្ហើម។





*ហូរសំបោរ*

**ការពិនិត្យលើទ្រូងមាន់**

- ការពិនិត្យមើលមាន់ធាត់ ឬ ស្គម គឺជាគន្លឹះសំខាន់

ដើម្បីកំណត់ពីការផ្ដល់ចំណីគ្រប់គ្រាន់ ឬមានជំងឺរ៉ាំរ៉ៃ។ ពេលខ្លះមានការពិបាកមើលចំពោះមេមាន់ ព្រោះរោម ស្លាបដុះច្រើន។



ផ្ទានជើងរឹងផាំ ដើម្បីស្វែងរកចំណីក្នុងភូមិ

- ☞ ការពិនិត្យរន្ធគូថមាន់
  - ~ ពិនិត្យមើលសញ្ញារាកនិងពិនិត្យមើលបរាសិត។





រន្ធប្រឡាក់ដោយលាមក

- ☞ ការពិនិត្យលើស្បែកមាន់ លើដងខ្លួននិងលើជើង
  - ~ ពិនិត្យមើលស្លាកស្នាមរបួស
  - ~ ពិនិត្យមើលស្នាមប្រឡាក់
  - ~ ពិនិត្យមើលក្រមរ និងរន្ធគល់ស្លាប
  - ~ ពិនិត្យមើលបរាសិត។



ដៃ



ជើងក្រិន

## ខ- ជ្រូក

### ១. ការពិនិត្យទូទៅ

ស្វាហាប់(មាំមួន)៖ ជាធម្មតាពេលយើងដើរមកក្បែរទ្រុងជ្រូកក្រោកឈរ ព្រោះវាប្លែក តែបើជ្រូកខ្លះនៅតែដេកប្រមូលគ្នាគឺជាសញ្ញាសត្វមានជំងឺ។



ជ្រូកទាំងអស់រវៀសរវៃ និងស៊ីចំណីបានល្អ



ជ្រូកប្រមូលផ្តុំគ្នានៅជ្រុងម្ខាង និងដេកគ្មានជ្រូកណាមួយនៅក្បែរស្នូកចំណី

**សភាពដងខ្លួន(រាងកាយ):** ជ្រូកប៉ុនៗគ្នាជាសញ្ញានៃការថែរក្សា និងសត្វមានសុខភាពល្អ។ជ្រូកមិនធំធាត់ក្នុងទ្រុងតែមួយ ជាសញ្ញានៃជំងឺរ៉ាំរ៉ៃ ឬ ផ្តល់ចំណីមិនបានគ្រប់គ្រាន់។



ជ្រូកមានរាងកាយល្អ និងទំហំប៉ុនៗគ្នា



ជ្រូកមានសុខភាពល្អ ប៉ុន្តែមិនមានចំណីគ្រប់គ្រាន់

**ការធ្វើចលនា:** វាមានសារៈសំខាន់សម្រាប់បសុពេទ្យដើម្បីពិនិត្យមើលថា តើសត្វអាចធ្វើចលនាបានធម្មតាឬទេ។ ជ្រូកនៅក្នុងទ្រុង ត្រូវដេញឱ្យក្រោកឈរ ប្រសិនបើមិនចង់ក្រោកឈរ ឬឈឺជើងដើម្បីធ្វើរោគវិនិច្ឆ័យ។



ជ្រូកអង្គុយចុះច្រត់ទ្រលើគែជង្គង់
(ច្រើនឃើញចំពោះជ្រូកកើតប៉េស្ត)

**ការស៊ីចំណី:** ការសង្កេតលើស្នូកចំណី បង្ហាញថាសត្វស៊ីចំណីបានល្អ ឬស៊ីមិនបានល្អ។ពេលសត្វឈឺខ្លាំងវាឈប់ស៊ីចំណី។



ជ្រូកមានរាងកាយល្អ និងទំហំប៉ុនៗគ្នា



ជ្រូកស៊ីចំណីអស់ពីស្នូក

**ការក្អក:** ពេលយើងមកជិតទ្រុង ជ្រូកនឹងក្រោកឈរ និងផ្លាស់ទី ហើយបង្កឱ្យជ្រូកក្អកពិសេសពេលព្រឹកព្រលឹម។ ប្រសិនបើជ្រូកនៅតែដេក យើងមិនអាចកំណត់បានទេ។

**លាមក:** ត្រូវធ្វើការពិនិត្យអាចឃើញលាមករាកនៅលើផ្ទៃក្រាល។ ការទល់លាមកចំពោះមេធើម មានសារៈសំខាន់ណាស់។



កូនជ្រូករាក ឃើញលើបាតទ្រុង



រាក (ជំងឺកុកស៊ីដ្យូស) ឃើញលើកម្រាល
និងជាប់លើជញ្ជាំង

## ២. ការពិនិត្យផ្ទាល់

ការពិនិត្យជ្រូកតែម្នាក់ឯងមានការលំបាក ព្រោះជ្រូកធ្ងន់ និងរើបម្រាស់លឿន ដូច្នេះត្រូវមានគ្នាពីរនាក់ជាការល្អ។

~ ការវាស់សីតុណ្ហភាពជាការសំខាន់ណាស់ ត្រូវវាស់នៅពេលព្រឹក។ សីតុណ្ហភាពឡើងខ្ពស់ជាសញ្ញានៃការឆ្លងជំងឺ។សីតុណ្ហភាពធម្មតារបស់ជ្រូកគឺក្រោម ៣៩ អង្សាសេ ប៉ុន្តែអាចមានដល់ ៣៩,៥ អង្សាសេ បើវាស់មិនច្បាស់ត្រូវវាស់ពេលបន្ទាប់មកទៀត។



**ការពិនិត្យលើភ្នែក:**

~ ភ្នែកមានហៀរអាចម៍ភ្នែក( ពពឹកភ្នែក )ជាទូទៅជាជំងឺប៉េស្តជ្រូក។



ភ្នែកធម្មតា



ភ្នែកបានឆ្លងជំងឺ

សូមរងចាំអានបន្តនៅទស្សនាវដ្តីកសិកម្ម លេខ ៧៩



# បច្ចេកទេសដាំដំណាំកៅស៊ូលក្ខណៈគ្រួសារ

ដោយ ៖ អគ្គនាយកដ្ឋានកៅស៊ូ

បន្តពីទស្សនាវដ្ដីកសិកម្មលេខ៧៧




ការបង្ហាញពីជម្រៅនៃការចៀរ

### ៤.៣.២ ការចំណាយសំបក

ការចំណាយសំបកកំណើត ត្រូវតែត្រួតពិនិត្យជាចាំបាច់ដើម្បីឱ្យការចៀរជ័រមានរយៈពេលវែង ដែលផ្ដល់លទ្ធផលដល់ការដុះសំបកថ្មីឡើងវិញ និងអាចត្រឡប់មកចៀរលើផ្ទាំងមុខចៀរដដែលនោះវិញបាន។ ផ្ទុយទៅវិញវាមិនទទួលបានទឹកជ័រច្រើនទេនៅពេលដែលគេចៀរសំបកក្រាស់។ មុខចៀរកន្លះស្ពៀរាល់ចៀររាប់បីថ្ងៃម្ដង(S/2,d3) ជាធម្មតាការចំណាយសំបកប្រចាំខែប្រហែល ១,២ស.ម សម្រាប់សំបកកំណើត និង១,៥ស.មសម្រាប់សំបកដុះថ្មី។ ដូច្នេះការចំណាយសំបកក្នុងមួយឆ្នាំ សម្រាប់សំបកកំណើតប្រហែល ១២ស.ម និង១៥ស.ម សម្រាប់សំបកដុះថ្មី។

### ៤.៣.៣ ពេលវេលានៃការចៀរជ័រ

ការចៀរជ័រត្រូវធ្វើនៅពេលព្រឹកព្រលឹមមុនពេលថ្ងៃរះតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យទឹកជ័រហូរបានយូ ពីព្រោះពេលថ្ងៃរះសម្ពាធនៅក្នុងសរសៃទឹកជ័រថយចុះ ដោយសារបំភាយនិងរំហួតទឹកក្នុងស្លឹកកៅស៊ូ។

### ៤.៣.៤ រានចៀរ

រានចៀរ គឺជាចំនួនដើមកៅស៊ូដែលអ្នកចៀរម្នាក់អាចចៀរបានក្នុងរយៈពេល១វេន។ ការកំណត់ចំនួនដើមក្នុងការរានចៀរ អាស្រ័យទៅលើទំហំដើម ប្រវែងមុខចៀរ ស្ថានភាពដី និងជួនការលើតម្រូវការកៅស៊ូ។

នៅលើដីរាបស្មើប្រព័ន្ធចៀរ S/2, d3 ចំនួនដើមកៅស៊ូក្នុង១រានចៀរមានចំនួនប្រហែល ៥០០ដើម។ នៅលើដីជម្រាលចំនួនដើមកៅស៊ូសមស្របក្នុង១រានចៀរមានចំនួនពី ៤០០ ទៅ ៤៥០ដើម។ ក្នុងមួយរានចៀរ អ្នកចៀរជ័រប្រើពេលពី ២ ទៅ ៣ម៉ោង ដើម្បីទុកពេលឱ្យទឹកហូរជ័របានរយៈពេលវែងមុនការប្រមូលទឹកជ័រ។

### ៤.៣.៥ ល្បឿនចៀរជ័រ

ល្បឿនចៀរជ័រអាស្រ័យលើស្ថានភាព ដី លក្ខខណ្ឌផ្ទាំងចៀរ ប្រព័ន្ធចៀរជ័រ កម្រាស់សំបក គម្លាតនៃចន្លោះដើម និងសុខភាពរបស់អ្នកចៀរជ័រ។

ជាធម្មតាដើមកៅស៊ូដែលមានរង្វង់ដើមទំហំ ៥០សង់ទីម៉ែត្រ និងមានសំបករលោងដែរចៀរកន្លះស្ពៀរាល់ប្រើរយៈពេល ១០វិនាទី/ដើម។ ដូច្នេះដើម្បីចៀរជ័រលើដើមកៅស៊ូចំនួន ៥០០ដើម គេត្រូវប្រើរយៈពេលប្រហែល ៣ម៉ោង។

### ៤.៣.៦ ការបំពាក់ឧបករណ៍ត្រង់ជ័រ

ប្រវែងពីមុខចៀរមកចានត្រង់ជ័រមានប្រវែង ៣៥ស.ម នៅចន្លោះពីមុខចៀរមកស្លាបព្រាមានប្រវែង ១៥ស.ម និងពីស្លាបព្រាមកចានត្រង់ជ័រមានប្រវែង២០ស.ម។ គេឆូតចង្អូររាងជ្រៅបន្តិច ដើម្បីឱ្យទឹកជ័រហូរចុះមកក្រោមកាត់តាមស្លាបព្រារួចស្រក់ធ្លាក់ចូលក្នុងចាន។

### ៤.៣.៧ ការចាប់ផ្ដើមបើកមុខចៀរយកជ័រ

មុននឹងចាប់ផ្ដើមដំណើរការចៀរជ័រ ដំបូងគេត្រូវប្រើមុខចៀរចំនួន៣ពន្លាកជាមុនសិន ដោយចៀរតាមលំនាំខ្នាតមុំចំ

ណោតមុខចៀរ ដែលបានរៀបរាប់នៅក្នុងរបៀបបើកមុខខាងលើ និងអនុវត្តតាមជំហានដូចខាងក្រោម៖

ពន្លាកទី១៖ ចៀរសើៗតាមគំរូចំណោតមុខចៀរ។

ពន្លាកទី២៖ ចៀរតាមលំនាំនៃពន្លកទី១ឱ្យបានជ្រៅជាងពន្លាកទី១បន្តិច។

ពន្លាកទី៣៖ រុញពន្លាកចៀរឱ្យបានដល់ជម្រៅតាមបទដ្ឋានដែលបានកំណត់គឺទុក ១ម.ម ពីស្រទាប់កំប៊ីយ៉ូម (Cambium)។




ការបង្ហាញពីរបៀបដាក់ចំទីតាំងផ្ទាំងមុខចៀរឱ្យបានត្រឹមត្រូវ

### ៤.៤ ការគ្រប់គ្រងការចៀរមុខលើ

ការចៀរមុខលើត្រូវបានគេប្រើ ដើម្បីទទួលបានទិន្នផលកើនឡើងភ្លាមៗពីដើមកៅស៊ូ។ នៅកម្ពុជាការបើកមុខចៀរលើ គឺគេអនុវត្តមួយភាគបួនស្ពៀរាល់(S/4)។ ការចៀរមុខលើចាប់ផ្ដើមពីកម្ពស់នៃផ្ទាំងមុខចៀរខាងក្រោម។ ការចៀរលើផ្ទាំងចៀរត្រូវធ្វើឱ្យស្របនឹងទិសដូចការចៀរមុខក្រោម។ បន្ទាប់មកគេបង្កើតចង្អូរមុខចៀរចុងបញ្ចប់ ដោយគូសបញ្ឈរឡើងលើចំណុចកណ្ដាលនៃផ្ទាំងមុខចៀរកន្លះស្ពៀរាល់(S/2)។ បន្ទាប់មកភ្ជាប់ចង្អូរមុខចៀរដំបូងទៅចង្អូរមុខចៀរចុងបញ្ចប់ ដោយបង្កើតចំណោតដោយមានមុំ ៤៥ដឺក្រេ។ ចៀរ២ ទៅ៣ពន្លាកចុះក្រោម រហូតបានទំហំមុខចៀរប៉ុននឹងផ្លែពន្លាក។ បន្ទាប់មកមុខចៀរដេញមកលើដោយបង្កើនជម្រៅជាបន្តបន្ទាប់ ដោយទុកកម្រាស់សំបកប្រមាណ ១,០-១,៥ ម.ម ពីស្រទាប់កំប៊ីយ៉ូម។




ការបង្ហាញពីរបៀបចៀរមុខលើ

#### ៤.៤.១ ទិស និងចំណោតមុខចៀរ

ចំពោះមុខចៀរក្រោម ចំណោតមុខចៀរ ៣០ដឺក្រេគឺស្រមស្របសម្រាប់ទឹកជ័រហូរតាមមុខចៀរដោយមិនមានការហូរជ័រចេញពីចង្អូរមុខចៀរ។ ចំពោះមុខចៀរលើ ចំណោតមុខចៀរ ៤៥ដឺក្រេ ត្រូវបានគេណែនាំឱ្យអនុវត្តដើម្បីកុំឱ្យមានការហូរជ័រចេញពីចង្អូរមុខចៀរ។

#### ៤.៤.៣ ជម្រៅនៃមុខចៀរ

វិធីសាស្ត្រនៃការចៀរល្អ គឺជាការចៀរមិនឱ្យប៉ះសាច់ឈើ (របួសឆ្អឹង)។ អ្នកចៀរជ័រត្រូវប្រុងប្រយ័ត្នធ្វើយ៉ាងណាកុំឱ្យមានរបួសដល់សាច់ឈើ ដើម្បីការពារជាតិទឹកដែលចេញពីសាច់លើមកលាយចូលជាមួយទឹកជ័រ ដែលធ្វើឱ្យទឹកជ័រមានកំហាប់ទាប និងបណ្ដាលឱ្យទឹកជ័រហៀរចេញក្រៅចង្អូរ។

សំបកកំណើតនៃផ្ទាំងចៀរមុខលើ មានកម្រាស់ក្រាស និងមានសរសៃជ័រច្រើន ដែលតម្រូវឱ្យមានការចៀរជ្រៅជាងការចៀរមុខក្រោម តែជៀសវាងកុំឱ្យប៉ះស្រទាប់កំប៊ីយ៉ូម។

#### ៤.៤.៣ ការចំណាយសំបក

ការចំណាយសំបកមានភាពខុសៗគ្នាអាស្រ័យទៅលើកម្ពស់មុខចៀរ និងអាយុរបស់សំបក។ ចំពោះការចៀរមុខលើផ្ទាំងមុខចៀរដំបូងនៅទាបដែលគេអាចបកជ័រកកចេញពីមុខចៀរ ហើយការចំណាយសំបកមានប្រមាណ ២ស.ម ក្នុង ១ខែ។

ការចៀរមុខលើកាន់តែខ្ពស់ គេមិនអាចបកជ័រកកចេញបានឡើយ ដោយការចៀរជ័រត្រូវប្រើកម្លាំងសង្កត់ដំបូងជាការសំខាន់ដើម្បីកាត់ជ័រកក ប៉ុន្តែអាចនឹងចំណាយសំបកច្រើន។ ការចៀរមុខលើកាន់តែខ្ពស់ការចំណាយសំបកកាន់តែច្រើន ពីព្រោះសំបករបស់វាក្រាស់ជាង និងរឹងជាង។ ការចំណាយសំបកនៅលើផ្ទាំងមុខចៀរលើពី ៣,៥ស.ម ទៅ ៤ស.ម គឺជាការធម្មតា។

#### ៤.៤.៤ ការប្រមូលទឹកជ័រ

ចំពោះការចៀរមុខលើ (Upward tapping) ចង្អូរមុខចៀរត្រូវប្រើខ្សែសម្រាប់នាំទឹកហូរទៅដល់ចានទឹកជ័រ ប៉ុន្តែវាជាការលំបាកនៅពេលមុខចៀរកាន់ខ្ពស់។ ក្នុងករណីនេះ ត្រូវភ្ជាប់ខ្សែទឹកជ័រនៅខាងចុងនៃស្លាបព្រាដើម្បីនាំទឹកជ័រចូលក្នុងចាន។ ជម្រើសមួយទៀតគឺការប្រើស្លាបព្រាពីរភ្ជាប់ដោយខ្សែនាំទឹកជ័រ ដោយដាក់ស្លាបព្រាមួយនៅជិតមុខចៀរ និងស្លាបព្រាមួយទៀតនៅជិតចានប្រមូលទឹកជ័រ។




បម្រែបម្រួលខ្លះប្រើក្នុងការចៀរពីក្រោមទៅលើ

#### ៤.៤.៥ ពន្លាកប្រើសម្រាប់មុខចៀរលើ

ពន្លាកមុខចៀរលើ (Upward Tapping) មានផ្លែរាងអក្សរ V។ ចំណែកឯពន្លាកចៀរមុខក្រោម (Downward Tap ping) មានផ្លែរាងអក្សរ U ។ ពន្លាកត្រូវបានផលិតជាចង្អូរផ្ទារ ដែលមានមុំស្រួច ដែលធ្វើឱ្យទឹកហូរជាប់បានល្អតាមចង្អូរ។ មុំសមស្របរបស់ពន្លាកផ្លែអក្សរ Vគឺ ៦០ដឺក្រេ។ បើពន្លាកមានមុំតូចជាង ៦០ដឺក្រេ វាមានការពិបាកក្នុងការសំលៀង និងយកសំបកចេញពីផ្លែពន្លាកដោយផ្លែរបស់វាមានមុំស្រួច ដែលពន្យារពេលនៃការចៀរជ័រ។



ពន្លាកផ្លែអក្សរ V ប្រើសម្រាប់ចៀរមុខលើ

#### ៤.៥ ការគ្រប់គ្រងផ្ទាំងមុខចៀរ

ការចៀរពាក់កណ្តាលជុំស្លៀវ៉ាល់ (S/2) នៅលើផ្ទាំងមុខចៀរ (BO-1) គឺត្រូវអនុវត្តចាប់ពីឆ្នាំទី១ រហូតដល់ឆ្នាំទី៦។ បន្ទាប់មកយើងចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរផ្ទាំងមុខចៀរ (BO-1) នៅផ្ទាំងមុខចៀរទី២ (BO-2) ហើយការចៀរលើផ្ទាំងមុខចៀរទី២ ត្រូវបានអនុវត្តន៍រហូតដល់ឆ្នាំទី១០ គឺចាប់ផ្តើមពីឆ្នាំទី៧ រហូតដល់ឆ្នាំទី១០។ ហើយបន្តចៀរទៀតនៅឆ្នាំទី១៣ ឆ្នាំទី១៦ ឆ្នាំទី១៩ និងបញ្ចប់ក្នុងឆ្នាំទី២២។ ចំពោះការចៀរមុខលើត្រូវបានចៀរនៅក្នុងឆ្នាំទី១១ និងឆ្នាំទី១២ ហើយក៏ផ្អាកចំនួនមួយឆ្នាំសិន។ ហើយការចៀរមុខលើនឹងចាប់ផ្តើមចៀរក្នុងឆ្នាំទី១៤ និងឆ្នាំទី១៥ ហើយក៏ផ្អាកចៀរចំនួន២ឆ្នាំទៀត និងបន្តចៀរចំនួន២ឆ្នាំទៀត។




y1 = ឆ្នាំទី១

y2 = ឆ្នាំទី២

ការគ្រប់គ្រងផ្ទាំងមុខចៀរ

### ៤.៦ លក្ខណៈសម្បត្តិអ្នកចៀរជ័រ

អ្នកចៀរជ័រត្រូវមានភាពអំណត់ រហ័សរហួន ភាពច្បាស់លាស់ និងជំនាញ។ អ្នកចៀរជ័រត្រូវតែមានសុខភាពល្អ ដើម្បីធ្វើការឱ្យមានប្រសិទ្ធភាព។ ជាការប្រសើរ អ្នកចៀរជ័រគួរតែទទួលការបណ្ដុះបណ្ដាល ដើម្បីឱ្យកសិករយល់ដឹងពីលក្ខណៈសរីរៈដើមកៅស៊ូ សារៈសំខាន់របស់សំបក និងមុខងារទាក់ទងផ្នែកដទៃទៀតលើដើមកៅស៊ូ។ អ្នកចៀរជ័រត្រូវមានលក្ខណៈសម្បត្តិសំខាន់ៗដូចខាងក្រោមៈ

- ចៀរឱ្យបានជ្រៅ ចៀសវាងប៉ះសាច់ឈើ (របួសឆ្អឹង)
- រក្សាចំណោតមុខចៀរឱ្យបានទៀងទាត់ ចៀសវាងហូរទឹកជ័រលើផ្ទាំងចៀរ
- ពិនិត្យការចំណាយសំបកឱ្យបានត្រឹមត្រូវ ដោយមិនលើសពីគំនូសក្រិតនៃការចំណាយសំបក
- បញ្ចប់ការចៀរតាមរានឱ្យបានលឿនតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យទឹកជ័រហូរស្រក់បានយូរមុនពេលប្រមូលទឹកជ័រ។

## ៥. ការធ្វើរំញោចកម្មបង្កើនទិន្នផល

ការធ្វើរំញោចកម្មលើដើមកៅស៊ូ គឺជាវិធីសាស្ត្រសារធាតុគីមីដើម្បីទាញយកទឹកជ័រឱ្យច្រើនដោយវាមិនធ្វើឱ្យមុខសរសៃជ័រឆាប់ស្ទះ និងធ្វើឱ្យទឹកជ័រហូរបានយូរ។ ការធ្វើរំញោចកម្ម ធ្វើឱ្យកសិករទទួលបានទិន្នផលកៅស៊ូច្រើន ដោយមិនចាំបាច់បង្កើនប្រវែងមុខចៀរ និងចង្វាក់ចៀរ។

### ៥.១ គុណសម្បត្តិនៃការធ្វើរំញោចកម្ម

- បង្កើនបរិមាណទិន្នផលយ៉ាងតិច៣០%
- ចំណាយសំបកតិច ដោយសារមិនចាំបាច់បង្កើនប្រវែងមុខចៀរ និងចង្វាក់ចៀរ។
- ពន្យាការចៀរលើសំបកដុះឡើងវិញ ដែលធ្វើឱ្យការដុះសំបកថ្មីបានល្អពេញលេញ។

### ៥.២ ថ្នាំរំញោច

អេតេហ្វូន ឬអេត្រែល ដែលឈ្មោះគីមី អាស៊ីត២ ក្លរ៉ូអេទីល ផូស្វូនិក (2chloroethy-phoshoric acid) គឺជាធាតុសម្រាប់ធ្វើការរំញោចកម្ម បង្កើនទិន្នផលជ័រកៅស៊ូ ដែលគេនិយម។ សារធាតុអេតេហ្វូននេះនឹងបំលែងជាឧស្ម័នក្នុងសរសៃជ័រមានលំនឹង (មិនឆាប់បែកស្ទះរន្ធសរសៃទឹកជ័រ) ធ្វើឱ្យទឹកជ័រហូរបានហូរនាំឱ្យទិន្នផលទឹកជ័រកើនឡើង។

### ៥.៣ កំហាប់ថ្នាំរំញោច

ជាទូទៅថ្នាំរំញោចលក់លើផ្សារមានកំហាប់ ៥%។ តាមបទដ្ឋានបច្ចេកទេស គេត្រូវបន្ថយកំហាប់វាមកនៅត្រឹម ២,៥% សម្រាប់ប្រើលើការចៀរដើមកៅស៊ូក្មេង។ ដើម្បីបន្ថយកំហាប់ពី ៥% គេត្រូវយកអេតេហ្វូនដែលមានកំហាប់ ៥% ចំនួន ១លីត្រ លាយជាមួយទឹក១លីត្រ។ ចំពោះការចៀរមុខលើ ឬចៀរសម្លាប់ដើមគេប្រើអេតេហ្វូនមានកំហាប់ ៥%។ បរិមាណថ្នាំរំញោច ដែលត្រូវលាបក្នុងមួយដើមៗមានចំនួន ១ក្រាម ដោយប្រើជក់ប្រើស្រកីដូង ឬច្រាស់ដុសធ្មេញជ្រលក់មួយលើកសម្រាប់លាបមួយដើម។

### ៥.៤ ចំនួនដង និងពេលវេលាប្រើថ្នាំរំញោច

ចំនួនដងនៃការប្រើថ្នាំរំញោចតិច ឬច្រើនក្នុងមួយឆ្នាំអាស្រ័យលើពូជ (ក្លូន) កៅស៊ូ។ តាមការអនុវត្តកន្លងមកថ្នាំរំញោចត្រូវបានប្រើជាមធ្យមពី ២-៤ដង/ឆ្នាំ ក្នុងរយៈពេល៣ខែ

ម្ដង។ ចូរកុំប្រើថ្នាំរំញោចនៅរដូវក្ដៅ ឬរដូវរំហើយ (ខែកុម្ភៈដល់ខែមេសា) ដើម្បីការពារកៅស៊ូពីការទាញយកផលហួសកម្រិត។

ការធ្វើការរំញោចកម្មត្រូវប្រព្រឹត្តទៅ ២៤ ទៅ៤៨ម៉ោង មុនពេលចៀរនៅវគ្គបន្ទាប់ទៀត។ ការធ្វើរំញោចកម្មលើសកម្រិតកំណត់អាចបណ្ដាលដើមកៅស៊ូខ្សោយ សំបកស្ងួត និងទឹកជ័រលែងហូរ ដែលគេហៅថាជំងឺស្ងួតមុខចៀរ។

### ៨.៨ វិធីលាបថ្នាំរំញោច

ការលាបថ្នាំរំញោចមានវិធីផ្សេងៗគ្នាដូចខាងក្រោម៖

- ការលាបលើសំបកកោសក្រោមមុខចៀរ (Ba: Bark Application)
- ការលាបលើចង្អូរមុខចៀរ (Ga: Groove Application)
- ការលាបលើមុខចៀរ (La: Lace Application)
- ការលាបលើផ្ទាំងមុខចៀររួច (Pa: Panel Application)

#### ៨.៨.១ ការលាបសំបកកោសក្រោមមុខចៀរ (Ba:Bark Application)

កោសស្រទាប់ខាងក្រៅនៃសំបកចេញស្ដើងៗ កម្ពស់ប្រវែង ៥ស.ម នៅខាងក្រោមមុខចៀរ រួចលាបថ្នាំរំញោចស្ដើងៗ លើចំណែកដែលបានកោសរួចដោយប្រើជក់មុខរាបស្មើ។




ការលាបថ្នាំរំញោចដោយប្រើជក់

#### ៨.៨.២ ការលាបលើចង្អូរមុខចៀរ (Ga: Groove Application)

បកយកជ័រមុខ និងជូតសំអាតទឹកជ័រ។ លាបថ្នាំរំញោចលើចង្អូរមុខចៀរដោយប្រើជក់។ វិធីសាស្ត្រនេះងាយស្រួល និងចំណាយពេលតិចជាងវិធីកោសសំបកចេញ និងទទួលបានទិន្នផលឆ្លើយតបយ៉ាងមានប្រសិទ្ធភាព។



ការលាបថ្នាំរំញោចលើចង្អូរមុខចៀរ

#### ៨.៨.៣ ការលាបលើមុខចៀរ (La: Lace Application)

ចំពោះវិធីនេះ ថ្នាំរំញោចបានប្រើលាបមុខចៀរដោយប្រើថ្នាំលើជក់តូចដោយមិនបកជ័រមុខចេញ ដែលវិធីនេះថ្នាំរំញោចជាប់លើមុខជ័រផង និងសំបកដុះឡើងវិញផង។ វិធីនេះចំណេញពេលជាងវិធីលាបលើចង្អូរមុខចៀរដែលបកជ័រមុខចេញ។



ការលាបថ្នាំរំញោចលើមុខចៀរ

#### ៨.៨.៤ ការលាបលើផ្ទាំងមុខចៀររួច (Pa: Panel Application)

ចំពោះវិធីនេះ ថ្នាំរំញោចត្រូវបានលាបលើសំបកដុះឡើងវិញផ្នែកខាងលើមុខចៀរ បន្ទាប់ពីចៀរបានចំនួន ១ ទៅ ២ខែ និងមិនមានការកោសសំបកចេញទេ។ វិធីនេះងាយស្រួល និងចំណាយតិច ប៉ុន្តែវិធីនេះអនុវត្តន៍បានតែចំពោះដើ

កៅស៊ូដែលសំបកវាមិនត្រូវបានចៀរម្តងទៀត។





ការលាបថ្នាំរំញោចលើផ្ទាំងមុខចៀរ

## ឯកសារយោង៖

១. សៀវភៅបច្ចេកទេសកៅស៊ូ សម្រាប់កសិករកៅស៊ូគ្រួសារនៅប្រទេសភីលីពីន (E.A.ALCALA , 200manual for rubber smallholder, Philiphin

២. អគ្គនាយកដ្ឋានកៅស៊ូ របាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ ២០១៥ និងទិសដៅការងារឆ្នាំ២០១៦

៣. វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ២០០៤ បច្ចេកទេសធ្វើថ្នាលបណ្តុះកូនកៅស៊ូក្នុងថង់តាមលក្ខណៈគ្រួសារ

៤. វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ២០០៨ មគ្គុទេសបច្ចេកទេសវិធីដាំកូនកៅស៊ូឆ័ត្រ

៥. វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ២០១១ មគ្គុទេសបច្ចេកទេសរបៀបបើកមុខចៀរដំបូង

៦. វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ២០១២ មគ្គុទេសបច្ចេកទេសការរំញោចទឹកជ័រដោយប្រើអេតេហ្វូន ៕







# ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាមរយៈយន្តការរេដបូកនៅខេត្តកំពង់ធំ ITTO PD 740/14 Rev.2 (F)

ដោយៈ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមរយៈការបាត់បង់ និងរេចរឹលព្រៃឈើ ឬ រេដបូក គឺជាយន្តការមួយដែលបណ្តាប្រទេសលើពិភពលោកឯកភាពគ្នាថាមានសក្តានុពលក្នុងការកាត់បន្ថយការកើនឡើងកម្តៅលើភពផែនដី ព្រមទាំងចូលរួមចំណែកក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។ ប្រទេសកម្ពុជាបាននិងកំពុងអនុវត្តសកម្មភាពស្តែងចេញពីយន្តការនេះ មានទាំងកម្រិតគម្រោង និងកម្រិតថ្នាក់ជាតិ។ តួយ៉ាងមានគម្រោងកាបូន នៅខេត្តឧត្តរមានជ័យ និងគម្រោងកាបូនសីមា ដែល បានអនុវត្តក្រោមស្តង់ដារកាបូនស្ម័គ្រចិត្តកន្លងមក។ កម្ពុជាបានទទួលមេរៀន និងបទពិសោធន៍ជាច្រើនពីគម្រោងទាំង នោះដើម្បីឈានទៅរកការអនុវត្តកម្មវិធីរេដបូកថ្នាក់ជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការក្នុងការអនុត្តកម្មវិធីរេដបូកថ្នាក់ជាតិ គឺមានលក្ខណៈស្មុគស្មាញ ហើយទាមទារនូវបទពិសោធន៍ជាក់ស្តែងជាច្រើនបន្ថែមទៀត ជាពិសេសចេញពីសកម្មភាពគម្រោង។

ដោយពិនិត្យឃើញពីសារសំខាន់នៃសកម្មភាពរេដបូកនេះ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើត និងអនុវត្តគម្រោង “ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាមរយៈយន្តការរេដបូកនៅក្នុង ខេត្តកំពង់ធំ, ITTO PD 740/14 Rev.2( F )”។ គម្រោងនេះទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈអង្គការព្រៃឈើត្រូពិចអន្តរជាតិ ( ITTO ) និងមានគោលដៅដើម្បីចូលរួមចំណែកការអនុវត្តរេដបូកឱ្យមាន ប្រសិទ្ធភាពតាមរយៈការកសាងសមត្ថភាពអ្នកពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីយន្តការរេដបូក និងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋក្នុងសហគមន៍ដើម្បីចូល រួមចំណែកក្នុងការកាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើក្នុងខេត្តកំពង់ធំ។ តំបន់សហគមន៍ព្រៃឈើគោលដៅចំនួន ០៣ក្នុងខេត្តកំពង់ធំ ត្រូវបានជ្រើសរើសសម្រាប់អនុវត្តសកម្មភាពសំខាន់ៗរបស់គម្រោងគឺ សហគមន៍ព្រៃឈើវាលអូរក្តី ស្ថិតក្នុងស្រុកសន្ទុក សហគមន៍ព្រៃឈើក្បាលអូរក្រញ៉ាក និងសហគមន៍ព្រៃឈើក្បាលខ្លា ស្ថិតនៅ ក្នុងស្រុកសណ្តាន់។

ការអនុវត្តគម្រោងនេះ បានចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមមួយចំនួនក្នុងការគ្រប់គ្រងព្រៃឈើ និងបង្កើតសកម្មភាពចូលរួមចំណែកកាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើក្នុងតំបន់ទំរឹងនៃខេត្តកំពង់ធំ តាមរយៈការកសាងសមត្ថភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការលើកកម្ពស់ការយល់ដឹងដល់គណៈកម្មាធិការសហគមន៍ ការគាំទ្រក្នុងដំណើរការចុះកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ ការគាំទ្រកម្មវិធីស្តារព្រៃឈើ និងការបង្កើតកម្មវិធីអភិវឌ្ឍន៍ជីវភាពសហគមន៍។ សកម្មភាពសំខាន់ៗរួមមាន៖

គាំទ្រកម្មវិធីល្បាតព្រៃសហគមន៍ តាមរយៈការគាំទ្រថវិកា សម្ភារល្បាត និងការបណ្តុះបណ្តាលនានាដល់សមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើតាមរយៈវគ្គបណ្តុះបណ្តាលនានា




វគ្គបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិស្តីពីការប្រើប្រាស់ដ្រូន

- ☑ គាំទ្រកម្មវិធីបោះស្លាកសម្គាល់ព្រំព្រៃសហគមន៍
- ☑ គាំទ្រកម្មវិធីប្រើប្រាស់ទឹកក្នុងសហគមន៍
- ☑ គាំទ្រកម្មវិធីស្ដារព្រៃឈើក្នុងតំបន់រេចរឹលក្នុងព្រៃសហគមន៍គោលដៅ



គាំទ្រកម្មវិធីស្ដារព្រៃឈើនៅតំបន់រេចរឹល ក្នុងសហគមន៍ព្រៃឈើគោលដៅ

- ☑ បង្កើតកម្មវិធីអភិវឌ្ឍន៍ជីវភាពសហគមន៍ និងកម្មវិធីបណ្ដុះបណ្ដាលកសិករគំរូ ក៏ដូចជាកសិករទូទៅក្នុងតំបន់គោលដៅសហគមន៍ទាំង៣



ប្រធាន និងសមាជិកសមាជិកាគណៈកម្មាធិការបច្ចេកទេស ចុះទស្សនកិច្ចនៅទីតាំងកសិករគំរូ ឈ្មោះ សេង យ៉េត នៅស្រុកសន្ទុក

- ☑ គាំទ្រកម្មវិធីប្រើប្រាស់ចង្ក្រានសន្សំសំចៃថាមពលអុស
- ☑ លើកកម្ពស់ការយល់ដឹងសហគមន៍ពីការប្រែប្រួលអាកាសធាតុ និងយន្តការរេដបូក
- ☑ រៀបចំកម្មវិធីកសាងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់ជាតិ តាមរយៈវគ្គបណ្ដុះបណ្ដាល ស្ដីពីការវាយតម្លៃគម្របព្រៃឈើដោយប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ
- ☑ គាំទ្រដំណើរការចុះកិច្ចព្រមព្រៀងរបស់សហគមន៍ព្រៃឈើវាលអូរក្ដី ជាមួយខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ ដោយបញ្ចប់ការចុះធ្វើបច្ចុប្បន្នភាពការប្រើប្រាស់ដីក្នុងព្រៃសហគមន៍។



Mr.Youngtea Choi, ITTO និងក្រុមការងារចុះទស្សនកិច្ច ទីតាំងអណ្ដូងទឹកស្អាតប្រើថាមពលពន្លឺព្រះអាទិត្យ នៅសហគមន៍ក្បាលខ្លា ស្រុកសណ្ដាន់ ខេត្តកំពង់ធំ



ចង្ក្រានសន្សំសំចៃថាមពលអុសរបស់គម្រោង



ការដំឡើងប្រព័ន្ធស្រោចស្រពដោយប្រើថាមពលពន្លឺព្រះអាទិត្យ នៅស្រុកសន្ទុក ខេត្តកំពង់ធំ

សកម្មភាពទាំងអស់នេះរួមចំណែកជំរុញទឹកចិត្តដល់អ្នកពាក់ព័ន្ធឱ្យមានការចូលរួមក្នុងការទប់ស្កាត់ ការបាត់បង់ព្រៃឈើក្នុងតំបន់ និងជំរុញទឹកចិត្តសមាជិកសហគមន៍ព្រៃឈើឱ្យចូលរួមការពារធនធានព្រៃឈើក្នុងតំបន់ទំរឹងបន្ថែមទៀត៕

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆមាសទី១ ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆមាសទី១នេះ ការងារបង្កបង្កើនផលដំណាំរដូវវស្សាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសស្រូវរដូវវស្សាសម្រេចបាន ១ ៩៨៣ ០៤៥ហ.ត ស្មើនឹង៧៦,០១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ វិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆមាសទី១នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់តាមរយៈការប្រជុំពីចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅ របស់រាជរដ្ឋាភិបាលដែលសម្រេចបានគិតត្រឹមឆមាសទី១ ឆ្នាំ២០២១នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែកជាំដុះ

### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ១៤៥ ០០៦ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៨ ៨៩៨ហ.ត ស្មើនឹង០,៤១% និងដោយគ្រឿងយន្តចំនួន ២ ១៣៦ ១០៨ហ.ត ស្មើនឹង៩៩,៥៩%
- ផ្ទៃដីសាបសម្រេចបានចំនួន ៩ ៩៣៩ហ.ត លើសឆ្នាំមុនចំនួន ៣ ៩៨០ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ១ ៩៨៣ ០៤៥ហ.ត ស្មើនឹង៧៦,០១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត លើសឆ្នាំមុន ១៩១ ០៨១ហ.ត។

### ១.២ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៤៣ ២០២ហ.ត ស្មើនឹង៨០,៤៧% នៃផែនការចំនួន ៥៣ ៦៨៦ហ.ត តិចជាងឆ្នាំមុន ៦៩០ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៦៤៩ ៦៩៦ហ.ត ស្មើនឹង៧៩,២៣% នៃផែនការចំនួន ៨១៩ ៩៨៩ហ.ត លើសឆ្នាំមុន ៤ ១៨៥ហ.ត។

### ១.៣ ការនាំចេញផលិតផលកសិកម្ម

#### ១.៣.១ ការនាំចេញអង្ករ

- បរិមាណអង្ករនាំចេញមានចំនួន ២៨០ ៤៥០តោន មានការថយចុះចំនួន ១១៧ ២១០តោន (-២៩,៤៧%) បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល៦ខែឆ្នាំ២០២០ ដែលមានចំនួន ៣៩៧ ៦៦០តោន

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

- ការនាំចេញអង្ករក្នុងខែមិថុនា ឆ្នាំ២០២១ មានចំនួន ៤៧ ៤១៩តោន កើនឡើងចំនួន ៥ ៨៥៦តោន (១៤,០៩%) បើធៀបនឹងខែមិថុនា ឆ្នាំ២០២០ ដែលមានចំនួន ៤១ ៥៦៣តោន

- អង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២០ប្រទេស មានបរិមាណសរុបចំនួន ៦៧ ១៣៦តោន (ថយចុះចំនួន ៦៨ ៤៤០តោន ស្មើនឹង -៥០,៤៨%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១៤៣ ២៩៣តោន (ថយចុះចំនួន ៤ ៦៥៦តោន ស្មើនឹង -៣,១៥%) ទិសដៅអាស៊ានចំនួន ៥ប្រទេស មានបរិមាណសរុបចំនួន ២៧ ១៣៦តោន (ថយចុះចំនួន ២៥ ៨៥១តោន ស្មើនឹង -៤៨,៧៩%) និងទិសដៅដទៃទៀតចំនួន ២១ប្រទេស មានបរិមាណសរុប ៤២ ៨៨៥តោន (ថយចុះចំនួន ១៨ ២៦៣តោន ស្មើនឹង -២៩,៨៧%)

- ក្រុមហ៊ុនបាននាំចេញអង្ករចំនួន ៥៦ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន ១០ មានរហូតដល់ ២០៣ ៨៤៧តោន (៧២,៦៩%) និងក្រុមហ៊ុន៤៦ដទៃទៀតបាននាំចេញត្រឹមតែ ៧៦ ៦០៣តោន (២៧,៣១%)។

**១.៣.២ ការនាំចេញកសិផលផ្សេងៗ**

ក្នុងឆមាសទី១ ឆ្នាំ២០២១ មានបរិមាណ៖

- ដំឡូងមីស្រស់ មានចំនួន ៣៥៨ ៨០០តោន (ថយចុះចំនួន -១១,៧៥%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ៦៥ ០០០តោន និងប្រទេសវៀតណាមចំនួន ២៩៣ ៨០០តោន

- ម្សៅដំឡូងមីមានចំនួន ១៥ ៩០៣,៦៤តោន (កើនឡើងចំនួន ១៥,៩៥%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១៤ ១៩១តោន ប្រទេសអ៊ីតាលីចំនួន ៥២,៨៤តោន ប្រទេសណេដឺឡែនចំនួន ១១៤តោន ប្រទេសថៃចំនួន ១ ៣៧៥,៨តោន និងសហរដ្ឋអាមេរិកចំនួន ១៧០តោន

- គ្រាប់ស្វាយចន្ទីមានចំនួន ៨៤៣ ២៤៣,២៦តោន (កើនឡើងចំនួន ៣៣៦,៤៣%) នាំចេញទៅប្រទេសចិនចំនួន ៣ ៥៩០,៨៣តោន ប្រទេសឥណ្ឌាចំនួន ១៧តោន ប្រទេសជប៉ុនចំនួន ៣៣,៤៨តោន ប្រទេសកូរ៉េចំនួន ២,០២តោន ប្រទេសឡាវចំនួន ២តោន ប្រទេសអារ៉ាប់ចំនួន ០,៥១តោន ប្រទេសតួហ្គោចំនួន ០,០១តោន ប្រទេសថៃចំនួន ៣ ១៤៧,៤០តោន ប្រទេសអារ៉ាប់រួមចំនួន ០,០១តោន និងប្រទេសវៀតណាមចំនួន ៨៣៦ ៤៥០តោន

- គ្រាប់ពោតមានចំនួន ១៤០ ៦៦៩,១៣តោន (កើនឡើងចំនួន ១៧៦,៤៤%) នាំចេញទៅប្រទេសបង់ក្លាដេសចំនួន ៤២តោន ប្រទេសកូរ៉េចំនួន ២១តោន កោះតៃវ៉ាន់ចំនួន ៦៧៦,១៣តោន ប្រទេសថៃចំនួន ៤២ ៣៥០តោន និងប្រទេសវៀតណាមចំនួន ៩៧ ៥៨០តោន

- គ្រាប់សណ្តែកបាយមានចំនួន ១៨ ៥៨០តោន (កើនឡើងចំនួន ៥៨៥,៦៧%) នាំចេញទៅប្រទេសវៀតណាម

- គ្រាប់សណ្តែកសៀងមានចំនួន ១៧ ៧៥០,០៤តោន (កើនឡើងចំនួន ១០០%) នាំចេញទៅប្រទេសថៃចំនួន ៧ ០៥០តោន ប្រទេសអារ៉ាប់រួមចំនួន ០,០៤តោន និងប្រទេសវៀតណាមចំនួន ១០ ៧០០តោន

- ផ្លែចេកស្រស់មានចំនួន ២៣៧ ០៩៩,៥តោន (កើនឡើងចំនួន ៦៨,៦៧%) នាំចេញទៅប្រទេសចិនចំនួន ២១១ ០៧៩តោន ប្រទេសជប៉ុនចំនួន ៤២៦,៦៦តោន ប្រទេសសិង្ហបុរីចំនួន ៤៨០,៤៨តោន និងប្រទេសវៀតណាមចំនួន ២៥ ១១៣,៣៦តោន

- ផ្លែស្វាយស្រស់មានចំនួន ១៥៩ ៧៧៨,៥៥តោន (កើនឡើងចំនួន ២៤៥,៨៤%) នាំចេញទៅទីក្រុងហុងកុងចំនួន ៥០,៧៨តោន ប្រទេសកូរ៉េចំនួន ១២៤,៣៨តោន ប្រទេសគុយវ៉ែតចំនួន ០,០១តោន ប្រទេសសិង្ហបុរីចំនួន ១៦,២០តោន ប្រទេសថៃចំនួន ២០ ៩៦៩,២៨តោន ប្រទេសវៀតណាមចំនួន ១៣៨ ៤០៦,៦៨តោន និងប្រទេសចិនចំនួន ២១១,២២តោន

- ដូងប្រេងចំនួន ២៤ ៤១៦,៦៩តោន (កើនឡើងចំនួន ៨,៦៦%) នាំចេញទៅប្រទេសឥណ្ឌាចំនួន ២០ ០១៦,៦៩តោន និងប្រទេសម៉ាឡេស៊ីចំនួន ៤ ៤០០តោន

- ម្រេចមានចំនួន ១៤ ៥៦១,៦២តោន (កើនឡើងចំនួន ៣៩៨,៧៦%) នាំចេញទៅប្រទេសប៊ែលហ្សិកចំនួន ១០,៦៣តោន ប្រទេសកាណាដាចំនួន ០,៥២តោន សាធារណរដ្ឋឆេកចំនួន ៦,១០តោន ប្រទេសបារាំងចំនួន ១៩,០១តោន ប្រទេសអាល្លឺម៉ង់ចំនួន ១៦០,៥៧តោន ប្រទេសឥណ្ឌាចំនួន ៤២តោន ប្រទេសជប៉ុនចំនួន ២,៥៨តោន ប្រទេសកូរ៉េចំនួន ១,៥៥តោន ប្រទេសប៉ូឡូញចំនួន ៧,០៩តោន ប្រទេសរុស្ស៊ីចំនួន ០,៣១តោន ប្រទេសស៊ុយអ៊ែតចំនួន ១,២៩តោន ប្រទេសស្វីសចំនួន ០,៤៨តោន កោះតៃវ៉ាន់ចំនួន ១៥តោន ប្រទេសអង់គ្លេសចំនួន ១,២៤តោន ប្រទេសអារ៉ាប់រួមចំនួន ០,០១តោន សហរដ្ឋអាមេរិកចំនួន ១,៧៥តោន និងប្រទេសវៀតណាមចំនួន ១៤ ២៩១,៤៩តោន

- បន្លែចម្រុះមានចំនួន ៤៤,៩២តោន (ថយចុះចំនួន -២៨,៥១%) នាំចេញទៅប្រទេសបារាំង

២

- ម្ទេសស្រស់មានចំនួន ៦៤ ៩០៧,១២តោន (កើនឡើងចំនួន ៨៣,៤៧%) នាំចេញទៅប្រទេសថៃចំនួន ៦៤ ៩០៧,១២តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០០២តោន

- ម្ទេសក្រៀមមានចំនួន ៩០០,២២តោន (ថយចុះចំនួន -២៤,៩៨%) នាំចេញទៅប្រទេសថៃចំនួន ៩០០តោន ប្រទេសប៊ែលហ្សិកចំនួន ០,២១តោន និងប្រទេសកាណាដាចំនួន ០,០១តោន។

## ២ ផ្នែកផលិតកម្មកៅស៊ូ (ខែឧសភា)

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ១៦០ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្មចំនួន ៤៨ ៥៤៦ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩៤ ៤៥៤ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦១ ១៦០ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ២៩២ ៥១៩ហ.ត ស្មើនឹង៧២% និងផ្ទៃដីថែទាំចំនួន ១១១ ៦៤១ហ.ត ស្មើនឹង២៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ២៦ ០៤៨តោន កើនឡើងចំនួន ៩ ១៧០តោន ស្មើនឹង៥៤% ធៀបខែមុន និងកើនឡើងចំនួន ៣៥៥តោន ស្មើនឹង១% ធៀបខែឧសភា ឆ្នាំ២០២០

- ផលិតផលឈើកៅស៊ូសម្រេចបានចំនួន ២៩៦ម៣ កើនឡើងចំនួន ៤៦ម៣ ស្មើនឹង១៨,៤០% ធៀបខែមុន។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណជ័រកៅស៊ូបញ្ចេញលក់សម្រេចបានចំនួន ២៥ ២៦១តោន កើនឡើងចំនួន ៩ ១៤៦តោន ស្មើនឹង៥៦,៧៥% ធៀបខែមុន និងថយចុះចំនួន ១៨៩តោន ស្មើនឹង១% ធៀបខែឧសភា ឆ្នាំ២០២០

- បរិមាណបញ្ចេញលក់ឈើកៅស៊ូសម្រេចបានចំនួន ២៩៦ម៣ កើនឡើង ៤៦ម៣ ស្មើនឹង១៨,៤០% ធៀបខែមុន។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃជ័រកៅស៊ូលក់មធ្យមក្នុងខែឧសភាគឺ១ ៧០៤ដុល្លារ/តោន ថយចុះចំនួន ៧៩ដុល្លារ/តោន ស្មើនឹង៤,៤៣% ធៀបខែមុន និងបានកើនឡើងចំនួន ៥១៤ដុល្លារ/តោន ស្មើនឹង៤៣% ធៀបខែឧសភា ឆ្នាំ២០២០

- តម្លៃលក់ឈើកៅស៊ូមធ្យមក្នុងខែឧសភាគឺ១៦០ដុល្លា/ម៣

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែឧសភាគឺទឹកជ័រ (DRC ១០០%) មានការប្រែប្រួលពី ៥ ២០០រ/គ.ក្រ ដល់ ៦ ៣២៥រ/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ២០០រ/គ.ក្រ ដល់ ៣ ៣៥០រ/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០២១ ចំនួន ៣០ផ្ទាំង និងរូបភាពផ្កាយរណប Sentinel-2 ចំនួន ២៥ផ្ទាំង បាននិងកំពុងពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២១

- បានចេញសេចក្តីប្រកាសស្តីពី ការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៥កន្លែង មានផ្ទៃដី សរុបទំហំ ៣ ៦១៩,៨៦ហ.ត និងបានយល់ព្រមជាគោលការណ៍លើផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ៣កន្លែងមានផ្ទៃដីសរុបទំហំ ១ ៦៣០ហ.ត

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តសរុបចំនួន ៩៥គ្រឿង និងយានយន្តចំនួន ១២៨គ្រឿង ជូនក្រុមហ៊ុនចំនួន ៧ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១នាក់

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផលអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៧ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន៤ នាក់។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានចុះសិក្សាស្រាវជ្រាវអំពីបន្លាស់ទី ផលប៉ះពាល់ និងអេកូឡូស៊ីសត្វខ្ទីងក្នុងសហគមន៍ព្រៃឈើវាលកន្សែង ស្ថិតក្នុងឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ

- បានចុះប្រមូលលាមកសត្វដំរីក្នុងដែនជម្រកសត្វព្រៃ (ព្រៃឡង់) ក្នុងស្រុកសៀមបូក ខេត្តស្ទឹងត្រែង ដែនជម្រកសត្វព្រៃឆែប និងដែនជម្រកសត្វព្រៃព្រះរការ ស្រុកជាំក្សាន្ត និងស្រុកឆែប ខេត្តព្រះវិហារដោយប្រមូលបានសំណាកលាមកដំរីចំនួន ១៤៩សំណាក

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៦៩ច្បាប់ ក្នុងនោះ ៦៧ច្បាប់សម្រាប់ការថែរក្សាសត្វក្រចៀកកាំ និង ២ច្បាប់សម្រាប់ការថែរក្សាសត្វឃ្មុំ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ខេត្តកោះកុង កំពត តាកែវ ពោធិ៍សាត់ កណ្តាល សៀមរាប បន្ទាយមានជ័យ កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ប៉ៃលិន និងខេត្តមណ្ឌលគីរី

៣

- បានសហការជាមួយអង្គការ FFI ដើម្បីចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ១២គ្រឿង នៅតំបន់ជួរភ្នំក្រវាញ ខេត្តកោះកុង ដោយថតជាប់សត្វជំរីព្រៃចំនួន ២៨ក្បាល ប្រើសចំនួន ១១ក្បាល ឈ្លូសចំនួន ៩ក្បាល ស្វាត្រោសចំនួន ៣២ក្បាល ប្រម៉ាចំនួន ១ក្បាល និងជ្រូកព្រៃចំនួន ៨ក្បាល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧កំពុងដំណើរការកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្ដាមចំនួន ៨៦ ២៨៩ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦៤៥ក្បាល (បក្សីចំនួន ៥៨ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វព្រៃថ្មីចំនួន ៤០៦ក្បាល ព្យាបាលចំនួន ១៨៣ក្បាល និងស្តារលទ្ធភាព ជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ២៨៨ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ៣០នាក់ បានចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងជាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវក្រាលក្រួសក្រហមសរុបប្រវែង ៥ ១១៩ម៉ែត្រ និងកាប់ឆ្ការធ្វើអនាម័យព្រៃបានទំហំ ៥,១៣ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- ជីកប្រឡាយការពារចម្ការគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំប្រវែង២ ០០០ម៉ែត្រ
- បានបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសែនមនោរម្យខេត្តមណ្ឌលគិរីលើផ្ទៃដីទំហំ១០០ហ.ត
- បាននិងកំពុងថែទាំចម្ការឈើសរុប៨២២ហ.ត ក្នុងនោះចម្ការពូជឈើ៩៤ហ.ត ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ ៤៤ហ.ត ចម្ការឈើដាំទំហំ៦៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា ទំហំ៣០ហ.ត ស្ថិតក្នុងខេត្តចំនួន៧
- បានឈូសឆាយសម្អាតដីសម្រាប់ដាំឈើជាចម្ការថ្មីទំហំ១០៥ហ.ត ក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំង
- បានបណ្ដុះកូនឈើគ្រប់ប្រភេទចំនួន ៣៨៤ ៤០៧ដើម និងចែកចាយកូនឈើសម្រាប់ដាំអាស្រ័យផលចំនួន ១៥ ០០៤ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើចំនួន ៣៨១ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើដែលចាប់ឃាត់ និងដកហូតមាន ឈើអារចំនួន ៦៩៩ម៣ ផ្ទៃដីព្រៃឈើកាប់រានទំហំ៨៥៥ហ.ត ក្នុងខេត្តរតនគិរី ព្រះសីហនុ ព្រះវិហារ ក្រចេះ សៀមរាប កំពង់ស្ពឺ ព្រៃវែង កំពង់ឆ្នាំង ស្ទឹងត្រែង តាកែវ និងខេត្តកំពង់ធំ ព្រមទាំងវត្ថុតាងអនុផលព្រៃឈើ និងឧបករណ៍ផ្សេងៗទៀត។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- បានចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផលអនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ៧កន្លែង និងពន្យារសុពលភាពចំនួន ៨កន្លែង

- បានពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ២កន្លែង និងពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើ និងរោងសិប្បកម្មកែច្នៃចិញ្ច្រាំកម្ទេចឈើដាំចំនួន ៤កន្លែង

- ក្រុមហ៊ុនចំនួន៧បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ និងជ័រទឹកទៅក្រៅប្រទេសចំនួន ៩៣០ម៣ ជ័រទឹកចំនួន ១៩៦តោន និងចំណាំងកម្ទេចឈើប្រេងខ្យល់ចំនួន ៤ ០០០តោន

- ក្រុមហ៊ុនចំនួន៣បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ៩០៦ម៣

- បានផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន៨មានឈើកែច្នៃចំនួន ៦៥៤ម៣ ចំណាំងកម្ទេចឈើប្រេងខ្យល់ចំនួន ៧ ០០០តោន ឫស្សីកែច្នៃចំនួន ៣៩តោន និងជ័រទឹកចំនួន ២២៦តោន

- បានផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន៤មានបរិមាណឈើកែច្នៃ (MDF, Wood Panel, Dark Red Meranti, Chanfuta, ឈើស្រស់) សរុបចំនួន ១ ៤២៥ម៣ ។

៤

### ៣.៧ ការងារចំណូលព្រៃឈើ

- បានប្រមូលចំណូលសរុប៤ ៣៣៦ ០៨៣ ៦៥៧រៀល និង១ ៥៣៨ ៦៧១,៦១ដុល្លារ ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិត-ផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ២៦ករណី។ រាជធានី-ខេត្តចំនួន ២៤ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៩៨ ៩៥៩លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**

  - ចុះផ្សព្វផ្សាយអំពីការទប់ស្កាត់ជំងឺផ្តាសាយបក្សី និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៥។
- **ការងារនីតិកម្ម និងវិវាទ**

  - កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ
  - ចុះពិនិត្យ និងតាមដានការអនុវត្តច្បាប់លើវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន៤។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៤ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៧ ៤១៩វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ ជំងឺផ្តាសាយបក្សីផ្ទុះ១កន្លែងនៅភូមិព្រៃកតាច្រែង ឃុំព្រៃងនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង។ ជំងឺដុំពកស្បែកគោ ក្របី (LSD) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) បានរកឃើញតាមរយៈការលួចនាំជ្រូកចូលពីប្រទេសថៃចំនួន ២ករណី នៅខេត្តបន្ទាយមានជ័យ និងត្រូវមន្ត្រីជំនាញសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធសម្រេចដុតកម្ទេចចោលតាមវិធានការបសុព្យាបាល។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តបញ្ចប់ត្រឹមចំនួន ១ ៣១០តោន ស្មើនឹង១១,៩១% នៃផែនការចំនួន ១១ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ១៩០តោន
- នេសាទគ្រួសារដែននេសាទបានចំនួន ១៣២ ២០០តោន ស្មើនឹង៤៤,០៧% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៧០០តោន
- នេសាទគ្រួសារតាមវាលស្រែបានចំនួន ២២ ០០០តោន ស្មើនឹង១៥,៧១% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៨ ៧០០តោន។

៥

៥.១.២ នេសាទសមុទ្រ

បានចំនួន ៥៧ ៤០០តោន ស្មើនឹង៤៤,១៥% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ២០០តោន។

**៥.២ វារីវប្បកម្ម**

- ការចិញ្ចឹមត្រីនិងបង្គាបានចំនួន ១៤៤ ៣៤០តោន ស្មើនឹង៣០,០១% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ៨ ៩៤០តោន

- ការចិញ្ចឹមក្រពើបានចំនួន ៩២ ២០០ក្បាល ស្មើនឹង២៧,៩៤% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៥០ ០៤០ក្បាល

- ការភ្ញាស់កូនត្រីពូជបានចំនួន ៨៤ ៣០០ ០០០កូន ស្មើនឹង៣១,២២% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ៨០០ ០០០កូន។

**៥.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាបបានចំនួន ២៥ ៩១០តោន ស្មើនឹង៣២,៣៩% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ១ ៣៤០តោន

- ផលនេសាទសមុទ្របានចំនួន ៦ ១៣០តោន ស្មើនឹង៥១,០៨% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ២០តោន

- ការផលិតទឹកត្រីបានចំនួន ៣៤ ៧៥០ ០០០លីត្រ ស្មើនឹង៦៣,១៨% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ១ ១៦២ ០០០លីត្រ។

**៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល**

- សំណុំរឿងបទល្មើសជលផលមានចំនួន ១ ២១១ករណី ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ២១៧ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១ ១៤១ករណី និងសមុទ្រចំនួន ៧០ករណី។

**៥.៥ ការនាំចេញផលនេសាទ**

- ផលនេសាទស្រស់នាំចេញចំនួន ១ ៩៤៥តោន ស្មើនឹង២៤,៣១% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ៨០៥តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ១៤៧តោន ស្មើនឹង៧,៣៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៨៥តោន។

**៥.៦ ការប្រមូលចំណូលថវិកាសេវាជលផល**

- ចំណូលបានចំនួន ៤២៤ ៩២៦ ១២៨រៀល ស្មើនឹង១១៨,៥០% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ៨៣ ៤៤១ ៧៦៨រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចុះត្រួតពិនិត្យលើការអនុវត្តតួនាទីភារកិច្ចរបស់អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ និងមេគង្គ

- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផលផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាតនៅខេត្តកណ្ដាល ត្បូងឃ្មុំ តាកែវ ព្រៃវែង និងខេត្តកំពត

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបន្ទាយមានជ័យ និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរដែលក្រសួងណែនាំឱ្យកែលម្អ

- ការទទួលពាក្យបណ្ដឹងតាមរយៈប្រអប់សំបុត្រ និងតាមរយៈប្រព័ន្ធអ៊ិនធើណេតចំនួន ២ករណី

- ស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៥៨៩ករណី លើវិស័យព្រៃឈើ១៤០ករណី ជលផល១៣៤ករណី ពេទ្យសត្វ៦៣ករណី កៅស៊ូ៧ករណី កសិ-ឧស្សាហកម្ម៤ករណី ក្សេត្រសាស្ត្រ៤ករណី នីតិកម្ម ១ករណី និងវិស័យផ្សេងៗ២៣៦ករណី

- ការងារចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ២៨លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៣ ៧១៣ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ១ ៤០៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ១ ៦៨៣ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៦២៧ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៥ ៥៥២ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរចំនួន ២២៩ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១២៥ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្ដាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្ដាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨២៣នាក់ (ស្រី១ ៤១៣នាក់ ស្មើនឹង២៤,២៦%) រួមមាន៖
  + អង្គភាពថ្នាក់កណ្ដាលចំនួន ២ ៩១៤នាក់ (ស្រី៨២៣នាក់ ស្មើនឹង២៨,២៤%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩០៩នាក់ (ស្រី៥៩០នាក់ ស្មើនឹង២០,២៨%)
- តែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៧០នាក់ (ស្រី២៩នាក់)
- រៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ៧នាក់ (ស្រី៣នាក់) ក្នុងនោះ ដោយសុំលាឈប់ពីការងារចំនួន ៤នាក់ និងមរណភាពចំនួន ៣នាក់
- រៀបចំប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន ៧នាក់ (ស្រី១នាក់) ផ្ទេរចូលក្នុងក្រសួងចំនួន ៤នាក់ និងផ្ទេរផ្ទៃក្នុងក្រសួងចំនួន ៣៩នាក់
- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ៣៣នាក់ (ស្រី២០នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ៥នាក់ ច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ៤នាក់ ច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ១៦នាក់ និងច្បាប់ឈប់សម្រាកសម្រាប់ព្យាបាលជំងឺចំនួន ៨នាក់
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ចំនួន ១៥នាក់ (ស្រី៨នាក់)
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលបម្រើការងារវិញចំនួន ៧នាក់ (ស្រី១នាក់)
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១៥នាក់ (ស្រី២នាក់)
- រៀបចំសំណើទៅក្រសួងមុខងារសាធារណៈស្ដីពីសំណើសុំដំឡើងឋានន្តរស័ក្ដិ និងថ្នាក់មន្ត្រីរាជការប្រចាំឆ្នាំ២០២១ ចំនួន២ ៨៣៦នាក់ (ស្រី៦៤២នាក់) ក្នុងនោះ ថ្នាក់កណ្ដាលចំនួន ១ ៤៩៦នាក់ (ស្រី៤០៧នាក់) និងថ្នាក់រាជធានី-ខេត្តចំនួន ១ ៣៤០នាក់ (ស្រី២៣៥នាក់)
- ការបណ្ដុះបណ្ដាលក្នុង និងក្រៅប្រទេសសរុបចំនួន ៧៩៤នាក់ (ស្រី២០៥នាក់) ក្នុងនោះ៖
  + ការបណ្ដុះបណ្ដាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ៧៨២នាក់ (ស្រី២០៣នាក់)
  + ការបណ្ដុះបណ្ដាលក្រៅប្រទេសរយៈពេលខ្លី និងមធ្យមតាមរយៈប្រព័ន្ធអនឡាញ (Online) ចំនួន ៤នាក់។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានចូលរួមប្រជុំ សិក្ខាសាលា បណ្ដុះបណ្ដាល ពិនិត្យផ្ដល់យោបល់ និងសហការសម្របសម្រួលការងារជាមួយបណ្ដាអង្គភាព ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការនានា

- បានរៀបចំសុំផ្ដល់ធាតុចូលលើសេចក្ដីព្រាងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២១-២០៣០

- បានរៀបចំពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងរបាយការណ៍ស្ដីពីវឌ្ឍនភាពប្រចាំឆ្នាំ២០២០ ក្នុងការអនុវត្តក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍នៃប្រព័ន្ធអង្គការសហប្រជាជាតិឆ្នាំ២០១៩-២០២៣

៧

- ចុះពង្រឹងលើការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តរតនគិរី ស្ទឹងត្រែង សៀមរាប ឧត្តរមានជ័យ ពោធិ៍សាត់ បន្ទាយមានជ័យ និងខេត្តបាត់ដំបង
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល ២០២២-២០២៤
- បានពិនិត្យ និងកែសម្រួលផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល ២០២២-២០២៤
- បានធ្វើការណែនាំ និងធ្វើការអង្កេតស្ទង់ទិន្នផលស្រូវប្រាំងឆ្នាំ២០២០-២០២១ ដោយសហការជាមួយមន្ត្រីស្ថិតិថ្នាក់ខេត្តស្រុក បានចុះបេសកកម្មនៅខេត្តពោធិ៍សាត់ ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង និងខេត្តបាត់ដំបង
- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្ដាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្ដងក្នុងសប្ដាហ៍នូវរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្ដាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្ដារាជធានីខេត្តចំនួន២៥
- បានរៀបចំសំណើផ្ដល់កិច្ចសហការ និងសម្របសម្រួលដល់ក្រុមការងារចុះតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២១ និងសុំចាត់មន្ត្រីជំនាញចូលរួមអនុវត្តផ្ទាល់លើការងារតាមដាន និងវាយតម្លៃ
- បានពិនិត្យ និងកែសម្រួលសេចក្ដីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានអនុវត្តប្រមូលចំណូល និងចុះក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ៣៦ ៨២៣ ៩៩៦ ៤១៥រៀល ស្មើនឹង១០៣,៩% ធៀបច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១
- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៤៨ ៦៩៥ ៣៩០ ០៤០រៀល ស្មើនឹង៣២,៦% ធៀបឥណទានថ្មីក្រោយនិយ័តកម្ម
- បានរៀបចំសំណើសុំថវិកាចំនួន ៤១ ២៩១,២៥ដុល្លារអាមេរិក និងចំនួន ២៥ ៦២០អឺរ៉ូ សម្រាប់ទូទាត់ជូនក្រុមហ៊ុន Agriconsulting Europe S.A (AESA) ក្នុងការអនុវត្តកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកវារីវប្បកម្ម (CaPFish Aquaculture) ក្រោមហិរញ្ញប្បទានឥតសំណងរបស់ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD)
- បានរៀបចំសំណើសុំថវិកាចំនួន ១៥២ ៨៦១,០៣ដុល្លារអាមេរិក ដើម្បីបំពេញឡើងវិញចូលគណនីគម្រោងរបៀងអភិរក្សជីវចម្រុះមហាអនុតំបន់មេគង្គក្រោមហិរញ្ញប្បទានឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- បានទទួលបង្កាន់ដៃបង់ប្រាក់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ១៥ក្រុមហ៊ុន
- បានចុះបំពេញការងារនៅខេត្តព្រៃវែង កំពង់ចាម និងខេត្តកំពង់ឆ្នាំង ដើម្បីពិនិត្យការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រពនៅតាមបណ្ដាសហគមន៍កសិកម្ម
- បានចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តសៀមរាប ចំនួន ៨ក្រុមហ៊ុន
- បានរៀបចំលិខិតជូនដំណឹងស្ដីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ៥៤ក្រុមហ៊ុន
- បានរៀបចំឯកសារសម្រាប់ដំណាក់កាលនៃការរៀបចំដេញថ្លៃ និងចរចាថ្លៃសរុបចំនួន ៦គម្រោង
- បានចូលរួមដេញថ្លៃ និងពិគ្រោះថ្លៃផលឈើដាំនៅសង្កាត់រដ្ឋបាលព្រៃឈើឆ្លូង ផ្នែករដ្ឋបាលព្រៃឈើឆ្លូងនៃខណ្ឌរដ្ឋបាលព្រៃឈើខេត្តក្រចេះ
- បានចូលរួមប្រជុំ ពិនិត្យ និងវាយតម្លៃលក់ផលឈើដាំក្នុងទីតាំងដីស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ និងស្រុកសៀមបូក ខេត្តស្ទឹងត្រែង
- បានចូលរួមប្រជុំ ពិនិត្យ សិក្សា និងវាយតម្លៃមធ្យោបាយដឹកជញ្ជូនបទល្មើសព្រៃឈើគ្រប់ប្រភេទរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី ឧត្តរមានជ័យ ត្បូងឃ្មុំ ក្រចេះ កំពង់ធំ កំពត និងខេត្តកំពង់ស្ពឺ ស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤
- បានធ្វើវិចារណកម្មចំណាយលើឥណទានអនុម័តឆ្នាំ២០២១
- បានធ្វើវិចារណកម្មចំណាយលើឥណទានរដ្ឋទេយ្យបុរេប្រទានកម្មវិធីឆ្នាំ២០២១

៨

- ពុំបានចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ ដោយសារស្ថានភាពឆ្លងរាលដាលនៃជំងឺកូវីដ-19។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចូលរួមកិច្ចប្រជុំ៣លើក សិក្ខាសាលា១លើក ចុះកិច្ចព្រមព្រៀង១លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី
- បានចូលរួមកិច្ចប្រជុំ១៨លើក (តាមប្រព័ន្ធវីដេអូពីចម្ងាយ) ទស្សនកិច្ច១លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស និងកិច្ចប្រជុំ៣លើក ក្រោមក្របខ័ណ្ឌកសិ-ពាណិជ្ជកម្មពិភពលោក
- បានសម្របសម្រួលកិច្ចប្រជុំចំនួន ១២លើក ទស្សនកិច្ច SNV ១លើកលើការងារក្នុងប្រទេស
- បានសម្របសម្រួលកិច្ចការងារជាមួយដៃគូអភិវឌ្ឍន៍ចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងចំនួន ៤គម្រោងដោយគិតជាទឹកប្រាក់ចំនួន ៥ ៨២១ ៨៣៨ដុល្លារ
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយគម្រោង ACIAR-CROP/2019/145 ស្តីពីបច្ចេកទេសគ្រប់គ្រងស្មៅសម្រាប់ប្រព័ន្ធដាំដុះដំណាំនៅវាលទំនាបដោយម៉ាស៊ីននៅប្រទេសកម្ពុជា និងប្រទេសឡាវ
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គភាព WCPO ស្តីពីការពង្រីកការអភិរក្ស និងការពារសុខភាពសត្វព្រៃនៅប្រទេសកម្ពុជា
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គភាព APAARI ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការសម្រាប់ការស្រាវជ្រាវកសិកម្មនវានុវត្តន៍ និងការអប់រំកសិកម្មក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៤៦ក្រុមហ៊ុន សរុបចំនួន ១ ៧២៥មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៣២ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤៣ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤០ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៤៥ក្រុមហ៊ុន សរុបចំនួន ២២៨សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- បានពិនិត្យលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗចំនួន ៦ករណី
- បានពិនិត្យ និងផ្តល់មតិសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗចំនួន ៥ករណី។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥៧ក្រុមហ៊ុន
- ចុះពិនិត្យការស្នើសុំចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្ម និងលាយផ្សំវេចខ្ចប់ជាថ្មីចំនួន ២២ក្រុមហ៊ុន។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសរុបចំនួន១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- បានដាក់ឲ្យដំណើរការប្រើប្រាស់អ៊ីម៉ែល (@maff.gov.kh) ផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ថ្នាក់ដឹកនាំប្រើប្រាស់ក្នុងការទំនាក់ទំនងផ្លូវការ
- បានបង្កើត Sub Domain (dal.maff.gov.kh) របស់នាយកដ្ឋាននីតិកម្មកសិកម្មសម្រាប់ភ្ជាប់ទៅកាន់ប្រព័ន្ធ QR Code នៃព័ត៌មានផលិតផលថ្នាំកសិកម្មដែលបានចុះបញ្ជី
- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១

- តាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តលើគេហទំព័រផុសសរុបចំនួន ១ ៨៣៥ព័ត៌មាន

- ដំឡើង និងកំពុងត្រួតពិនិត្យលើការប្រើប្រាស់ Network Attach Server (NAS) សម្រាប់មជ្ឈមណ្ឌលប្រើប្រាស់ក្នុងការទុកដាក់ឯកសារ

- បណ្ណាល័យកសិកម្មបានទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តីទទួលបានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ១៦៧ក្បាល/ច្បាប់

- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកមានអ្នកចូលអានចំនួន ៧១ ២៥២ដង/នាក់។

### ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្តីពីបច្ចេកទេសចិញ្ចឹមបង្កង ភ្ញាស់កូនបង្កងលក់ បច្ចេកទេសចិញ្ចឹមមាន់ ភ្ញាស់កូនមាន់លក់ និងការដាំដុះបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់នៅខេត្តបន្ទាយមានជ័យ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្តីពីការជោគជ័យលើមុខរបរចិញ្ចឹមឃ្មុំនៅខេត្តត្បូងឃ្មុំ និងមុខរបរបង្កាត់ពូជមាន់ស្រែលក់ ភ្ញាស់កូនមាន់លក់របស់កសិករនៅខេត្តកណ្តាល

- បានចុះទៅថត Video បទយកការណ៍ចំនួន ១០ប្រធានបទ

- បានចាក់ផ្សាយឡើងវិញស្តីពីវេទិកាស្វែងយល់ពីកសិកម្មចំនួន ៦ប្រធានបទ

- បានចាក់ផ្សាយឡើងវិញស្តីពីនាទីចុះស្រែជាមួយកសិករចំនួន ៨ប្រធានបទ

- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៣៥ដើម្បីចាក់ផ្សាយ

- បានបោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មានកសិកម្មស្តីពីបទពិសោធន៍ជោគជ័យលើមុខរបរចិញ្ចឹមបង្កង និងភ្ញាស់កូនបង្កងលក់ចំនួន ១ ០០០ច្បាប់។

### ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមក្នុងសិក្ខាសាលាចាប់ផ្តើមអនុវត្ត និងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីគម្រោងបន្លែ ផ្លែឈើកម្ពុជាដំណាក់កាលទី៣

- បានចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យ និងផ្តល់ធាតុចូលលើក្របខ័ណ្ឌជំរុញវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មកម្ពុជា

- បានចូលរួមវគ្គបណ្តុះបណ្តាលមន្ទីរពិសោធន៍និម្មិតតាមប្រព័ន្ធ online ស្តីពីការប្រមូលសំណាកការរៀបចំប្រើប្រាស់ទុកដាក់សំណាក ការលាងសម្អាត និងការវិភាគកាកសំណល់ថ្នាំកសិកម្ម និងការធ្វើបង្ហាញក្នុងមន្ទីរពិសោធន៍តាមវីដេអូ

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងគុណភាពចំណីអាហារតាមប្រព័ន្ធ online នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី

- បានចុះជាមួយអ្នកជំនាញការ JICA ពិនិត្យ និងសិក្សាបញ្ហាពាក់ព័ន្ធខ្សែច្រវាក់ផលិតកម្មស្វាយចន្ទីរបស់សហគមន៍កសិកម្មស្នើសុំគម្រោង KUSANONE នៃរដ្ឋាភិបាលជប៉ុន នៅខេត្តកំពង់ធំ

- បានចុះបណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រងគុណភាព និងសុវត្ថិភាពក្រោយប្រមូលផលនេសាទសមុទ្រនៅខេត្តព្រះសីហនុ

- បានចុះបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពបុគ្គលិករោងចក្រកែច្នៃគ្រាប់ស្វាយចន្ទី ជ័យ សំបូរ នៅខេត្តកំពង់ធំអំពីប្រព័ន្ធ HACCP ការប្រើប្រាស់ឧបករណ៍ សម្ភារ និងគ្រឿងម៉ាស៊ីន

- បានធ្វើការវិភាគលើសំណាកត្រីទឹកសាបចំនួន ១៤ប្រភេទ ក្នុងនោះ វិភាគរកកាកសំណល់លោហៈធ្ងន់គឺ អាសេនិច (Arsenic, As) សំណ (Lead, Pb) និងបារត (Mercury, Hg) វិភាគរកសមាសធាតុគីមីគឺ ខ្លាញ់សរុប (Crude Fat) ហ៊ីស្តាមីន (Histamine) វិភាគរកវត្តមានបាក់តេរីបង្កគ្រោះថ្នាក់គឺ បាក់តេរីសរុប (Total Plate count) សាល់ម៉ូណេឡា (Salmonella) និងអ៊ីកូលី (E-coli)

១០

- បានវិភាគសំណាកទឹកឃ្មុំចំនួន ២ប្រភេទ ក្នុងនោះ វិភាគសមាសធាតុគីមីគឺ សំណើម (Moisture) ផេះ (Ash) អាស៊ីត (Acid/pH) វិភាគរកវត្តមានបាតេរីបង្កគ្រោះថ្នាក់គឺ បាក់តេរីសរុប (Total Plate count) មេតំបែ និងផ្សិត (yeast and mold) សាល់ម៉ូណេឡា (Salmonella) និងអ៊ីកូលី (E-coli)

- បានវិភាគសំណាក ម្សៅត្រីចំនួន ២ប្រភេទ និងចំណីត្រីចំនួន ១ប្រភេទ ក្នុងនោះ វិភាគរកកាកសំណល់លោហៈធ្ងន់អាសេនិច (Arsenic) វិភាគសមាសធាតុគីមីគឺ សំណើម (Moisture) ផេះ (Ash) ប្រូតេអ៊ីន (Crude protein) អាស៊ូត( Nitrogen) ខ្លាញ់សរុប (Crude fat) អំបិល (Salt) ស្ករសរុប(Total sugar) សូដ្យូម(Na) កាល់ស្យូម (Ca) ផូស្វ័រ (P) វិភាគរកវត្តមានបាតេរីបង្កគ្រោះថ្នាក់គឺ បាក់តេរីសរុប (Total Plate count) មេតំបែ និងផ្សិត (yeast and mold) សាល់ម៉ូណេឡា (Salmonella) និងអ៊ីកូលី (E-coli)។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានប្រមូលប្រភេទពូជដំណាំថ្មីៗបន្ថែមទៀតចំនួន ១៥ប្រភេទ សរុបចំនួន ១០៦សំណាក (ត្រសក់២៨សំណាក ល្ពៅ៣៤សំណាក ឪឡឹក២សំណាក ត្រប់៤សំណាក ម្ទេស២សំណាក ចេក៥សំណាក អំពៅ៦សំណាក ដំឡូងជ្វា ៩សំណាក ដំឡូងឈាមមាន់២សំណាក ដំឡូងដៃខ្លា១សំណាក ត្រាវ១សំណាក សណ្តែក១សំណាក ពោត១សំណាក ស្វាយ៥សំណាក និងស្វាយចន្ទី៥សំណាក) មករក្សាទុកក្នុងធនាគារពន្ធុរបស់វិទ្យាស្ថាន និងបន្តការអភិរក្សពូជដំណាំនៅក្នុងវិទ្យាស្ថានចំនួន ៣៩ប្រភេទ រួមមានស្រូវចំនួន ៦ ៧៧៦បញ្ចឹក/សំណាក និងដំណាំផ្សេងៗចំនួន ២ ៥១៧បញ្ចឹក/សំណាក សរុបទាំងអស់ចំនួន ៩ ២៩៣បញ្ចឹក/សំណាក។ ដាំវាយតម្លៃ និងកំណត់លក្ខណៈលើដំណាំ៤មុខគឺ មេទ្បុងចំនួន ៥០សំណាក ម្ទេសចំនួន ៥០សំណាក ល្ពៅចំនួន ៣០សំណាក និងត្រប់ចំនួន ៤០សំណាក

- បានធ្វើពិសោធន៍ចំនួន ៤៥ប្រភេទនៅ១៤៦កន្លែង ក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ៧០កន្លែង។ បើកវគ្គបណ្តុះបណ្តាលកសិករចំនួន ១២លើកមានកសិករចូលរួមចំនួន ៤០០នាក់

- បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន ១០លើក មានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន ៦០នាក់ (ស្រី១៤នាក់)។ មន្ត្រីសរុបចំនួន៤នាក់បាននិងកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតចំនួន២នាក់ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន២នាក់ នៅប្រទេសកូរ៉េ ជប៉ុន និងប្រទេសចិន

- ក្នុងឆមាសទី១ ឆ្នាំ២០២១នេះមានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ៧៦៩ ៣០៤នាក់ ហើយគិតជាមធ្យមមានប្រមាណ៥ ១២៨នាក់/ថ្ងៃ

- បានចូលរួមប្រជុំ សន្និបាត និងកិច្ចប្រជុំផ្សេងៗទៀតនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ២៥លើក និងស្ថាប័ន/អង្គភាពនានាចំនួន ១២លើកតាមប្រព័ន្ធ online (ZOOM) និងទទួលជួបភ្ញៀវជាតិនិងអន្តរជាតិនៅវិទ្យាស្ថានចំនួន ៥លើក មានភ្ញៀវសរុប ២២នាក់។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- បានចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាក្រុមដើម្បីជំរុញសុវត្ថិភាពចំណីអាហារតាមរយៈដៃគូរៀបចំដោយគម្រោង CapFish របស់អង្គការ UNIDO

- បានចុះ MOU រវាងមហាវិទ្យាល័យវិស្វកម្មកសិកម្ម និងខ្មែរអេកូគិចណូឡូជី

- បានប្រជុំពិភាក្សាលើសេចក្តីព្រាងចុះ MoU រវាងមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ(BTIC) និង Cambodia Post Bank លើការជំរុញជីវឧស្ម័នខ្នាតធំដោយមានការជួយសម្របសម្រួលពី UNIDO

- បានចូលរួមប្រជុំជាមួយ IFAD Supervision Mission ដើម្បីពិភាក្សាលើការអភិវឌ្ឍមុខវិជ្ជាបច្ចេកវិទ្យាថាមពលកកើតឡើងវិញ

- បានចូលរួមប្រជុំអំពីវិធីសាស្ត្របង្រៀនតាមបែបថ្មីដែលសហការរៀបចំដោយសាកលវិទ្យាល័យហុងកុង និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម

១១

- បានជួបប្រជុំជាមួយតំណាងក្រុមហ៊ុន Solar Green Energy (Cambodia) Co. LTD ដើម្បីស្នើសុំនិស្សិតសហការស្រាវជ្រាវពី Innovation on aquaculture using solar power for freshwater prawn culture in plastic/concrete tanks Auto-motors by using solar power and Auto-water quality management by using solar power

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី Food Safety and Good Hygiene Practices for Entrepreneurs ដល់ក្រុមអ្នកកែច្នៃគ្រាប់ស្វាយចន្ទីតាមរយៈ online

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី Food Industry Virtual Office Hours ក្រោមប្រធានបទសេចក្តីណែនាំសុវត្ថិភាព និងអនាម័យអាហារសម្រាប់ការពារកូវីដ-១៩ ក្នុងឧស្សាហកម្មអាហារតាមរយៈ online

- រៀបចំចុះកិច្ចសន្យាលើសម្ភារៈកាត់របស់មន្ទីរពេទ្យសត្វក្រោមគម្រោង Capacity development of the faculty of veterinary medicine of the royal university of agriculture (RUA) improving veterinary teaching hospital with focus on small animal research and services គាំទ្រដោយ CE SAIN សម្រេចបាន១០០ភាគរយ

- សាស្ត្រាចារ្យ និងនិស្សិតនៃមហាវិទ្យាល័យនីមួយៗ បាននិងកំពុងបន្តការងារសិក្សាពិសោធន៍ស្រាវជ្រាវលើប្រធានបទរៀងៗខ្លួននៅក្នុងសាកលវិទ្យាល័យ និងនៅមូលដ្ឋានផលិតកម្មផ្សេងៗ។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ១ ១២៧នាក់ (ស្រី៤៦៤នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- និស្សិតនៅប្រទេសអ៊ីស្រាអែលចំនួន ៤១នាក់ (ស្រី២២នាក់) និងនិស្សិតចំនួន ២២ (ស្រី២នាក់) បានវិលត្រឡប់មកកម្ពុជាវិញហើយ

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗដែលកំពុងដំណើរការ គឺការពិសោធន៍ចិញ្ចឹមគោទឹកដោះ ការពិសោធន៍ចិញ្ចឹមបង្គា ការពិសោធន៍បង្កាត់ពូជមាន់ ការសិក្សាពិសោធថ្នាំបណ្តេញសត្វល្អិត ការពិសោធន៍ចិញ្ចឹមពពែនៅតំបន់ភ្នំ ការសិក្សាស្រាវជ្រាវបង្កាត់កេសរកូល ការពិសោធន៍ដំណាំព្រីង ការសិក្សាពិសោធន៍ផលិតម្សៅឫស្សី ការបណ្តុះជាលិការុក្ខជាតិ ការពិសោធន៍ចិញ្ចឹមកង្កែប សាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធន៍ចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ ការសិក្សាផលិតកម្ម និងច្រវាក់តម្លៃស្វាយចន្ទី

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រស្រាវជ្រាវអេពីដេមីសាស្ត្រ

- ចូលរួមវគ្គបណ្តុះបណ្តាលដើម្បីចែករំលែកបទពិសោធន៍លើការងារស្រាវជ្រាវស្តីជីវសុវត្ថិភាពជំងឺហ្សូណូស ជំងឺសត្វឆ្លងដែន និងការគ្រប់គ្រងកាកសំណល់រឹង និងរាវ

- បានទៅខេត្តកំពង់ឆ្នាំងដើម្បីសិក្សាស្រាវជ្រាវពីវត្ថុធាតុដើមសម្រាប់ផលិត និងការប្រើប្រាស់ថ្នាំពុលកសិកម្មធម្មជាតិ

- បានចុះពិនិត្យស្ថានភាពមេគោដើម្បីបង្កាត់សិប្បនិម្មិត និងស្ថានភាពទូទៅនៅស្ថានីយពិសោធន៍កសិកម្មត្រាំកក់ខេត្តតាកែវ២លើក

- បានទៅកាន់ខេត្តព្រៃវែងដើម្បីពិនិត្យការពិសោធន៍ដំណាំស្រូវពូជនាំចូលពីប្រទេសជប៉ុន ដែលអនុវត្តគម្រោងដោយដៃគូអភិវឌ្ឍន៍របស់វិទ្យាស្ថាន។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៥៨៨នាក់ (ស្រី២៦៨នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កក្តាចង្រៃលើដំណាំខាត់ណាផ្កា

- ពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប
- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច
- បានបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងវិភាគបាក់តេរីនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

**១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- តាមដានស្រង់ និងបញ្ចូលទិន្នន័យចម្ការពិសោធន៍ក្នុងនិងក្រៅស្ថានីយចំនួន ១៧ចម្ការពិសោធន៍
- សហការជាមួយអង្គការ WWF-កម្ពុជា ក្នុងការរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការយកផលទឹកជ័ររបស់កៅស៊ូគ្រួសារ នៅខេត្តមណ្ឌលគិរី
- តាមដានស្រង់បញ្ចូលទិន្នន័យគ្រប់ចម្ការពិសោធន៍នៅក្នុងស្ថានីយចំនួន១៣ និងក្រៅស្ថានីយចំនួន១
- រៀបចំបង្កើតចម្ការពិសោធន៍ឥទ្ធិពលនៃការបើកមុខចៀរនៅទំហំដើមខុសៗគ្នា
- បណ្តុះបណ្តាលមន្ត្រីក្នុងការរៀបចំលាយសូលុយស្យុងវត្ថុធាតុគីមី និងវិភាគរកស្តង់ដារសរីទឹកជ័រ (LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (R-SH)
- យកសំណាក និងវិភាគ (LD) ចម្ការពិសោធន៍ការប្តូរផ្ទាំងចៀរចំនួន១ ស្មើនឹង២០សំណាក
- បាញ់ថ្នាំការពារ និងព្យាបាលជំងឺផ្កាកុលាបនៅតាមប្រគៀបមែកកៅស៊ូចាប់ពីអាយុ៣ឆ្នាំ ដល់ ១០ឆ្នាំ លើផ្ទៃដី១៦១,៦៦ហ.ត
- វិភាគ pH ដី ចំនួន ១៨០សំណាក
- ត្រួតពិនិត្យការប្រមូលផលជ័រកៅស៊ូ និងការកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រ
- ធ្វើតេស្ត និងចេញលទ្ធផលតេស្តដល់រោងចក្រកៅស៊ូសន្លឹកចំនួន ៤២សំណាក
- វិភាគកៅស៊ូដុំ (TSR) របស់ក្រុមហ៊ុន អិមអរធី រ៉ាប់ប៊ើ ផ្លេនថេសិនសរុបចំនួន ៣សំណាក
- វិភាគកៅស៊ូដុំ (CSR) របស់ក្រុមហ៊ុន ខេម អេគ្រី រ៉ាប់ប៊ើរ ឯ.ក (ខេត្តព្រះវិហារ) សរុបចំនួន ១០សំណាក។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ១ ៩៨៣ ០៤៥ហ.ត ស្មើនឹង៧៦,០១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

**១ ផ្នែកដាំដុះ**

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០២១
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩

១៣

- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

## ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្គុរ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការ

១៤

បណ្ដុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

### ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្ដីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប
- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្ដីពីជលផលឱ្យបានតឹងរ៉ឹងបំផុត
- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

### ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ
- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្ដាអង្គភាពក្រោមឱវាទនិងបណ្ដាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក
- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី
- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្ដែង រួមទាំងការរៀបចំវគ្គបណ្ដុះបណ្ដាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក
- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្ដង់ដារ។

ថ្ងៃអង្គារ ១២រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

១៥

# សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញទទួលជួបលោកស្រី **Veena Reddy** ជានាយកទីភ្នាក់ងារ USAID ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងសហការីក្នុងឱកាសដែលលោកស្រីត្រូវបញ្ចប់បេសកកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការីអញ្ជើញ ចុះពិនិត្យខ្សែច្រវាក់ផលិតកម្មជីធម្មជាតិ របស់ក្រុមហ៊ុន ហ៊ុនយន់ អេហ្គ្រីខលឈ័រ នៅភូមិតាឡាក់ ឃុំក្សេមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការី អញ្ជើញចុះពិនិត្យ និងវាយតម្លៃដោយផ្ទាល់លើវឌ្ឍនភាពនៃការងារពិសោធន៍ ស្រាវជ្រាវពូជដំឡូងមីនៅក្នុងកសិដ្ឋានផលិតពូជដំណាំកសិកម្ម ខ្ពង់រាបចម្ការលើ ខេត្តកំពង់ចាម




ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការីអញ្ជើញចុះពិនិត្យវឌ្ឍនភាពរបស់ស្ថានីយដាំឈើម្យៅក្រដាសសម្ដេច **ហ៊ុន សែន** មានក ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង




ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ  អញ្ជើញចុះពិនិត្យនិងវាយតម្លៃលើវឌ្ឍនភាពនៃគម្រោងសាងសង់ប្រព័ន្ធស្រោចស្រពបន្លែ នៅភូមិត្រពាំងក្រសៃកើត ឃុំគោគគង់លិច ស្រុកកញ្ជៀច ខេត្តព្រៃវែង




ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការីអញ្ជើញចុះពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃផលិតកម្មចិញ្ចឹមជ្រូកសាច់ នៅខេត្តកំពង់ធំ





ឯកឧត្តម **នុត ច័ន្ទសុខា** រដ្ឋលេខាធិការប្រចាំការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអញ្ជើញ ជាអធិបតីភាពក្នុងពិធីប្រកាសសចូលកាន់តំណែង លោក ឡេ ប៊ុណ្ណា ជានាយកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជំនួសលោកបណ្ឌិត អ៊ុក ម៉ាការា ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍



ឯកឧត្តម **ឱម គឹមស៊ា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងកិច្ចប្រជុំលើកទី២របស់ក្រុមការងារបច្ចេកទេសរៀបចំកសាងគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័នជាតិនៅកម្ពុជាឆ្នាំ២០២១-២០៣០



ឯកឧត្តម **ណៅ ធួក** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំ ក្រុមការងារទប់ស្កាត់និងបង្ក្រាបបទល្មើសដឹកជញ្ជូនផលិតផលជលផលនាំចូលខុសច្បាប់នៅខេត្តកណ្ដាល



ឯកឧត្តម **ហាស់ សារ៉េត** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជួបសំណេះសំណាល និងចែកកូនត្រីអណ្ដែង និងសម្ភារចិញ្ចឹមត្រីមួយចំនួនទៀតជូនកសិករក្នុងអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ ១៩ នៅខេត្តត្បូងឃ្មុំ



ឯកឧត្តម **ណយ លន់** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចុះទស្សនៈកិច្ចកសិដ្ឋានចិញ្ចឹមគោយកកូន និងយកសាច់របស់កសិករ ហួត លាង នៅភូមិតារាម ឃុំចុងជាច ស្រុកតំបែរ ខេត្តត្បូងឃ្មុំ



ឯកឧត្តម **គឹម សុន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជួបសំណេះសំណាលចែកពូជដំណាំ និងពិនិត្យស្ថានភាពដំណាំស្រូវជូនប្រជាកសិករ នៅខេត្តស្វាយរៀង



ឯកឧត្តម **អ៊ុង សំអាត** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចុះពិនិត្យវឌ្ឍនភាពក្រុមហ៊ុនចម្ការកៅស៊ូវិនិយោគស៊ីហ្សវីសសស៍ លីមីធីត ខេត្តក្រចេះ និងក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខេត្តត្បូងឃ្មុំ




ឯកឧត្តម **គុយ ម៉ារិនឌី** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមន្ទីរពិសោធន៍ជាតិកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ឯកឧត្តម **ចាន់ សុខុឡា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីចែកកូនត្រីអណ្តែងសម្ភារចិញ្ចឹមត្រី តង់ ចំណីត្រី ម្សៅវីតាមីនជូនប្រជាកសិករចិញ្ចឹមត្រីចំនួន៥០គ្រួសារ នៅខេត្តបាត់ដំបង




ឯកឧត្តម **គិត សេង** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងពិធីបើកសិក្ខាសាលាលើសេចក្តីព្រាងចុងក្រោយនៃផែនការមេអភិវឌ្ឍកសិកម្មឆ្នាំ២០២៣



ឯកឧត្តម **មាស ពិសិទ្ធ** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធី បើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៣ អាណត្តិទី១លើការងារពិនិត្យកែសម្រួលសមាសភាពគណៈកម្មាធិការលទ្ធកម្ម និងការងារផ្សេងៗមួយចំនួនទៀត



# មច្ឆា

បទពាក្យប្រាំបី

- មច្ឆាស្នេហ៍ទឹក ជាតិម្រឹគស្នេហ៍ព្រៃ ពឹងពាក់ប្រាស្រ័យ និស្ស័យមាត់ធ្មេញ
  ភ្នំជ្រោះឃ្លាំងព្រឹក្សហ្វូងម្រឹគពាសពេញ ទឹករាក់ក្តៅដេញ អោយចេញមច្ឆា ។

- ជម្រក ត្រីបឹង កុំប្រឹងកាប់ដុត ព្រៃលិចទឹកស្តុក ថែទុកកុំឆ្ការ
  ក្នុងទឹកខ្សត់ត្រី គប្បី ជួយស្តារ ពូជជាតិមច្ឆា គោលការណ៍លើកស្ទួយ។

- គួរជួយកំណើន បង្កើនធារពូជ មច្ឆាល្អិតតូច កើនស្រួចផលត្រួយ
  កូនចៅផៅញាតិ ចាកឃ្លាតទុក្ខព្រួយ បើថែលើកស្ទួយ ផលជួយស្តុកស្តម្ភ។

- ឱ! ទេពទន្លេ ឆ្នេរ ស្ទឹង បឹង ព្រែក សូមនាំសម្រែក ចំណែក ត្រីសុំ
  រសជាតិអាហារ វិសាលត្រីធំ សល់តយូរលង់ ពូជពង្សមច្ឆា។

- នេសាទទឹកសាប នេសាទទឹកប្រៃ ឧបករណ៍សម័យ គប្បីយល់ការ
  កំណែទំរង់ ទ្រទ្រង់មច្ឆា នេសាទគ្រួសារ រដ្ឋាប្រណី។

- សត្វស្លាបទឹកគោក រងោកខ្សៀវខ្សារ ទំមែកព្រឹក្សា វស្សាយប់ថ្ងៃ
  ខែប្រាំង ជួបជុំមនោរម ប្រុសស្រី រីករាយស្បៀងត្រី ប្រពៃមាតុភូមិ។

រៀបរៀងដោយៈ ជីម ងួន
អតីតអគ្គនាយករងទី១នៃអគ្គនាយកដ្ឋានចំការកៅស៊ូ







ការផ្សាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ